ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភាសាខ្មែរ

៦



PUBLISHING AND DISTRIBUTION HOUSE

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

## ថ្នាក់ទី ៦

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោកស្រី ឈីន ស៊ីវឡេង | លោក យ៉ង់ កំស៊ាន |
| | លោកស្រី ស៊ុន សូម៉ាណា | លោកស្រី ជា ចាន់នារី |
| **អ្នកវាយអត្ថបទ** | លោក អ៊ុំ បុប្ផា | |
| **វិចិត្រករ** | លោក ឃុន សុវណ្ណរិទ្ធី | |
| **អ្នករៀបរៀង** | លោកជំទាវ ទន់ សាអ៊ីម | |
| **អ្នករចនាទំព័រ** | លោក ខែម ម៉ារី | |
| **គណៈកម្មការពិនិត្យ** | លោកស្រី យ៉ក់ បូឡែន | លោកស្រី ឃាត ថារី |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២៧២០ អយក.ប្រក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ2016

ISBN 9-789-995-001-438

# អារម្ភកថា

ប្អូនៗកុមារា កុមារី ជាទីស្នេហា !

សៀវភៅភាសាខ្មែរថ្នាក់ទី៦ នេះ ត្រូវបាននិពន្ធតាមកម្មវិធីសិក្សាថ្មី ។ សៀវភៅនេះនឹងជួយប្អូនៗក្នុងការអភិវឌ្ឍចំណេះដឹងគ្រឹះផ្នែកភាសាខ្មែរដូចជា បំណិនអាន សរសេរ ស្ដាប់ និងនិយាយ ។ ខ្លឹមសារនៃសៀវភៅនេះទាក់ទងនឹងប្រធានបទល្អៗដូចជា ទំនៀមទម្លាប់ ប្រពៃណីខ្មែរ ជំនឿ សាសនា តន្ត្រី សិល្បៈ ទេសចរណ៍និងចំណេះដឹងសំខាន់ៗជាច្រើនទៀតដែលមានប្រយោជន៍សម្រាប់ប្អូន ។

តាមរយៈសៀវភៅនេះប្អូនៗនឹងបានសិក្សាកំណាព្យ រឿងនិទាន អត្ថបទសន្ទនា លំហាត់អាន និងលំហាត់សរសេរងាយៗដែលប្អូនអាចយល់ និងអាចធ្វើបានគ្រប់មេរៀន ។ ជាពិសេសនៅចុងបញ្ចប់នៃមេរៀននីមួយៗ ប្អូននឹងអាចធ្វើការស្ទាបស្ទង់សមត្ថភាពខ្លួនផ្ទាល់ដើម្បីធ្វើស្វ័យវាយតម្លៃលើការសិក្សាកន្លងមក ។

ដោយឡែក នៅផ្នែកខាងក្រោយនៃសៀវភៅនេះ មានបទានុក្រមដែលអាចជួយប្អូនៗឱ្យបានយល់ដឹងអំពីន័យរបស់ពាក្យពិបាក ដែលមាននៅក្នុងសៀវភៅនេះ និងសូរអានរបស់ពាក្យនីមួយៗដែលប្អូនអាចហាត់អានពាក្យទាំងនោះ មុននឹងអានអត្ថបទនៅក្នុងមេរៀន ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភាសាខ្មែរថ្នាក់ទី៦ ថ្មីនេះ អាចផ្ដល់ចំណេះដឹងល្អៗ ដើម្បីពង្រឹងសមត្ថភាពភាសាខ្មែរនិងជួយឱ្យសតិបញ្ញាស្មារតីចម្រើនលូតលាស់ឆាប់រហ័ស ។

សូមឱ្យប្អូនៗទទួលបានជោគជ័យក្នុងការសិក្សា ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ


មេរៀនទី១ ៖ អ្នកមានគុណ ........................................ ១

មេរៀនទី២ ៖ ក្ដីសង្ឃឹមរបស់កុមារ.................................. ១៧

មេរៀនទី៣ ៖ ធនធានរ៉ែនៅប្រទេសកម្ពុជា.............................. ៣៣

មេរៀនទី៤ ៖ ប្រយោជន៍នៃធម្មជាតិ.................................. ៤៧

មេរៀនទី៥ ៖ ធនធានជលផលនៅកម្ពុជា.............................. ៦១

មេរៀនទី៦ ៖ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ............................ ៧៧

មេរៀនទី៧ ៖ តន្ត្រីនិងសិល្បៈបុរាណ................................ ៨៩

មេរៀនទី៨ ៖ ជំនឿនិងសាសនា .................................... ១០១

មេរៀនទី៩ ៖ រមណីយដ្ឋានទេសចរណ៍នៅកម្ពុជា.................... ១១៥

មេរៀនទី១០៖ សេចក្ដីថ្លៃថ្នូរ........................................ ១២៥

តែសអំណាន ៖............................................... ១៤១

បទានុក្រម ៖............................................... ១៤៥

**មេរៀនទី ១**

# អ្នកមានគុណ



អ្នកមានគុណ គឺអ្នកដែលបានធ្វើអំពើល្អគ្រប់បែបយ៉ាងដូចជា ចិញ្ចឹមបីបាច់ ថែទាំ ទូន្មានប្រៀនប្រដៅបង្ហាត់បង្រៀន និងឧបត្ថម្ភគាំទ្រដល់យើង ។ អ្នកមានគុណមានមាតាបិតា ជីដូនជីតា បងប្អូន គ្រូបាអាចារ្យ និងឧបការី ឧបការិនីដទៃទៀតដែលបានជួយទំនុកបម្រុងយើង ។

យើងត្រូវតបស្នងគុណអ្នកទាំងនោះឱ្យបានសមរម្យ ។

# ការប្រើវចនានុក្រម




ពេលអ្នកអានអត្ថបទអ្វីមួយហើយជួបប្រទះពាក្យដែលអ្នកមិនចេះអាន ឬមិនយល់ន័យ អ្នកអាចបើកមើលក្នុងវចនានុក្រម ។ វចនានុក្រមនឹងបង្ហាញអ្នកអំពីសូរអាន ថ្នាក់ពាក្យ ប្រភព និងសេចក្ដីពន្យល់ន័យរបស់ពាក្យនោះ ។ មុននឹងប្រើវចនានុក្រម អ្នកគប្បីស្គាល់អក្សរសង្ខេបនិងគ្រឿងសម្គាល់ខ្លះៗជាមុនសិន ។

ចូរអ្នកសិក្សាអក្សរសង្ខេបមួយចំនួនខាងក្រោម ៖

| | | |
|---|---|---|
| កិ. គឺកិរិយា | ច្រ.ប្រ. គឺច្រើនប្រើជា | បា.ស. គឺបាលីនិងសំស្ក្រឹត |
| កិ.នុ. គឺកិរិយានុគ្រោះ | ន. គឺនាមស័ព្ទ | បារ. គឺបារាំង |
| កិ.វិ. គឺកិរិយាវិសេស | និ. គឺ និបាតស័ព្ទ | ម.ព. គឺមើលពាក្យ |
| ក្ល.ម. គឺក្លាយមកជា | ប. គឺបរិវាស័ព្ទ | យ. គឺយួន(ភាសាយួន) |
| គុ. គឺគុណនាម | បា. គឺបាលី | រ.ស. រាជស័ព្ទ |
| ច្រ.ន. គឺច្រើននិយាយថា | បា.ក្ល. គឺបាលីក្លាយ | ល. គឺលាវ(ភាសាលាវ) |
| | | ស. គឺសៀម(ភាសាសៀម) |

ពាក្យនៅខាងដើមជួរនីមួយៗ ជាពាក្យដែលត្រូវពន្យល់។ ពាក្យនេះ ហៅថា "មេពាក្យ"។ គេសរសេរមេពាក្យដោយប្រើអក្សរធំ ដិត។ គេតម្រៀបមេពាក្យទាំងនោះ តាមលំដាប់តួអក្សរ (លំដាប់ព្យញ្ជនៈនិងលំដាប់ស្រៈ)។ អក្សរក្នុងវង់ក្រចកជាសូរអានមេពាក្យ។ អក្សរកាត់នៅបន្ទាប់ពីសូរអានគឺជាថ្នាក់ពាក្យ រីឯអក្សរកាត់នៅក្នុងវង់ក្រចកបន្ទាប់ពីថ្នាក់ពាក្យ ប្រាប់ប្រភពរបស់ពាក្យនេះ។ បន្ទាប់ពីថ្នាក់ពាក្យ ឬប្រភពពាក្យ គឺជាសេចក្ដីពន្យល់ន័យរបស់មេពាក្យ។

ខាងក្រោមនេះ ជាគំរូខ្លះនៃវចនានុក្រមខ្មែរ (គេនិយមហៅថាវចនានុក្រមសម្ដេចជួន ណាត)៖

**កវី** (ក:វ៉ី) *ន.* (សំ.បា.កវី) អ្នកប្រាជ្ញដែលចេះតែងកាព្យឃ្លោង (អ្នកប្រាជ្ញខាងសម្ដី)។

**កវីនិពន្ធ** (-និពន់) *ន.* (បា.កវី+និពន្ធ) កវីជាអ្នកនិពន្ធ អ្នកនិពន្ធខាងកាព្យឃ្លោង។

**កសិកម្ម** (ក: សិ កាំ) *ន.* (បា.) ការភ្ជួររាស់ ការងារដែលគេប្រកបក្នុងការភ្ជួររាស់ គឺការធ្វើស្រែចម្ការ។

**កសិករ** (-ក) *ន.* ឬ *គុ.*(បា.)។ ម.ព.កសិការ។

**កសិការ** (-កា) ន. ឬ គុ.(បា.) អ្នកធ្វើកសិកម្ម។

**កសិណ** (ក:-សិន)*គុ.*(បា.)"ទាំងអស់"។ *ន.* រូបតាងជាសម្គាល់: កសិណសាក្សី យើងនឹងយកពាក្យនេះជាកសិណ មិនបានទេ។

**កា១** *ន.* ចំពង់សម្រាប់ដាក់ទឹក ធ្វើដោយលោហធាតុផ្សេងៗ ឬដោយដីលាយពណ៌: កាទឹក។

**កា២** *កិ.* សរសេរអាសយដ្ឋាន គឺសរសេរចុះឈ្មោះលំនៅអ្នកដែលនឹងទទួលសំបុត្រ នៅស្រោមសំបុត្រដែលនឹងផ្ញើទៅ: *កាស្រោមសំបុត្រសរសេរថែមសេចក្ដីផ្សេងៗលើខ្នងសំបុត្រជាសញ្ញា: កាខ្នងសំបុត្រ*។

**កាកគតិ** (កាក-គ: តិ) *ន.*(បា.) ឈ្មោះបទកាព្យពាក្យ ៤ (បទដំណើរក្អែកលោត): នេះគឺច្បាប់ក្រម ប្រសើរឧត្ដម ទូន្មានអ្នកផង ប្រើឱនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង កើតដោយប្រណិប័តន៍...។

> វចនានុក្រម គឺជាបញ្ជីពាក្យដែលត្រូវបានរៀបតាមអក្ខរក្រម (លំដាប់អក្សរ) ដោយមានសូរអាន ថ្នាក់ពាក្យ ប្រភពពាក្យ និងសេចក្ដីពន្យល់ន័យមេពាក្យ។

## លំហាត់

ក. ចូរអានពាក្យខាងក្រោម រួចប្រាប់ថ្នាក់ពាក្យ និងន័យមេពាក្យក្នុងវចនានុក្រម ៖

បរិបូរ (ប-រិ៉បូឬ ប-បូ) *គុ.* (បា.សំ.) ដែលគ្រប់គ្រាន់ ដែលពេញគ្រប់គ្រាន់ ពេញលេញសម្បូរ ដែលឆ្អែតហើយ : ម្ហូបចំណីបរិបូរ ។

បរិភោគ (បរិ៉ភោគ) *ន.*(បា.សំ.) ការចម្អែតអាត្មា(ស៊ី) ។

បរិយាយ (បរិ៉យ៉ាយឬប៉-)*ន.*(បា.សំ.បយ៉ាយ) សេចក្ដីអធិប្បាយដោយផ្សៃផ្សំ ការអធិប្បាយសម្រួលសេចក្ដី : ពោលដោយបរិយាយ ។

បរិសុទ្ធ (បរិ៉សុត) *គុ.*(បា.) ដែលស្អាត ឥតសៅហ្មង : ចិត្តបរិសុទ្ធ ។

បវរ (បវ៉ៈ)*គុ.*(បា.សំ.ប្រវរ) ប្រសើរ លើសលែង ថ្លៃថ្លា : ទ្រព្យដ៏បវរ ។

បដិវត្ត (ប៉ៈដិវ៉ាត់) *កិ.* ប្រព្រឹត្តប្រឆាំង ប្រែប្រួល កែប្រែ ផ្លាស់ប្ដូរ (របបគ្រប់គ្រងដើម្បីឱ្យបានចម្រើន) ។

បដិសេធ (ប៉ៈដិសែត)*កិ.* (បា.សំ.)ឃាត់ហាម លើកចោល ឬទាត់ចោលលែងយកជាការ លែងរាប់អានៈ បដិសេធពាក្យ ។

បឋម (ប៉ៈ ឋៈ ម៉ៈ ឬ ប៉ៈ ឋំ) *ឬ.សំ.ឬ គុ.* (បា.សំ.ប្រថម)ដំបូង មុន មុនគេ ទី១ : គ្រាជាបឋម ។

បណ្ណាគារ (ប៉ុន-ណា-គារ) *ន.* (បា, សំ. បណ៌ាគារ) ផ្ទះដាវសៀវភៅ , សាស្ត្រា , ក្បួន , ច្បាប់ ។

ខ. ចូររៀបពាក្យខាងក្រោមឱ្យត្រូវតាមលំដាប់អក្សរ រួចពន្យល់ន័យពាក្យទាំងនេះដោយប្រើវចនានុក្រម ។

១. សោមនស្ស

២. មាតា

៣. ឧបត្ថម្ភ

៤. គង្គា

៥. ឧបការី

៦. មេត្តា ។

គ. ចូរបង្កើតល្បះដោយប្រើពាក្យនីមួយៗខាងលើ ។

# កតញ្ញូប្រាំប្រការ



(បទពាក្យប្រាំពីរ)

កូនត្រូវតបគុណម្តាយឪពុក     ផ្គត់ផ្គង់ហូបចុកគ្រឿងធានា
សម្លៀកបំពាក់ថ្នាំការពារ     ឈឺគ្រុនរងាញ័រញាក់ក្តៅ ។
ត្រូវជួយធុរៈអ្នកមានគុណ     កាប់គាស់រែកពុនកុំហ្មងសៅ
ទោះបីនឿយហត់ត្រជាក់ក្តៅ     មើលថែម៉ែឪឱ្យលោកស្រាន្ត ។
ត្រូវចេះរក្សាពូជពង្សញាតិ     មិត្តភក្តិផងទៀតផៅសន្តាន
កេរ្តិ៍ឈ្មោះត្រកូលឱ្យថ្កើងថ្កាន     ជៀសវាងឱ្យបានកុំទាស់គ្នា ។
កូនត្រូវបម្រើអ្នកមានគុណ     វាចាទន់ភ្លន់គ្រប់វេលា
ព្រោះជាព្រះរស់នៃបុត្រភ្វា     កូនត្រូវវន្ទាដោយភក្តី ។
នៅពេលមាតាឬបិតា     រលត់សង្ខារលាលោកិយ
កូនធ្វើបុណ្យតាមប្រពៃណី     បុត្រាបុត្រីត្រូវចងចាំ ។

## សំណួរ

១. តើពាក្យ "កតញ្ញូ" មានន័យដូចម្ដេច ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

២. តើកូនត្រូវមានកតញ្ញូប៉ុន្មានប្រការចំពោះម្ដាយឪពុក ?

៣. ចូរពន្យល់អត្ថន័យនៃប្រការនីមួយៗ នៅក្នុងកំណាព្យនេះ ។

៤. តើអ្នកបានធ្វើអ្វីខ្លះដើម្បីសងគុណម្ដាយឪពុកអ្នក ?

៥. តើអត្ថបទកំណាព្យនេះ និយាយអំពីអ្វី?

៦. តើអត្ថបទកំណាព្យនេះ មានគំនិតអប់រំដូចម្ដេច ?

៧. តើកំណាព្យនេះមានប៉ុន្មានវគ្គ ? តើក្នុងមួយវគ្គមានប៉ុន្មានឃ្លា ?

៨. ចូរប្រាប់ពាក្យចួនក្នុងវគ្គនិងពាក្យចួនឆ្លងវគ្គនៅក្នុងកំណាព្យខាងលើ ។

## លំហាត់

ក. ចូរប្រើវចនានុក្រមដើម្បីពន្យល់ន័យពាក្យ ៖

ធុរៈ ស្រាន្ត ពង្ស ញាតិ កេរ្តិ៍ វន្ទា សន្តាន សង្ខារ ឧទ្ទិស ។

ខ. ចូរគូសភ្ជាប់ពាក្យដែលមានន័យដូចគ្នាឱ្យបានត្រឹមត្រូវ ។

| | |
|---|---|
| ១. វាចា | ក. ម្ដាយ |
| ២. សព | ខ. សម្ដី |
| ៣. បុត្រ | គ. ឪពុក |
| ៤. វន្ទា | ឃ. កូន |
| ៥. មាតា | ង. ខ្មោច |
| ៦. បិតា | ច. សំពះ ។ |

## សំណេរ

ក. ចូរតែងល្បះដោយប្រើពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

គុណ ៖ ............................................................................ ។

ចិញ្ចឹម ៖ ............................................................................ ។

សងគុណ ៖ ............................................................................ ។

ស្រឡាញ់ ៖ ............................................................................ ។

ខ. ចូរតែងល្បះទាក់ទងគ្នាតាមរូបភាពនេះឱ្យបាន៥ ល្បះ ។



គ. ចូរអ្នកសរសេរតែងសេចក្ដីពណ៌នាអំពីម្ដាយរបស់អ្នកដោយប្រើគម្រោងខាងក្រោម ៖

១. សេចក្ដីផ្ដើម

- ឈ្មោះ អាយុ មុខរបរ
- ទីកន្លែងរស់នៅ ។

២. តួសេចក្ដី

- រូបសម្បត្តិ ៖ រូបរាង សម្បុរ ទម្រង់មុខ សក់ ភ្នែក ច្រមុះ មាត់ ដៃជើង...
- ចរិយាសម្បត្តិ ៖ ស្លូត កាច ព្យាយាម យោគយល់ អធ្យាស្រ័យ...
- សកម្មភាព ៖ ទំនាក់ទំនង សាមគ្គីភាព ការចិញ្ចឹមបីបាច់កូន... ។

៣. សេចក្ដីបញ្ចប់

ចំណាប់អារម្មណ៍ចំពោះម្ដាយអ្នក ។

## ការកត់ត្រាគំនិតសំខាន់ៗនៅក្នុងកំណាព្យ

ពេលអ្នកស្តាប់ ឬអានអត្ថបទអ្វីមួយ អ្នកគួរកត់ត្រាចំណុចសំខាន់ៗព្រោះធ្វើឱ្យអ្នកងាយចងចាំ ងាយយល់អត្ថបទនោះ ។ ការកត់ត្រានេះ មិនទាមទារឱ្យអ្នកសរសេរជាល្បះពេញលេញទេ គឺសរសេរតែពាក្យ ឬកន្សោមពាក្យសំខាន់ៗប៉ុណ្ណោះ ។

ចូរអានកំណាព្យខាងក្រោម ដោយកត់សម្គាល់គំនិតសំខាន់ៗ ។

(បទកាកគតិ)

ត្រូវធ្វើបុណ្យខ្មើត ម៉ែឪស៊ីកើត កំពុងស្រែកឃ្លាន
ម៉ែឪរស់នៅ កូនត្រូវធ្វើទាន បំបាត់ក្តីឃ្លាន
ហៅធ្វើបុណ្យខ្មើត ។

ហៅបុណ្យខែភ្លឺ កុំចាំគាត់ឈឺ ពិសាលែងកើត
ជូនគាត់ពេលជា ហៅថាបុណ្យខ្មើត គាត់ពិសាកើត
បានជាងរនោច ។

លុះបាត់ជីវិត បុណ្យខែងងឹត ដូចថ្ងៃដប់រោច
កូនចៅទាំងឡាយ យកបាយឱ្យខ្មោច ម៉ែឥតប្រយោជន៍
ខ្មោចណាចេះស៊ី ។

(ដកស្រង់ចេញពី ច្បាប់គោរពមាតាបិតា របស់លោក អ៊ូ ចុង)

គំនិតសំខាន់ៗនៅក្នុងកំណាព្យនេះមាន ៖

- ត្រូវធ្វើបុណ្យទាន់ខែភ្លឺ ឬខ្មើត : ម៉ែឪនៅរស់ ម៉ែឪពិសាកើត កំពុងស្រេកឃ្លាន កូនត្រូវជូនចំណីអាហារ កុំចាំគាត់ឈឺពិសាលែងកើត ។
- ធ្វើបុណ្យខែងងឹត : ម៉ែឪបាត់ជីវិត យកបាយឱ្យខ្មោចស៊ី ម៉ែឪឥតបានប្រយោជន៍ ។

ការកត់ត្រាគំនិតសំខាន់ៗ គឺការកត់ពាក្យ កន្សោមពាក្យ ឃ្លាដែលប្រាប់គំនិតសំខាន់ៗក្នុងអត្ថបទ ។

## លំហាត់

ចូរអាននិងសូត្រកំណាព្យខាងក្រោម រួចកត់ត្រាគំនិតសំខាន់ៗ ។

### សន្ដានចិត្តរបស់អ្នកម្ដាយ

### (បទព្រហ្មគីតិ)



ពេលកូនមកចាប់ផ្ទៃ ក្នុងហឫទ័យម្ដាយសប្បាយ
ម៉ែតែងតែខ្វល់ខ្វាយ រកឧបាយថែរក្សា ។
ធ្វើអ្វីតែងប្រយ័ត្ន មិនឱ្យភ្លាត់ខ្លាចប៉ះពារ
ឱ្យកូនបានសុខជា ម្ដាយធានាគាំពារស្ងួន ។
ស៊ូនឿយព្រោះថ្លើមថ្លៃ រង់ចាំថ្ងៃប្រសូតនួន
បានឃើញមុខកូនស្ងួន ថ្នមថែជូនព្រោះស្រឡាញ់ ។

# ៦ ការគោរពលោកគ្រូ អ្នកគ្រូ



## សំណួរ

១. តើសិស្សត្រូវធ្វើអ្វីខ្លះ ចំពោះលោកគ្រូ អ្នកគ្រូ ?

២. ហេតុអ្វីបានជាសិស្សត្រូវគោរពលោកគ្រូ អ្នកគ្រូ ?

៣. តើអត្ថបទកំណាព្យនេះ មានគំនិតអប់រំដូចម្ដេច ?

## លំហាត់

ចូរគូសសញ្ញា✓ នៅមុខល្បះដែលជាគំនិតសំខាន់ៗនៅក្នុងអត្ថបទកំណាព្យ ។

☐ ១. សិស្សក្រោកឈរនិងប្រកាន់ការស្ងៀមស្ងាត់ពេលគ្រូមកដល់ ។

☐ ២. សិស្សត្រូវធ្វើត្រាប់តាមពុតគ្រូ ។

☐ ៣. សិស្សធ្វើកិច្ចការដែលគ្រូដាក់ឱ្យដោយផ្ចិតផ្ចង់ ។

☐ ៤. សិស្សយកចិត្តទុកដាក់ស្ដាប់គ្រូពន្យល់ ។

☐ ៥. សិស្សត្រូវមានស្មារតីសាមគ្គីភាព ។

☐ ៦. សិស្សត្រូវចូលរួមរំលែកទុក្ខរបស់គ្រូ ពេលគាត់មានធុរៈ ។

# គុណនាមចំនួន

គុណនាម គឺជាប្រភេទពាក្យម្យ៉ាងដែលប្រាប់លក្ខណៈរបស់នាម ។ អ្នកធ្លាប់បានសិក្សារួចមកហើយអំពីប្រភេទផ្សេងៗនៃគុណនាម ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីគុណនាមចំនួន ។ គុណនាមចំនួនមានពីរយ៉ាង គឺគុណនាមចំនួនរាប់ និងគុណនាមចំនួនរៀប ។



ក. គុណនាមចំនួនរាប់

១. គ្រួសារសុខាមានមនុស្សចំនួនប្រាំមួយនាក់ ។

២. សុខាមានបងប្អូនបង្កើតចំនួនបួននាក់ ។

៣. ពួកគេកំពុងហូបម្ហូបបីមុខ គឺសម្លទឹកមួយមុខ ឆាមួយមុខ និងត្រីអាំងមួយមុខ ។

៤. គេឃើញមានចានបាយ និងចានម្ហូបទាំងអស់ប្រាំបួន ។

៥. សុខាចិញ្ចឹមឆ្មាមួយ ។

ពាក្យ “ ប្រាំមួយ បួន បី មួយ និងប្រាំបួន” ជាចំនួនរាប់ ។

គុណនាមចំនួនរាប់ គឺជាគុណនាមប្រាប់ចំនួនមនុស្ស សត្វ វត្ថុ ដែលគេរាប់ ។

## ខ. គុណនាមចំនួនរៀប

១. បងប្រុសសុខាជាកូនទីមួយនៅក្នុងគ្រួសារ ។ គេរៀននៅថ្នាក់ទីប្រាំបី ។

២. សុខាជាកូនទីបី ។ នាងរៀននៅថ្នាក់ទីប្រាំមួយ ។

៣. ប្អូនស្រីសុខាជាកូនទីបួន ។ គេរៀនបានលេខ២ ។

៤. គ្រួសារនេះ ហូបបាយថ្ងៃត្រង់នៅម៉ោងដប់មួយគត់ ។

ពាក្យ : ទីមួយ ទីប្រាំបី ទីបី ទីប្រាំមួយ ទីបួន លេខ២ ម៉ោងដប់មួយជាចំនួនរៀប ។

> គុណនាមចំនួនរៀបគឺជាគុណនាមប្រាប់ទី លំដាប់ ជាន់ ឬថ្នាក់ ដែលគេរៀប ។

## លំហាត់

ក. ចូរស្រង់គុណនាមចំនួនរាប់ និងគុណនាមចំនួនរៀបពីក្នុងប្រអប់ទៅដាក់ក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | | |
|---|---|---|---|---|---|---|
| ទីប្រាំ | ដប់ពីរ | ថ្នាក់ទី៣ | ជាន់ទីពីរ | មួយឡូ | បួនរយ | បីពាន់ |
| ទីហាសិប | ម៉ោងប្រាំមួយ | ប្រាំមួយ | សាមសិប | យប់ទីបី | ពីរម៉ឺន | |

| គុណនាមចំនួនរាប់ | គុណនាមចំនួនរៀប |
|---|---|
| ដប់ពីរ ............................... | ទីប្រាំ .................................. |

ខ. ចូរបង្កើតល្បះដោយប្រើគុណនាមចំនួនរាប់ និងគុណនាមចំនួនរៀបខាងក្រោមឱ្យបានត្រឹមត្រូវ ។

បី ទីដប់ លេខបួន ជាន់ទី២ ម៉ោងមួយ ។

# រឿង បងប្រុស



និតនិងនួនជាបងប្អូនបង្កើតនឹងគ្នា ។ តាំងពីអ្នកមានគុណបានចែកឋានទៅ ជីវភាពគ្រួសារពួកគេជួបការលំបាកយ៉ាងខ្លាំង ។ និតជាបងបានសម្រេចចិត្តផ្អាកការរៀនសូត្រមួយរយៈដោយទុកឱ្យប្អូនបានសិក្សាបន្តទៀត ។ នួនខំរៀនណាស់មិនឱ្យបងខកចិត្តឡើយ ។ឯនិតវិញ ពេលទំនេរពីការងារស្រែចម្ការ គេបានចូលសិក្សានៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ ។

ឆ្នាំនេះ នួនរៀននៅថ្នាក់ទី១២ ហើយបានប្រឡងជាប់ដូចប្រាថ្នា ។ ថ្ងៃមួយ នួនចង់ទៅរកការងារធ្វើ ដើម្បីជួយសម្រាលបន្ទុកបង តែនិតមិនយល់ព្រម ។ នួនសួរបង ៖

“ តើយើងបានប្រាក់ពីណា ? ” ។

និតឆ្លើយ ៖ “ ឯងកុំបារម្ភ ! ទុកឱ្យបងជាអ្នកដោះស្រាយ ” ។

រាត្រីនោះ និតនិទ្រាមិនលក់សោះ ព្រោះខ្លួនមិនដឹងទៅប្រកបរបរអ្វីដើម្បីរកបានប្រាក់ឱ្យប្អូនរៀននោះទេ ។ ពីមួយថ្ងៃទៅមួយថ្ងៃ និតចេះតែជញ្ជឹងគិតរកមុខរបរផ្សេងៗ តែនឹកមិនឃើញសោះ ។ ចំណែកនួនអាណិតបងខ្លាំងណាស់ ។ គេតាំងចិត្តថានឹងខិតខំរៀនសូត្រ ដើម្បីបានការងារធ្វើចិញ្ចឹមបងគេវិញ ។

ថ្ងៃមួយ និតនិងអ្នកភូមិខ្លះបាននាំគ្នាទៅខ្ចីប្រាក់ឥណទានពីធនាគារភូមិ យកមកធ្វើជាដើមទុនក្នុងការចិញ្ចឹមជ្រូកនិងត្រី ។ ជាលើកដំបូង និតបានត្រឹមតែរួចដើមប៉ុណ្ណោះ ។ ក្រោយមក និតបានរៀនបច្ចេកទេសចិញ្ចឹមសត្វពីមជ្ឈមណ្ឌលសិក្សាសហគមន៍ ។ ចាប់ពីពេលនោះមក និតចេះជំនាញចិញ្ចឹមសត្វច្បាស់លាស់ ។ និតអាចរកប្រាក់ឧបត្ថម្ភការសិក្សារបស់នួនដោយមិនជួបការលំបាកដូចមុនទៀតឡើយ ។

2

ក្រោយពីបញ្ចប់ការសិក្សា នួនបានចូលបម្រើការងារក្នុងក្រុមហ៊ុនមួយ នៅរាជធានីភ្នំពេញ ។ នួនសន្សំប្រាក់ខែបានមួយចំនួន ។ គេបានយកប្រាក់ទាំងនោះទៅប្រគល់ជូនបងទាំងអស់ ដើម្បីឱ្យបងបានរៀបអាពាហ៍ពិពាហ៍ ។ ចាប់ពីពេលនោះមក គ្រួសារនេះរស់នៅជាមួយគ្នាប្រកបដោយសុភមង្គល ។

## សំណួរ

១. តើនិតនិងនួនត្រូវជាអ្វីនឹងគ្នា?

២. តើនិតប្រើមធ្យោបាយអ្វី ដើម្បីឱ្យនួនបានបន្តការសិក្សា ?

៣. ហេតុអ្វីបានជានិតតស៊ូចិញ្ចឹមប្អូនឱ្យបានរៀនសូត្រ ?

៤. តើអ្នកពេញចិត្តតួអង្គនិតដែរ ឬទេ ? ហេតុអ្វី ?

៥. តើរឿងនេះ មានគំនិតអប់រំដូចម្តេច ?

## លំហាត់

ក. ចូរប្រើវចនានុក្រមដើម្បីពន្យល់ន័យរបស់ពាក្យ ៖

បច្ចេកទេស ឥណទាន ឧបត្ថម្ភ ធនាគារ សហគមន៍ ។

ខ. ចូររកពាក្យន័យដូចមកជំនួសពាក្យដែលមានគំនូសពីក្រោមក្នុងល្បះនីមួយៗ ។

១. និតបានសម្រេចចិត្តឈប់រៀន ដោយទុកឱ្យនួនបានសិក្សាបន្តទៀតឡើយ ។

២. រាត្រីនេះនិតនិទ្រាមិនលក់សោះ ។

៣. និតអាចរកប្រាក់ឧបត្ថម្ភនួន ដោយមិនមានការលំបាកដូចមុនទៀត ។

៤. និតបានប្រគល់ប្រាក់ជូនបងទាំងអស់ ដើម្បីឱ្យបងបានរៀបអាពាហ៍ពិពាហ៍ ។

## ការតែងរឿងខ្លី

ចូរអ្នកសរសេររឿងខ្លីមួយ រៀបរាប់អំពីគុណរបស់បងប្រុស ឬ បងស្រីអ្នកដែលបានធ្វើចំពោះអ្នក ។

# ការពណ៌នាអំពីអ្នកមានគុណ

ស្រីណែតឃើញឪពុករៀបនំចំណី ផ្លែឈើ នាងឆ្ងល់ណាស់ ក៏សួរឪពុក ។ ចូរអានការសន្ទនារវាងស្រីណែត និងឪពុកនាងខាងក្រោម ៖

ស្រីណែត : លោកប៉ា ! ព្រឹកនេះកូនឃើញប៉ារៀបចំត្រកដាក់ផ្លែឈើ នំចំណី និងទឹកដោះគោ តាំងពីព្រលឹម ។ តើប៉ាបម្រុងអញ្ជើញទៅណា ?

ឪពុក : អូ! កូនស្រី ប៉ាទៅសួរសុខទុក្ខលោកយាយសួននៅឯស្រុក ។ ប៉ានឹកគាត់ណាស់ ។

ស្រីណែត : តើលោកយាយសួនជាអ្នកណា ? កូនឃើញប៉ាយកចិត្តទុកដាក់នឹងគាត់ណាស់ ។

ឪពុក : គាត់ជាម្ដាយមីងរបស់ប៉ា ហើយមានគុណលើប៉ាខ្លាំងណាស់ ។ កាលប៉ានៅរៀន គ្រួសារប៉ាក្រីក្រ ។ លោកយាយបានយកប៉ាទៅនៅជាមួយ ចិញ្ចឹមបាយទឹក ហើយឧបត្ថម្ភប្រាក់កាសឱ្យប៉ារៀនសូត្រ រហូតប៉ាបានការងារធ្វើសព្វថ្ងៃនេះ ។ ហេតុនេះហើយទើបប៉ាមិនភ្លេចគុណគាត់ ។

ស្រីណែត : កូនរំភើបចិត្តណាស់ ។ ក្រៅពីលោកយាយបង្កើត កូននៅមានលោកយាយសួនម្នាក់ទៀត ។ លោកប៉ា! កូនសូមបួងសួងឱ្យពួកគាត់មានអាយុវែង ។

## សំណួរ

១. តើស្រីណែតសួរឪពុកនាងអំពីរឿងអ្វីខ្លះ ?

២. តើឪពុកនាងឆ្លើយដូចម្ដេចខ្លះ ?

## លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ រួចរៀបរាប់ពីអ្នកមានគុណអ្នក ប្រាប់សមាជិកក្រុមអ្នក ។

# ការតែងកំណាព្យ

ចូរអានកំណាព្យបទពាក្យប្រាំពីរខាងក្រោម ដោយកត់សម្គាល់ទីតាំងពាក្យចួនក្នុងវគ្គ និងឆ្លងវគ្គ ។

១ ២ ៣ ៤ ៥ ៦ ៧    ១ ២ ៣ ៤ ៥ ៦ ៧
វគ្គទី១ : ខ្ញុំ សូម វ ន្ទា ចំ ពោះ គុណ    ធំ ហើយ សែន ធ្ងន់ មក លើ ខ្ញុំ
១ ២ ៣ ៤ ៥ ៦ ៧    ១ ២ ៣ ៤ ៥ ៦ ៧
មាន ឪ ពុក ម្តាយ ដ៏ ឧ ត្តម    មីង ពូ បង អ៊ំ ក្រុម គ្រួ សារ ។

វគ្គទី២ : លោក គ្រូ អ្នក គ្រូ ផ្តល់ ចំ ណេះ    ឱ្យ ខ្ញុំ បាន ចេះ មាន ប្រា ជ្ញា
បួង សួង ឱ្យ លោក ជួប សុ ខា    កើត ជាតិ ណា ៗ សូម ជួប ទៀត ។

## សំណួរ

១. តើកំណាព្យខាងលើមានប៉ុន្មានវគ្គ ?
២. តើពីត្រឹមណាដល់ត្រឹមណាដែលហៅថា ១វគ្គ ?
៣. តើកំណាព្យបទពាក្យប្រាំពីរ ក្នុងមួយវគ្គមានប៉ុន្មានឃ្លា ?
៤. តើក្នុងមួយឃ្លាមានប៉ុន្មានព្យាង្គ ?
៥. តើព្យាង្គណាខ្លះចួនគ្នានៅក្នុងវគ្គ ?
៦. តើព្យាង្គណាខ្លះចួនឆ្លងវគ្គ ? ( ឆ្លងពីវគ្គទី ១ មកវគ្គទី ២)

## លំហាត់

ចូរពិនិត្យមើលទីតាំងពាក្យចួននៅក្នុងកំណាព្យបទពាក្យប្រាំពីរខាងលើ រួចតែងកំណាព្យបទពាក្យប្រាំពីរចំនួនបីវគ្គនិយាយពីប្រធានបទណាមួយដែលអ្នកពេញចិត្ត ។

មេរៀនទី

# ២ ក្ដីសង្ឃឹមរបស់កុមារ




កុមារនិងយុវជន មានភារកិច្ចសំខាន់ក្នុងការជួយទ្រទ្រង់ប្រទេសជាតិឱ្យមានការរីកចម្រើន ។ ដើម្បីឱ្យកុមារអាចសម្រេចភារកិច្ចនេះបានល្អ លុះត្រាតែមាតាបិតា អាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងសហគមន៍ផ្ដល់សិទ្ធិពេញលេញដល់កុមារ ការពារកុមារ និងមិនរំលោភបំពានលើសិទ្ធិរបស់ពួកគេ ។

តើកុមារមានសិទ្ធិអ្វីខ្លះ ? តើអ្វីខ្លះជាការរំលោភសិទ្ធិកុមារ ?

# ការសង្ខេបរឿង

នៅពេលណាអ្នកចង់និយាយ ឬសរសេររឿងនិទានណាមួយប្រាប់អ្នកដទៃ អ្នកមិនអាចរៀបរាប់លម្អិតគ្រប់ចំណុចបានទេ អ្នកត្រូវតែសង្ខេបរឿងនោះ ដើម្បីឱ្យអ្នកស្ដាប់ ឬអ្នកអានងាយចងចាំ ។

សង្ខេបរឿង មានន័យថា និយាយ ឬសរសេរបំព្រួញរឿងឱ្យខ្លី ដោយប្រើប្រាស់ពាក្យពេចន៍របស់ខ្លួន ដើម្បីឱ្យគេស្ដាប់បាន និងយល់ខ្លឹមសារសំខាន់ៗនៃរឿងនោះ ។

ដើម្បីសង្ខេបរឿង អ្នកត្រូវអនុវត្តតាមជំហានបន្តបន្ទាប់ខាងក្រោម ៖

១. អានរឿងទាំងមូល និងស្វែងយល់ខ្លឹមសារឱ្យបានច្បាស់លាស់ជាមុន

២. ស្រង់ព្រឹត្តិការណ៍សំខាន់ ឬខ្លឹមសារសំខាន់របស់រឿង

៣. ប្រមូលផ្តុំព្រឹត្តិការណ៍បន្ទាប់បន្សំ ដែលមានក្នុងព្រឹត្តិការណ៍សំខាន់នីមួយៗ

៤. រៀបព្រឹត្តិការណ៍តាមលំដាប់មុនក្រោយ

៥. និយាយ ឬសរសេររឿងនោះឡើងវិញ ដោយផ្អែកលើគម្រោងដែលបានធ្វើរួច ។ អ្នកត្រូវប្រើកន្សោមពាក្យ ឬឈ្នាប់សេចក្តី ដើម្បីភ្ជាប់ព្រឹត្តិការណ៍មួយទៅព្រឹត្តិការណ៍មួយទៀត ឱ្យជាប់រដឹកតាំងពីដើមរហូតដល់ចប់ ។

ចូរអ្នកអានរឿងខាងក្រោម រួចពិនិត្យមើលរបៀបសរសេរ ។

## រឿង ព្រាហ្មណ៍និងស្ការ

មានរឿងតំណាលថា មានព្រាហ្មណ៍ម្នាក់និងភរិយាបានចិញ្ចឹមសត្វស្ការមួយ ។ ព្រាហ្មណ៍ស្រឡាញ់ស្ការនោះដូចកូនបង្កើតដែរ ។

ថ្ងៃមួយ ព្រាហ្មណ៍និងភរិយាមានធុរៈចេញទៅក្រៅ ហើយទុកកូនតូចឱ្យស្ការថែរក្សា ។ ពេលព្រាហ្មណ៍និងភរិយាចេញផុតទៅ មានពស់វែកមួយលួនចូលមកជិតកូននោះ ។ ស្ការឃើញពស់ជាសត្រូវពីកំណើតមកដល់ ក៏ស្ទុះទៅខាំពស់នោះដាច់ជាពីរ បីកំណាត់ភ្លាម ។ ក្រោយមក ស្ការក្រឡេកមើលទៅឃើញព្រាហ្មណ៍កំពុងដើរចូលមកត្រេកអរណាស់ ទាំងមុខមាត់ដៃជើងប្រឡាក់ឈាមក្រហមច្រាលនៅឡើយ ក៏រត់ទៅនឿល

នៅក្បែរជើងព្រាហ្មណ៍ ដើម្បីសម្ដែងអាការត្រេកអរដែលបានបម្រើម្ចាស់ដោយប្រពៃ ។ ឯព្រាហ្មណ៍ឃើញឈាមនៅមុខ មាត់ ជើងស្ការក្រហមច្រាលដូច្នោះ ក៏កំណត់ក្នុងចិត្តឥតពិចារណា ៖ " ស្ការនេះស៊ីកូនអាត្មាអញហើយ " ។ ព្រាហ្មណ៍លើកដំបងសំពងស្ការនោះងាប់ទៅ ។

ភ្លាមនោះ ព្រាហ្មណ៍ក៏ចូលទៅមើលកូន ឃើញកូនសុខសប្បាយធម្មតា ហើយឃើញពស់ដាច់ជាពីរបីកំណាត់ នៅរាត់រាយក្បែរអង្រឹងកូន ទើបដឹងថាស្ការបានជួយជីវិតកូនគាត់ឱ្យផុតពីពស់ចឹក ។ ព្រាហ្មណ៍មានចិត្តសោកស្ដាយក្រៃលែង ។

(សម្រួលពីស្រីហិតោបទេសភាគ៤)

# រឿង ព្រាហ្មណ៍និងស្ការ

កាលអាកាស ៖

- កាល ឬពេលវេលា : ថ្ងៃមួយ ពេលព្រាហ្មណ៍ និងភរិយាចេញផុត ក្រោយមកព្រាហ្មណ៍ចូលទៅមើលកូន ។
- ទីកន្លែង : ផ្ទះព្រាហ្មណ៍ ។

តួអង្គ ៖ ព្រាហ្មណ៍ ភរិយាព្រាហ្មណ៍ ស្ការ ពស់ កូនតូច ។

ព្រឹត្តិការណ៍ ៖

- ព្រាហ្មណ៍និងភរិយាចិញ្ចឹមស្ការ
- ព្រាហ្មណ៍និងភរិយាចេញទៅក្រៅ ទុកកូនតូចឱ្យស្ការថែរក្សា
- ពស់វែកមួយលូនមកជិតកូនតូច
- ស្ការស្ទុះទៅខាំពស់ដាច់ជាពីរបីកំណាត់
- ព្រាហ្មណ៍ត្រឡប់មកវិញ ឃើញស្ការប្រឡាក់សុទ្ធតែឈាម
- ព្រាហ្មណ៍វាយស្ការងាប់
- ព្រាហ្មណ៍ឃើញកូនសុខសប្បាយក៏នឹកស្ដាយស្ការ ។

ចូរអានសេចក្ដីសង្ខេបរឿង " ព្រាហ្មណ៍និងស្កា " ខាងក្រោម ៖

មានតំណាលថា មានព្រាហ្មណ៍និងប្រពន្ធបានចេញទៅក្រៅ ទុកកូនតូចឱ្យនៅជាមួយស្កា ។ ពេលនោះ មានពស់វែកមួយលូនមកជិតកូននោះ ។ ស្កាឃើញពស់ក៏ស្ទុះទៅខាំពស់នោះដាច់ជាពីរបីកំណាត់ ។ ពេលព្រាហ្មណ៍ត្រឡប់មកវិញ ស្កាក៏រត់ទៅននៀលក្បែរជើងគាត់ដោយសេចក្ដីត្រេកអរ ។ ព្រាហ្មណ៍ឃើញស្កាមានមុខ មាត់ ដៃ ជើងប្រឡាក់ឈាម គិតស្មានថា ស្កាខាំកូនខ្លួន ក៏យកដំបងវាយស្កាងាប់ភ្លាម ។ ក្រោយមកពេលព្រាហ្មណ៍ឃើញកូនសុខសប្បាយ គាត់នឹកស្ដាយស្កាដែលជួយការពារកូនគាត់ឱ្យរួចផុតពីគ្រោះថ្នាក់ ។

> សង្ខេបរឿង គឺនិយាយ ឬសរសេររឿងឡើងវិញ តាមលំដាប់លំដោយព្រឹត្តិការណ៍សំខាន់ៗរបស់រឿងដោយប្រើសម្ដីផ្ទាល់ខ្លួន ។

## លំហាត់

ចូរអានរឿង " ក្មេងស្រីបីនាក់ " ហើយសង្ខេបរឿងនេះ ។

ស្ដ្រីមេម៉ាយម្នាក់មានកូនស្រីបីនាក់ ។ កូនស្រីបងចូលចិត្តដើរលេងជាមួយមិត្តភក្ដិ ។ កូនស្រីបន្ទាប់មិនសូវចូលចិត្តការរៀនសូត្រទេ ។ រីឯកូនស្រីពៅ ជាក្មេងស្លូតបូតចេះគិតគូរដល់គ្រួសារ និងខិតខំរៀនសូត្រ ។

ថ្ងៃមួយ ពេលម្ដាយមិននៅ កូនទី១ និងទី២ បានឈ្លោះប្រកែកគ្នា ទោះបីប្អូនពៅឃាត់យ៉ាងណាក៏មិនស្ដាប់ ។ ពេលបានដឹងរឿង ម្ដាយក៏ហៅកូនទាំងបីនាក់មកជួបជុំគ្នា ។ ម្ដាយប្រាប់កូនម្នាក់ៗឱ្យរៀបរាប់អំពីការងារមានប្រយោជន៍ដែលគេបានធ្វើនៅថ្ងៃនេះ ។ ម្ដាយបានប្រាប់កូនថា គាត់នឹងឱ្យកូនបងទាំងពីរទៅនៅជាមួយបងប្អូននៅឯទីក្រុងធ្វើការជាមួយគេ ហើយទុកកូនពៅឱ្យនៅជាមួយ ព្រោះនាងខំរៀននិងជួយការងារផ្ទះ ។ កូនស្រីបងទាំងពីរដឹងខ្លួនខុស ក៏សន្យាថានឹងកែខ្លួន ហើយសុំឱ្យនាងបានរៀនតទៅទៀត ។ ម្ដាយក៏យល់ព្រម ។

# រឿង បងប្អូនពីរនាក់



គ្រួសារមួយមានកូនពីរនាក់ ។ កូនស្រីច្បងឈ្មោះ នាតកូនប្រុសប្អូនឈ្មោះ ណាត ។ ណាត ច្រើនតែច្រណែននឹងបងស្រីខ្លួន ។ ចំណែក នាតវិញមិនដែលប្រកាន់នឹងប្អូនទេ ។ នាងតែងតែសម្របចិត្តប្អូនជានិច្ច ។

ឪពុកម្ដាយក្មេងទាំងពីរ មានចិត្តអាណិតស្រឡាញ់កូនស្មើគ្នា ។ ពេលគាត់ទៅណា គាត់យកកូនទាំងពីរទៅជាមួយជាដរាប ។ គាត់ផ្គត់ផ្គង់ចំណីអាហារ សម្លៀកបំពាក់កូនទាំងពីរមិនឱ្យលើសខ្វះគ្នាឡើយ ។ គាត់មិនដឹងថាត្រូវធ្វើដូចម្ដេចទេ ដើម្បីឱ្យ ណាត យល់ចិត្តបងស្រី និងចេះស្រឡាញ់បងស្រីខ្លួន ។ ពួកគាត់តែងតែខ្វល់ខ្វាយនឹងរឿង ណាត ជានិច្ច ។

មានថ្ងៃមួយ ពួកគាត់បានសាកល្បងដោយប្រើមធ្យោបាយមួយ ។ គាត់ដឹងថា ក្មេងប្រុសចូលចិត្តលេងកូនឡាន ។ ពួកគាត់នាំគ្នាទៅផ្សារ ទិញកូនឡានជ័រមួយ និងសៀវភៅរូបភាពអំពីឡានតូច ធំមួយសម្រាប់ ។ គាត់បានយករបស់ទាំងនោះទៅឱ្យនាត ហើយប្រាប់ ៖ “ កូនឯងទុករបស់នេះកុំឱ្យប្អូនឃើញ ។ ដំបូងកូនយកកូនឡាននេះឱ្យទៅប្អូនដោយប្រាប់ថា មិត្តភក្តិកូនឱ្យកូន ។ ថ្ងៃក្រោយ កូនឱ្យសៀវភៅមួយសម្រាប់នេះទៀត” ។ នាតទទួលយល់ព្រមធ្វើតាមម្ដាយ ។

ដល់ពេលរសៀល នាតបានយកកូនឡានជ័រមកហុចឱ្យណាតព្រមទាំងនិយាយ ៖

- ណាត ! មកនេះ បងឱ្យកូនឡានមួយ ។

ណាតនិយាយដោយមើលមុខបង ៖

- តើបងបានកូនឡានហ្នឹងមកពីណា ? ហេតុអ្វីបានជាបងមិនទុកលេងខ្លួនឯង ?

នាតឆ្លើយ ៖

- មិត្តភក្តិបងឱ្យបង តែបងមិនលេងទេ បងឱ្យវាទៅអូនវិញ ព្រោះអូនស្រឡាញ់ឡានណាស់ ។

ណាតទទួលយកឡានពីបងភ្លាមក៏រត់ចេញមកក្រៅ យកទៅលេងមួយរំពេច ។

មួយសប្តាហ៍ក្រោយមក ពេលឃើញប្អូននៅជិត នាតធ្វើជាយកសៀវភៅរូបភាពឡានមកបើកមើល ។ ណាតចេះតែលួចតាមមើល ដោយឃើញរូបឡានប្លែកៗជាច្រើន ។ វាចង់បានណាស់ តែមិនហ៊ានសុំ ។ នាតដឹងចិត្តប្អូន ក៏បើកសៀវភៅបង្ហាញរូបភាពមួយចំនួន រួចសួរ ៖

- អូនឯងចង់បានសៀវភៅនេះ ឬទេ ? បើចង់បានបងឱ្យ ។

ណាតងក់ក្បាល ព្រមទាំងសួរបង ៖

- ម្តេចបងមិនទុកវាមើល ?

នាតមើលមុខប្អូនដោយញញឹម ហើយនិយាយដោយម៉ឺងម៉ាត់ ៖

- អត់ទេ ! បងឱ្យអូនឯងមើលវិញ ។

ថាហើយ នាងក៏ហុចសៀវភៅនោះទៅប្អូន ហើយណែនាំ ៖

- បើកវាថ្នមៗណ៎ា កុំឱ្យវាឆាប់រហែក ។ ថ្ងៃក្រោយ បើបងបានអ្វីប្លែក បងនឹងឱ្យអូនទៀត ។

ណាតញញឹម ហើយនិយាយទៅរកបង ៖

- អរគុណបង ! ខ្ញុំនឹងខំថែវាឱ្យបានល្អ ។

ចាប់ពីថ្ងៃនោះមក ណាតតែងតែទៅជិតនាត ។ ជួនកាលពួកគេនិយាយ ឬលេងជាមួយគ្នាយ៉ាងសប្បាយ ។ មាតាបិតា ក្មេងទាំងពីរសប្បាយចិត្តណាស់ ។

## សំណួរ

១. តើណាតច្រណែននឹងអ្នកណា ?

២. តើនាតស្អប់ណាត ឬទេ ?

៣. តើឪពុកម្ដាយមានអារម្មណ៍ដូចម្ដេច ពេលឃើញកូនមិនស្រឡាញ់គ្នា ?

៤. តើឪពុកម្ដាយនាតធ្វើដូចម្ដេច ដើម្បីឱ្យកូនចេះស្រឡាញ់គ្នា ?

៥. តើមធ្យោបាយនោះបានសម្រេចដែរ ឬទេ ?

៦. តើណាតធ្វើដូចម្ដេចនៅចុងបញ្ចប់ ?

៧. តើនាតជាក្មេងដូចម្ដេច ?

៨. តើអ្នកចូលចិត្តតួអង្គណាខ្លះនៅក្នុងរឿងនេះ ? ហេតុអ្វី ?

## លំហាត់

ក. ចូររកពាក្យផ្ទុយនឹងពាក្យ ៖

កូនច្បង ខ្វល់ចិត្ត ស្រឡាញ់ ប្លែកៗ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់មកជំនួសពាក្យដែលមានគំនូសពីក្រោម ។

| អាទិត្យ | ប្រាកដប្រជា | ទំនុកបម្រុង | ម្ដាយឪពុក |
|---|---|---|---|

១. ឪពុកនាត ផ្គត់ផ្គង់ ចំណីអាហារ សម្លៀកបំពាក់កូនមិនឱ្យលើសខ្វះគ្នាឡើយ ។

២. មួយ សប្ដាហ៍ ក្រោយមក ពេលឃើញប្អូននៅជិត នាតធ្វើជាយកសៀវភៅរូបភាពមកបើកមើល ។

៣. នាតមើលមុខប្អូន ហើយនិយាយដោយម៉ឺងម៉ាត់ ។

៤. មាតាបិតាក្មេងទាំងពីរ ក៏អស់កង្វល់ក្នុងចិត្តដែរ ។

# ១ រឿង ទឹកចិត្តមេមាន់



ចូរស្តាប់រឿង និងបំពេញចន្លោះឱ្យត្រូវតាមខ្លឹមសាររឿងនៅពេលស្តាប់ ។

## រឿង ទឹកចិត្តមេមាន់

កសិករម្នាក់បានចិញ្ចឹមមេមាន់មួយ និងមេទាមួយឱ្យនៅក្នុងទ្រុងជាមួយគ្នា ។ ក្រោយមកមេ... កើតបានកូនបួន ចំណែកមេទាកើតបានកូនមួយក៏... ចោលកូនទៅ ។

មេមាន់ឃើញកូន ... កំព្រាក៏យកមកចិញ្ចឹមបីបាច់ដូចកូនបង្កើតដែរ ។ រាល់ថ្ងៃមេមាន់បណ្តើរ... ទាំងអស់រកចំណីគ្រប់ទីកន្លែង ។

ថ្ងៃមួយ កូន... តូចជាងគេឆ្ងល់នឹងទង្វើរបស់... ក៏សួរ ៖ " ម៉ែ! ហេតុអ្វីបានជាម៉ែមើលថែកូនទា ?" ។ មេមាន់ឆ្លើយ ៖ " ... កំព្រាអត់មេ ហើយវានៅតូចណាស់ ។ វាត្រូវការ ការថែទាំដូចកូនដែរ ។ ម៉ែចិញ្ចឹមវា ព្រោះ... ក៏មានសិទ្ធិរស់រានមានជីវិតដូចក្មេងទូទៅដែរ ។ បើម៉ែមិនយកវាមកចិញ្ចឹម តើវា.... ដូចម្តេច ?" ។ កូនមាន់សួរមេវាទៀត ៖ " ម៉ែគិតចិញ្ចឹម ... រហូតឬ ? " ។ មេ ... ឆ្លើយ ៖ " ទេ ! ដល់វាគ្រប់អាយុម៉ែឱ្យវាទៅរៀនជាមួយកូន ហើយដល់ពេលវាអាចចិញ្ចឹមខ្លួនបាន ម៉ែឈប់ជួយវាហើយ " ។ " យី ! ម៉ែខ្ញុំចិត្តល្អណាស់ " កូន... លាន់មាត់ ។

## លំហាត់

ក. ចូរពន្យល់ពាក្យខាងក្រោមដោយប្រើវចនានុក្រម ឬបទានុក្រម ៖

ជីវភាព ប្រយោជន៍ កម្រៃ ឯកោ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ " ទុក ចិត្ត" ។

គ. ចូរសរសេរសេចក្ដីសង្ខេបរឿងខាងលើ ។

ឃ. ចូរបង្ហាញផ្នែកនៃរឿងដែលមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ និងបង្ហាញមូលហេតុនៃការជ្រើសរើសនេះ ។

## ការរៀបព្រឹត្តិការណ៍រឿងតាមលំដាប់

ក. ចូរអានល្បះខាងក្រោម រួចដាក់លេខក្នុងប្រអប់ខាងមុខល្បះ ឱ្យបានត្រឹមត្រូវតាមលំដាប់ព្រឹត្តិការណ៍នៃរឿង"មេមាន់និងកូនទា" ។

[១] មានមេមាន់មួយ ក្រាបពងទា ។

[ ] ពេលមួយ វានាំកូនដល់មាត់ត្រពាំងទឹក ។

[ ] កូនទា នាំគ្នាចុះហែលទឹកលេងកម្សាន្ត ។

[ ] ដល់ពេលកូនញាស់ មេមាន់នាំកូនចុះមកដី ។

[ ] មេមាន់បណ្ដើរកូនរកចំណីក្នុងទីធ្លា ។

[ ] វារត់ឆ្លេឆ្លា ហៅកូននៅមាត់ត្រពាំង ។

[ ] មេមាន់បារម្ភខ្លាំងណាស់ ខ្លាចកូនលង់ទឹក ។

[ ] កូនទាលេងទឹកស្កប់ស្កល់ ដល់ពេលព្រលប់នាំគ្នាឡើងមកត្រសុលក្រោមស្លាបមេ ។

[ ] ពេលណាកូនដើរបែកឆ្ងាយពីគ្នា មេមាន់ហៅកូនឱ្យមកជុំគ្នាវិញ ។

[១០] មេមាន់ខឹងណាស់ ស្ដីបន្ទោស ហើយបង្ខំកូនឱ្យចូលក្នុងសម្បុកវិញ ។

ខ. ចូរសរសេររឿងនេះ ឱ្យត្រូវតាមលំដាប់លំដោយនៃព្រឹត្តិការណ៍ ។

# រឿង អ្នកគ្រូរបស់គុណ



គុណជាសិស្សសាលាបឋមសិក្សាភូមិបឹង ។ គេជាកូនកំព្រាឪពុកម្ដាយ ហើយរស់នៅជាមួយម្ដាយមីង ។ គុណជាក្មេងឆ្លាត ស្លូតបូត ហើយឧស្សាហ៍ព្យាយាម ។ គុណខិតខំរៀនសូត្រ ហើយធ្វើកិច្ចការដោយហ្មត់ចត់ ។ អ្នកគ្រូ និងសិស្សឯទៀតស្រឡាញ់គុណគ្រប់ៗគ្នា ។ អ្នកគ្រូអាណិតគុណណាស់ ព្រោះគុណមានជីវភាពក្រីក្រជាងសិស្សឯទៀត ។

អ្នកគ្រូបានដឹងថា គុណចូលចិត្ត និងប៉ិនប្រសប់ក្នុងការគូរគំនូរ ។ គាត់មានបំណងជួយ គុណឱ្យក្លាយជាជាងគំនូរដ៏ពូកែម្នាក់ ។ ថ្ងៃមួយអ្នកគ្រូ បានហៅគុណមកសួរ ៖ “ គុណតើឯងចង់ក្លាយជាជាងគំនូរដែរ ឬទេ ?” ។ គុណលើកដៃសំពះអ្នកគ្រូ ហើយឆ្លើយដោយស្រងូតស្រងាត់ ៖ “ ជម្រាបប្រសាសន៍អ្នកគ្រូ ! ការងារនេះខ្ញុំចូលចិត្តណាស់ ប៉ុន្តែខ្ញុំមិនអាចធ្វើបានទេ ” ។ អ្នកគ្រូញញឹមហើយនិយាយបន្ត ៖ “ មិនអីទេ ! បើឯងពេញចិត្ត ខ្ញុំនឹងទៅនិយាយជាមួយឪពុកមាខ្ញុំឱ្យគាត់ជួយបង្រៀន ។ គាត់ជាជាងគំនូរដ៏ចំណានម្នាក់ ។ គាត់ចិត្តល្អណាស់ ។ គាត់ធ្លាប់ជួយក្មេងក្រីក្រដូចឯងពីរ បីនាក់រួចមកហើយ ។ ចំណែកខ្ញុំនឹងជួយផ្នែកសម្ភារៈ ។ ឯងកុំព្រួយអី គិតតែខំរៀនទៅ” ។ គុណសំពះអរគុណអ្នកគ្រូ ។

ប៉ុន្មានថ្ងៃក្រោយមក ពេលទំនេរ គុណបានឆ្លៀតពេលទៅរៀនគូរគំនូរ ។ ពូធឿន បានជួយបង្រៀន គុណដោយស្មោះសរ ។ មិនយូរប៉ុន្មាន គុណអាចគូររូបភាពខ្លះៗ ។ គុណ បានជួយគូររូបភាពផ្សេងៗទុកជាសម្ភារៈ សម្រាប់អ្នកគ្រូយកមកបង្រៀនសិស្ស រាល់ថ្ងៃ ។

ថ្ងៃមួយ ពូធឿនបានដឹងអំពីការប្រឡងគំនូរ សម្រាប់កុមារនៅក្នុងតំបន់ ។ គាត់បាន ប្រាប់គុណឱ្យគូរ ដើម្បីយកទៅចូលរួមប្រកួតប្រជែងនឹងគេ ។ ស្នាដៃរបស់គុណពេល នោះបានជាប់លេខ ២ ។ ក្រោយមកទៀត មានការប្រឡងម្តងទៀត ។ លើកទី ២ នេះ គុណទទួលបានលេខ ១ ព្រមទាំងទទួលបានរង្វាន់យ៉ាងច្រើន ។ គុណសប្បាយចិត្ត ណាស់ ។ គេរឹតតែខំប្រឹងថែមមួយកម្រិតទៀត តែគេក៏មិនភ្លេចការរៀនសូត្រដែរ ។

ពីរឆ្នាំក្រោយមក ពូធឿនបានហៅគុណឱ្យទៅជួយគូរគំនូររបស់គាត់សម្រាប់លក់ ។ គាត់បានឱ្យកម្រៃខ្លះៗដល់គុណ គ្រាន់បានបន្តការរៀនសូត្រ ។ ក្រោយមកទៀត គុណ បានចូលរៀនមហាវិទ្យាល័យវិចិត្រសិល្បៈ តាមការណែនាំរបស់អ្នកគ្រូ និងពូ ធឿន ។ គុណអាចរកប្រាក់បានបណ្តើរៗ ហើយក្រោយមក គេក៏ក្លាយជាជាងគំនូរដ៏ ល្បីម្នាក់ ។ គុណមិនដែលភ្លេចគុណពូធឿន និងអ្នកគ្រូរបស់គេឡើយ ។

## សំណួរ

១. តើគុណជាក្មេងដូចម្តេច ?

២. តើអ្នកណាខ្លះបានជួយគុណ ? ជួយអ្វីខ្លះ ?

៣. ហេតុអ្វីបានជាគាត់ជួយគុណ ?

៤. នៅទីបញ្ចប់គុណក្លាយជាអ្វី ?

៥. តើអ្នកគ្រូក្នុងរឿងនេះ ជាមនុស្សដូចម្តេច ?

## គុណនាមសំណួរ

ចូរអានឧទាហរណ៍ខាងក្រោម ។ តើពាក្យណាខ្លះជាគុណនាមសំណួរ ?

១. តើកុមារមានសិទ្ធិមូលដ្ឋានប៉ុន្មានយ៉ាង ? គឺសិទ្ធិអ្វីខ្លះ ?

២. តើអ្នកចូលចិត្តរៀនមុខវិជ្ជាអ្វីជាងគេ ?

៣. តើតួអង្គព្រាហ្មណ៍ចិញ្ចឹមសត្វអ្វី ?

៤. តើកុមារណាខ្លះមិនទាន់បានចូលរៀន ?

៥. តើឯងទើបនឹងមកពីណា ?

ពាក្យ " ប៉ុន្មាន អ្វីខ្លះ អ្វី ស្អី ណាខ្លះ ណា " មានទីតាំងនៅខាងស្តាំនាម ហើយត្រូវបានប្រើប្រាស់សម្រាប់សួរអំពីមនុស្ស សត្វ វត្ថុ ។ វាជាគុណនាមសំណួរ ។

> គុណនាមសំណួរ ជាពាក្យសម្រាប់សួរ ។

គុណនាមសំណួរមាន : ប៉ុន្មាន អ្វី អ្វីខ្លះ ស្អី អី ណា ណាខ្លះ... ។

### លំហាត់

ក. ចូរបំពេញល្បះដោយគុណនាមសំណួរសមស្រប ។

១. តើអ្នកមានឈ្មោះ ... ?

២. តើអ្នកមានបងប្អូន ... នាក់ ? ស្រី ... ?

៣. តើឪពុកអ្នកប្រកបមុខរបរ ... ?

៤. តើអ្នកធ្លាប់ទៅទស្សនាខេត្ត ... ?

៥. តើខេត្ត... សម្បូរប្រាសាទបុរាណជាងគេ ?

ខ. ចូរបង្កើតល្បះដោយប្រើគុណនាមសំណួរខាងក្រោម ៖

អ្នកណា អ្វី ប៉ុន្មាន ណា អ្វីខ្លះ ណាខ្លះ ។

# ការនិយាយអំពីសិទ្ធិរបស់កុមារ

ពេលចេញពីសាលារៀន កនបានជួបនឹងកុមារម្នាក់នៅតាមផ្លូវ ។

ចូរស្ដាប់ការសន្ទនារវាងកន និងកុមារនោះ ។

កន : កុល ! ឯងរែកអ្វីទៅណាហ្នឹង ?

កុល : អូបងកន ! ខ្ញុំរែកអុសទៅឱ្យគេនៅជិតផ្សារ ។

កន : តែឯងមិនគួររែកធ្ងន់យ៉ាងនេះទេណា៎!

កុល : បើខ្ញុំមិនធ្វើ តើបានអ្វីដោះស្រាយជីវភាព ? បងក៏ដឹងដែរថា ខ្ញុំជាក្មេងកំព្រា ។

កន : បងដឹង ! តែឯងក៏ពុំគួរប្រើកម្លាំងឱ្យហួសប្រមាណដែរ ។ ឯងត្រូវធ្វើពលកម្មតាមវ័យរបស់ខ្លួន និងគួរតែបានរៀនសូត្រដូចគេឯងដែរ ។

កុល : បើបានដូចបងនិយាយនោះ ខ្ញុំសប្បាយចិត្តណាស់ ។

កន : អូ ! បងនឹកឃើញហើយ ! បើឯងយល់ព្រម បងនឹងជម្រាបប៉ាបងឱ្យយកឯងទៅរស់នៅក្នុងមណ្ឌលកុមារកំព្រា ។ នៅទីនោះ គេនឹងចិញ្ចឹមឯងឱ្យឯងរៀនសូត្រ ហើយទទួលបានការការពារគ្រប់បែបយ៉ាង ។

កុល : ខ្ញុំសូមអរគុណបង ដែលជួយរកដំណោះស្រាយឱ្យខ្ញុំ ។

## លំហាត់

ចូរអ្នកនិយាយអំពីការរៀនសូត្រ និងការការពារអ្វីខ្លះដែលអ្នកទទួលបានអំពីមាតាបិតា ឬអាណាព្យាបាលរបស់អ្នកប្រាប់មិត្តរួមថ្នាក់ ។



## សំណេររបាយការណ៍ស្តីពីអំណានរឿងសម្រាប់អ្នកស្តាប់

ជាទូទៅ ការសរសេររបាយការណ៍ ស្តីពីការអានរឿងសម្រាប់អ្នកស្តាប់ត្រូវចែកជា ៣ផ្នែកធំ ដូចខាងក្រោម ៖

១. សេចក្តីផ្តើម

បញ្ជាក់ពេលវេលា ទីកន្លែង មូលហេតុនៃការអានរឿង ឈ្មោះរឿង និងអ្នកស្តាប់ ។

២. តួសេចក្តី

សរសេរសង្ខេបរឿងទាំងមូល ដោយប្រើពាក្យផ្ទាល់ខ្លួន ។

៣. បញ្ចប់សេចក្តី

បង្ហាញចំណាប់អារម្មណ៍ចំពោះខ្លឹមសាររឿងដែលខ្លួនបានអាន ។

បញ្ជាក់ : ដើម្បីឱ្យអ្នកស្តាប់ចាប់អារម្មណ៍ អ្នកត្រូវចេះជ្រើសរើសរឿងណាដែលមានសារៈសំខាន់ចំពោះអ្នកស្តាប់ រឿងដែលមានឧត្តមគតិ និងផ្តល់ដំបូន្មានដ៏ប្រពៃដល់អ្នកអានហើយត្រូវចេះនិយាយលើកដាក់សំឡេងតាមអារម្មណ៍របស់តួអង្គរឿងថែមទៀត ។

### លំហាត់គំរូ

អ្នកបានអានរឿង " អ្នកគ្រូរបស់គុណ " ឱ្យមិត្តរួមថ្នាក់ស្តាប់ ។ ចូរប្អូនសរសេររបាយការណ៍មួយស្តីពីអំណានរឿងនោះដោយ ៖

- ផ្តល់សេចក្តីសង្ខេបរឿង និងពន្យល់មូលហេតុនៃការជ្រើសរើស
- ដៅសម្គាល់ផ្នែកណា ដែលមានលក្ខណៈគួរឱ្យចាប់អារម្មណ៍នៅពេលអាន
- ពណ៌នាអំពីប្រតិកម្មរបស់អ្នកស្តាប់
- វាយតម្លៃអំណានរបស់អ្នកលើចំណុចល្អ និងចំណុចដែលត្រូវកែលម្អ ។

ខាងក្រោមនេះ ជាគម្រោងលម្អិតស្តីពីអំណានរឿង " អ្នកគ្រូរបស់គុណ " ។

# គម្រោងតែង

## ១. សេចក្ដីផ្ដើម

ពេលវេលា (ល្ងាចថ្ងៃសៅរ៍មួយ) ទីកន្លែង (នៅលើគ្រែក្រោមដើមស្វាយធំមួយដើម) មូលហេតុនៃការអានរឿង (ដើម្បីបង្កើតបរិយាកាសរីករាយ) អ្នកស្ដាប់ (ប្អូនៗ) ។

## ២. តួសេចក្ដី

- ការសង្ខេបរឿង (គុណជាសិស្សសាលាបឋមសិក្សាភូមិបឹង) ។ គេជាកូនកំព្រា... គុណមិនដែលភ្លេចគុណពូធឿន និងអ្នកគ្រូរបស់គេឡើយ ។
- មូលហេតុនៃការជ្រើសរើស (ជារឿងទាក់ទងនឹងកុមារ ហើយកុមារគួរតែដឹងអំពីសិទ្ធិរបស់ពួកគេ) ។
- ផ្នែកដែលគួរចាប់អារម្មណ៍ (គុណបានអ្នកគ្រូរបស់គេជួយជ្រោមជ្រែងរហូតបានក្លាយជាជាងគំនូរដ៏ល្បីម្នាក់) ។
- ការពណ៌នាអំពីប្រតិកម្មរបស់អ្នកស្ដាប់ (ប្អូនៗពេញចិត្តនឹងអ្នកគ្រូដែលមានចិត្តល្អ អាណិតកុមារកំព្រាក្រីក្រ) ។
- ការវាយតម្លៃអំណាន (ចំណុចល្អ : អានគ្មានរដាក់រដុបតាំងពីការផ្ដើមរឿងរហូតដល់បញ្ចប់រឿង ។ ចំណុចត្រូវកែលម្អ : មិនទាន់ចេះប្រើការលើកដាក់សំឡេងឱ្យត្រូវតាមមនោសញ្ចេតនារបស់តួអង្គ) ។

## ៣. បញ្ចប់សេចក្ដី

រឿង “ អ្នកគ្រូរបស់គុណ” ជារឿងមួយដែលបង្ហាញអំពីទឹកចិត្តគ្រូចំពោះសិស្ស ជាពិសេសសិស្សក្រីក្រ ឬកុមារកំព្រា ។ ទន្ទឹមនឹងការខិតខំប្រឹងប្រែងបង្រៀនសិស្សឱ្យចេះដឹងក្លាយជាមនុស្សល្អ គ្រូបានជួយជ្រោមជ្រែង និងលះបង់ថវិកាខ្លះ ដើម្បីឱ្យសិស្សដែលជួបការលំបាក ដើម្បីគេមានអនាគតរុងរឿងទៀតផង ។

## លំហាត់

ក. ចូរអ្នកមើលរូបភាព រួចសរសេររឿងតាមលំដាប់លំដោយ ។
ចូរនិទានរឿងនេះឱ្យមិត្តរួមថ្នាក់ស្តាប់ ។




ខ. អ្នកបានអានរឿង "ព្រាហ្មណ៍និងស្ការ" ឱ្យសិស្សតូចៗស្តាប់ ។ ចូរអ្នកសរសេររបាយការណ៍ ស្តីពីការអានរឿងនេះឱ្យសិស្សតូចៗស្តាប់ដោយ ៖

- ផ្តល់សេចក្តីសង្ខេបរឿង និងពន្យល់មូលហេតុនៃការជ្រើសរើសរឿងនេះ
- ប្រាប់ផ្នែកណាដែលលំបាក ឬមានលក្ខណៈគួរឱ្យចាប់អារម្មណ៍នៅពេលអាន
- ពណ៌នាអំពីប្រតិកម្មរបស់អ្នកស្តាប់
- វាយតម្លៃការអានរបស់អ្នកលើចំណុចល្អ និងចំណុចដែលត្រូវកែលម្អ ។

បញ្ជាក់ ៖ អ្នកអាចជ្រើសរើសរឿងផ្សេងទៀត ដែលផ្តល់ការអប់រំល្អ ។

មេរៀនទី

# ៣ ធនធានរ៉ែនៅប្រទេសកម្ពុជា



ប្រទេសកម្ពុជាមានសម្បត្តិធម្មជាតិនៅក្នុងទឹក លើដី និងក្នុងដី ។ រ៉ែជាសម្បត្តិធម្មជាតិមួយប្រភេទដែលរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ ឱ្យរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័ស ។ រ៉ែទាំងនោះ មានដូចជា រ៉ែដែក រ៉ែមាស រ៉ែត្បូង រ៉ែប្រេងកាត... ។

# ការកត់ត្រាចំណុចសំខាន់ៗនៃព័ត៌មាន

ពេលអ្នកស្តាប់ ឬអានអត្ថបទព័ត៌មាន អ្នកគួរកត់ត្រាចំណុចសំខាន់ៗទុក ព្រោះវាជួយអ្នកឱ្យចងចាំព្រឹត្តិការណ៍ ឬហេតុការណ៍សំខាន់ៗដែលអ្នកបានស្តាប់ ឬអាន និងងាយស្រួលក្នុងការសង្ខេបអត្ថបទនោះ ។ ការកត់ត្រានេះ មិនទាមទារឱ្យអ្នកសរសេរជាល្បះពេញលេញទេ ។ អ្នកគ្រាន់តែសរសេរពាក្យ ឬកន្សោមពាក្យសំខាន់ៗរបស់ព័ត៌មានប៉ុណ្ណោះ ។

ចូរអ្នកអានអត្ថបទខាងក្រោម ។ ពាក្យ ឬកន្សោមពាក្យដែលមានគំនូសពីក្រោម ជាពាក្យសំខាន់ដែលត្រូវកត់ត្រាទុក ។

## ថ្មកំបោរ

ភ្នំថ្មកំបោរនៅខេត្តកំពត ជាភ្នំដែលមានថ្មខុសប្លែកពីថ្មភ្នំដទៃទៀតនៅកម្ពុជា ។ កាលដើមឡើយ ប្រជាជនខ្មែរយើងពុំទាន់យល់ច្បាស់អំពីអត្ថប្រយោជន៍នៃថ្មកំបោរនៅឡើយទេ ។ គេនាំគ្នាទៅយកថ្មកំបោរពីភ្នំមកបញ្ចូលក្នុងឡដុតធ្វើកំបោរ សម្រាប់លក់ចែកចាយដល់អ្នកហូបម្លូ និងធ្វើជាកំបោរម៉ដ្ឋសម្រាប់លាបផ្ទះ លាបចិញ្ចើមថ្នល់ គល់ឈើលម្អក្នុងពិធីបុណ្យជាតិផ្សេងៗ ។ ជួនកាល គេយកថ្មកំបោរទៅរោយក្នុងរោង ឬទ្រុងចិញ្ចឹមសត្វ កន្លែងកខ្វក់ដើម្បីសម្លាប់មេរោគ ។

នៅឆ្នាំ ១៩៦៤-១៩៦៥ ក្រោមជំនួយឧបត្ថម្ភពីប្រទេសចិន ប្រទេសកម្ពុជាបានសាងសង់រោងចក្រស៊ីម៉ងត៍ នៅចក្រីទីងក្នុងខេត្តកំពត ។

ក្រោយពីរោងចក្រនេះដំណើរការ តម្លៃស៊ីម៉ងត៍នៅក្នុងប្រទេសថោកជាងស៊ីម៉ងត៍នាំចូលពីបរទេស រីឯគុណភាពក៏មិនចាញ់ស៊ីម៉ងត៍នាំចូលពី ប្រទេសក្រៅ ឡើយ ។ សំណង់គ្រប់យ៉ាង ប្រើប្រាស់តែស៊ីម៉ងត៍នៅចក្រីទីងប៉ុណ្ណោះ ។

ចំណុចសំខាន់ៗនៃអត្ថបទខាងលើមាន ៖

| | | |
|---|---|---|
| កន្លែងមានថ្មកំបោរ | ៖ | ភ្នំថ្មកំបោរ ខេត្តកំពត |
| ផលបានពីថ្មកំបោរ | ៖ | កំបោរសម្រាប់អ្នកហូបម្លូស្លា កំបោរម៉ដ្ឋ ស៊ីម៉ងត៍ |
| ការប្រើប្រាស់ | ៖ | ធ្វើសំណង់ ហូបជាមួយម្លូ លាបផ្ទះ ចិញ្ចើមថ្នល់ ដើមឈើ រោយក្នុងទ្រុងសត្វ កន្លែងកខ្វក់ ដើម្បីសម្លាប់មេរោគ |

ការផលិត ៖ ឆ្នាំ១៩៦៤-១៩៦៥ ក្រោមជំនួយឧបត្ថម្ភរបស់ប្រទេសចិន ប្រទេសកម្ពុជាបានសង់រោងចក្រស៊ីម៉ងត៍នៅចក្រីទីង

គុណភាពស៊ីម៉ងត៍ ៖ មិនចាញ់ស៊ីម៉ងត៍បរទេស តម្លៃថោក ។

ដើម្បីកត់ត្រាចំណុចសំខាន់ៗ អ្នកត្រូវយកចិត្តទុកដាក់លើព័ត៌មាន មួយចំនួនខាងក្រោម ៖

- សេចក្តីលម្អិតសំខាន់ៗ ដូចជាហេតុការណ៍ ឬព្រឹត្តិការណ៍គួរចាប់អារម្មណ៍ ឬឧទាហរណ៍ដែលគេលើកមកបញ្ជាក់ ជួនកាលមានមតិ ឬយោបល់ផ្សេងៗ ។
- កាលបរិច្ឆេទសំខាន់ៗ (ប្រសិនបើមាន) ។
- មនុស្សសំខាន់ៗ (ប្រសិនបើមាន) ។

ការកត់ត្រាចំណុចសំខាន់ៗ គឺការកត់ត្រាពាក្យ ឬកន្សោមពាក្យខ្លីៗ ដែលប្រាប់គំនិតសំខាន់ៗរបស់ព័ត៌មានក្នុងអត្ថបទ ។

## លំហាត់

ចូរអានអត្ថបទព័ត៌មានខាងក្រោម រួចកត់ត្រាចំណុចសំខាន់ៗ ។

នៅប្រទេសកម្ពុជាមានរ៉ែច្រើនប្រភេទ ។ រ៉ែទាំងអស់ ស្ថិតនៅក្នុងជម្រៅមិនស្មើគ្នាទេ ។ រ៉ែខ្លះអាចនៅស្រទាប់ខាងលើ រ៉ែខ្លះទៀតស្ថិតនៅយ៉ាងជ្រៅ ក្រោមបាតសមុទ្រ ដូចជារ៉ែប្រេងកាតជាដើម ។ ពេលគេយករ៉ែប្រេងកាតបានមក គេមិនអាចប្រើប្រាស់ភ្លាមបានទេ ។ គេត្រូវចម្រាញ់ប្រេងនៅឱ្យបានជាប្រេងឥន្ធនៈផ្សេងៗ សម្រាប់ឱ្យម៉ាស៊ីននានាមានដំណើរការ ។ គេយករ៉ែដែកទៅស្ល ដើម្បីឱ្យបានជាដែកសុទ្ធ ។ គេយករ៉ែមាសនិងត្បូងតាមរយៈការជីកដីយកទៅវែងក្នុងទឹក ។ គេយកកម្ទេចមាសទៅធ្វើអគ្គិសនីវិភាគយកមាសសុទ្ធ ។ ចំណែកត្បូង គេយកទៅច្នៃធ្វើគ្រឿងអលង្ការទុកលក់ដូរ និងប្រើប្រាស់តាមសេចក្តីត្រូវការ ។

# ធនធានធម្មជាតិនៅក្នុងដី

| ឈ្មោះរ៉ែ | ទីកន្លែងមានរ៉ែ | |
|---|---|---|
| | ឈ្មោះភូមិ ស្រុក | ឈ្មោះខេត្ត |
| ១. រ៉ែដែក | ស្រុករវៀង | ព្រះវិហារ |
| | ភ្នំដី ស្រុកសណ្ដាន់ | កំពង់ធំ |
| ២. រ៉ែមាស | ស្រុករវៀង ស្រុកអណ្ដូងមាស | ព្រះវិហារ-រតនគិរី |
| | ស្រុកតាវែង ស្រុកថ្មបាំង | កោះកុង |
| ៣. រ៉ែត្បូង | កាទី មេម៉ង់ ស្រុកកែវសីមា | មណ្ឌលគិរី |
| | ភ្នំយ៉ាត បយ៉ាខា បតាំងស៊ូ | ខេត្តប៉ៃលិន |
| | ស្រុកបកែវ ស្រុកកូនមុំ ស្រុកលំផាត់ | រតនគិរី |
| ៤. រ៉ែប្រេងកាត | សមុទ្រខ្មែរ បឹងទន្លេសាប | កោះកុង ខេត្តព្រះសីហនុ បឹងទន្លេសាប |

ប្រទេសកម្ពុជាមានក្រឡាផ្ទៃ តូចជាងប្រទេសជិតខាង ប៉ុន្តែសម្បូរទៅដោយភោគទ្រព្យរ៉ែផ្សេងៗ ។ ភោគទ្រព្យទាំងនេះ ធ្វើឱ្យប្រជាជនមានមោទនភាព និងមានទឹកចិត្តស្រឡាញ់ប្រទេសជាតិខ្លួន ជាពិសេសប្រជាជនដែលរស់នៅតំបន់មានរ៉ែ ។

រ៉ែដែកសម្បូរនៅស្រុករវៀង ខេត្តព្រះវិហារ និងភ្នំដីស្រុកសណ្ដាន់ ខេត្តកំពង់ធំ ។ សព្វថ្ងៃ ក្រុមហ៊ុនចិន បានសង់រោងចក្រស្លដែកមួយនៅចំណុចប្រសព្វនៃខេត្តស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ ។ រ៉ែមាស ភាគច្រើនមាននៅស្រុករវៀង ខេត្តព្រះវិហារ ស្រុកអណ្ដូងមាស ស្រុកតាវែង ខេត្តរតនគិរី និងស្រុកថ្មបាំងខេត្តកោះកុង ។ អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីបានផ្ដល់ព័ត៌មានថា ក្នុងភូមិសាស្ត្រកាទីនិងមេម៉ង់ស្រុកកែវសីមា ខេត្តមណ្ឌលគិរីមានមាសប្រហែលជាងប្រាំបីលានតោន ។

នៅភ្នំយ៉ាត បយ៉ាខា បតាំងស៊ូ ក្នុងខេត្តប៉ៃលិនពីមុនមានរ៉ែត្បូងល្អប្រណីត និងមានតម្លៃជាងគេដូចជាត្បូងទទឹម និងត្បូងកណ្ដៀង ។ នៅស្រុកបកែវ កូនមុំ និងលំផាត់ខេត្តរតនគិរី ក៏សម្បូរត្បូងធម្មជាតិដែរ ។ ពេលថ្មីៗនេះ នៅស្រុកគិរីវង់ ខេត្តតាកែវគេបានរកឃើញរ៉ែត្បូងមួយចំនួន តែគុណភាពអន់ជាងត្បូងនៅរតនគិរី និងប៉ៃលិន ។ ក្រៅពីធ្វើគ្រឿងអលង្ការសម្រាប់ពាក់លម្អ គេបាននាំយកត្បូងទាំងនេះ ទៅលក់ឯបរទេសទៀតផង ។

នៅបាតសមុទ្រខ្មែរ និងនៅបឹងទន្លេសាប គេបានរកឃើញរ៉ែពិសេសមួយទៀត គឺរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិ ។ បច្ចុប្បន្ន ក្រុមហ៊ុនបរទេសមួយចំនួនកំពុងធ្វើវិនិយោគទុន ដើម្បីបូមប្រេងកាត និងឧស្ម័នពីបាតសមុទ្រខ្មែរ ។

យើងជាខ្មែរត្រូវមានការប្រុងប្រយ័ត្នជានិច្ច ក្នុងការទាញយកភោគទ្រព្យធម្មជាតិដ៏មានតម្លៃទាំងនេះ ដោយមិនជីកយករ៉ែដែលនៅខ្ចី ឬខុសបច្ចេកទេសដែលធ្វើឱ្យហិនហោច ខាតបង់ដល់ប្រទេសជាតិនៅថ្ងៃអនាគតនោះទេ ។

## សំណួរ

១. តើរ៉ែច្រើនមាននៅក្នុងខេត្តណាខ្លះ ?

២. តើខេត្តណាខ្លះមានរ៉ែដែក ? ខេត្តណាខ្លះមានរ៉ែមាស ? ខេត្តណាខ្លះមានរ៉ែត្បូង ? តើរ៉ែប្រេងកាតមាននៅតំបន់ណាខ្លះ ?

៣. តើរ៉ែទាំងនោះ មានប្រយោជន៍អ្វីខ្លះ ?

៤. ហេតុអ្វីបានជាយើងត្រូវប្រុងប្រយ័ត្ន ក្នុងការទាញយកធនធានរ៉ែទាំងនោះ ?

៥. តើគេសរសេរព័ត៌មានខាងលើ ក្នុងគោលបំណងអ្វី ?

៦. តើគេសរសេរព័ត៌មានទាំងនេះ សម្រាប់អ្នកណាខ្លះ ?

## លំហាត់

ក. ចូរហាត់អាន និងពន្យល់ន័យពាក្យពហុព្យាង្គខាងក្រោម ៖

ព័ត៌មាន ភូមិសាស្ត្រ បច្ចុប្បន្ន វិនិយោគ អលង្ការ រដ្ឋាភិបាល ។

ខ. ចូររកពាក្យដែលមានន័យដូចគ្នាមកជំនួសពាក្យដែលមានគំនូសពីក្រោម ។

១. ប្រជាជនមានទឹកចិត្ត ស្រឡាញ់ ប្រទេសជាតិខ្លួន ។

២. ចិនបានសង់រោងចក្រស្លដែកនៅ ចំណុចប្រសព្វ នៃខេត្តស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ ។

៣. អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីបានផ្ដល់ ព័ត៌មាន ថា... ។

៤. បច្ចុប្បន្ន ក្រុមហ៊ុនចិនបានធ្វើវិនិយោគទុនរ៉ែមាសនៅទីនោះ ។

៥. គេបាននាំយកត្បូងទាំងនេះទៅលក់ឯ បរទេស ។

គ. ចូរកត់ត្រាចំណុចសំខាន់ៗនៃព័ត៌មាន នៅក្នុងអត្ថបទខាងលើ ។

## ត្បូងពណ៌ស្វាយមួយគ្រាប់



ចូរបំពេញចន្លោះក្នុងអត្ថបទខាងក្រោម ឱ្យត្រូវតាមព័ត៌មានដែលអ្នកកំពុងស្ដាប់ ។

ខេត្តរតនគិរី សម្បូរទៅដោយ ... ធម្មជាតិដ៏មានតម្លៃគួរកត់សម្គាល់ ដូចជានៅស្រុក... ស្រុកលំផាត់ និងស្រុក ... ។

កាលពីខែតុលាឆ្នាំ... នៅអូរខ្វេះ ភូមិ ... ឃុំត្រពាំងក្រហម ស្រុកកូនមុំគេជីកបានត្បូងធម្មជាតិពណ៌ ... មួយគ្រាប់ ទម្ងន់ ... គីឡូក្រាម ។ គេបានលក់ ... នេះ ទៅឱ្យកុងសៃទិញត្បូងម្នាក់នៅក្នុងខេត្តរតនគីរី តែពុំដឹងលក់ក្នុងតម្លៃប៉ុន្មានទេ ។

ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តរតនគីរីបានឱ្យដឹងថា ត្បូងពណ៌ស្វាយមួយគ្រាប់នេះ មិនមែនប្រភេទ ... នោះទេ គឺជាកែវណាមហ្វានពណ៌ ... ។ កែវណាមហ្វាននេះជា ... ប្រភេទថ្មី ។ ថ្មកែវណាមហ្វាន មានពណ៌ស្វាយល្អណាស់ ពេលគេជីកបានពីក្នុង ... តែក្រោយមក វាប្រែពណ៌ ... មិនសូវល្អ ដូចពេលគេជីកបានភ្លាមទេ ។

## សំណួរ

១. តើខេត្តរតនគីរីសម្បូរអ្វី ?

២. តើគេជីកត្បូងពណ៌ស្វាយនៅឯណា ?

៣. តើកែវណាមហ្វានជាអ្វី ?

៤. តើថ្មកែវណាមហ្វានមានពណ៌ដូចម្តេចនៅពេលគេទើបនឹងជីកបាន ?

## លំហាត់

**ក. ចូរកត់ត្រាចំណុចសំខាន់ៗនៃអត្ថបទខាងលើ ។**

**ខ. ចូរបង្ហាញប្រធានបទនៃអត្ថបទខាងលើ ដោយជ្រើសរើសចម្លើយមួយត្រឹមត្រូវ ៖**

១. ការលក់ត្បូងនៅខេត្តរតនគីរី

២. ត្បូងពណ៌ស្វាយមួយគ្រាប់នៅខេត្តរតនគីរី

៣. របរជីកត្បូងនៅខេត្តរតនគីរី



## គុណនាមចង្អុល

គុណនាមកំណត់មានច្រើនប្រភេទ ដូចជាគុណនាមចង្អុល គុណនាមសំណួរ គុណនាមកម្មសិទ្ធិ គុណនាមចំនួន និងគុណនាមមិនច្បាស់ ។ មេរៀននេះ អ្នករៀនអំពីគុណនាមចង្អុល ។

**ចូរពិនិត្យឧទាហរណ៍ខាងក្រោម តើពាក្យណាខ្លះជាគុណនាមចង្អុល ។**

១. ភ្នំនោះមានឈ្មោះថា ភ្នំថ្មកំបោរ ។

២. គេរកឃើញរ៉ែមាសទាំងនេះនៅខេត្តមណ្ឌលគិរី ។

៣. នៅបរកែវមានត្បូងល្អៗជាច្រើន ។ ឈ្មួញបរទេសនិយមទិញត្បូងទាំងនោះណាស់ ។

៤. មនុស្សនេះជាអ្នកស្រាវជ្រាវរករ៉ែនៅកម្ពុជា ។

ពាក្យ“នោះ ទាំងនេះ ទាំងនោះ នេះ” ជាគុណនាមចង្អុល ។

គុណនាមចង្អុល ជាពាក្យសម្រាប់បង្ហាញមនុស្ស សត្វ វត្ថុ រុក្ខជាតិ នៅនឹងមុខ ឬនៅឆ្ងាយ ឬបង្ហាញអ្វីដែលគេទើបនឹងប្រាប់ ឬដែលគេបម្រុងនឹងប្រាប់ ។

គុណនាមចង្អុលមាន ៖ នេះ នោះ ទាំងនេះ ទាំងនោះ នុះ ។

- នេះ បង្ហាញ មនុស្ស សត្វ វត្ថុ ដែលនៅជិតខ្លួន ឬបង្ហាញអ្វីដែលគេបម្រុងនឹងនិយាយប្រាប់ ។
- នោះ បង្ហាញអ្វីដែលនៅឆ្ងាយ ឬអ្វីដែលគេទើបនឹងប្រាប់ ។
- នុ៎ះ បង្ហាញអ្វីដែលនៅឆ្ងាយតែមើលឃើញ ។

បញ្ជាក់ : គុណនាមចង្អុល នេះ នោះ ទាំងនេះ ទាំងនោះ នុ៎ះ តែងតែនៅជាប់ខាងស្តាំនាម ។

## លំហាត់

ក. ចូរស្រង់គុណនាមចង្អុលនៅក្នុងល្បះខាងក្រោម ៖

១. គេទើបនឹងរកឃើញរ៉ែត្បូងទាំងនេះនៅស្រុកគីរីវង់ ខេត្តតាកែវ ។

២. បុរសពាក់អាវសនេះ ជាកុងសៃទិញត្បូងនៅខេត្តរតនគីរី ។

៣. គេចិញ្ចឹមគោទាំងនោះ ទុកលក់យកសាច់ ។

៤. ដើមឈើនោះ ច្រើនដុះនៅជិតភ្នំ ។

៥. ភ្នំនោះជាភ្នំថ្មកំបោរ ។

ខ. ចូរបង្កើតល្បះដោយប្រើគុណនាមចង្អុល“ នេះ នោះ ទាំងនេះ ទាំងនោះ” ឱ្យបានមួយល្បះក្នុងមួយពាក្យ ។

គ. ចូរប្រាប់លេខល្បះដែលមានគុណនាមចង្អុល ព្រមទាំងស្រង់ពាក្យទាំងនោះផង ។

១. នោះជាភ្នំដែក នៅខេត្តកំពង់ធំ ។

២. គេទើបនឹងរកឃើញវត្ថុនេះ នៅក្នុងខេត្តយើង ។

៣. នេះជាមធ្យោបាយល្អបំផុត ។

៤. យើងត្រូវថែរក្សារ៉ែទាំងនោះ ឱ្យនៅគង់វង្ស ។

# រ៉ែប្រេងកាត




ប្រេងកាតជារ៉ែមួយប្រភេទដែលមានតម្លៃជាងគេនៅលើពិភពលោក ។ នៅប្រទេសកម្ពុជា គេរកឃើញរ៉ែប្រេងកាតនៅក្នុងដី ក្រោមបាតសមុទ្រ និងក្រោមដីបាតបឹងទន្លេសាប ។ បច្ចុប្បន្ននេះ ក្រុមហ៊ុនវិនិយោគទុនជាច្រើនកំពុងចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីបូមប្រេងកាតនៅក្នុងសមុទ្រខ្មែរ ។

តាមអ្នកស្រាវជ្រាវបានឱ្យដឹងថា ប្រេងកាតនៅប្រទេសកម្ពុជាមានរាប់ពាន់បារ៉ែល ។ គេធ្វើសំណង់បូមប្រេងក្នុងទឹកសមុទ្រ ឬទឹកសាប ។ គេបុកទម្លុះដីមិនជ្រាបទឹកដោយឆ្លងកាត់ស្រទាប់ដែលមានឧស្ម័ន ។ នៅស្រទាប់ខាងក្រោមប្រេង មានទឹកប្រៃ ។ នៅក្រោមទឹកប្រៃ មានស្រទាប់ដីដែលជាទម្រទឹកប្រៃ ។ នៅក្នុងស្រទាប់ឧស្ម័ន ក្នុងស្រទាប់ប្រេងកាត និងក្នុងស្រទាប់ទឹកប្រៃ គេសង្កេតឃើញមានសិលាស្លោត ។ នៅពេលបុកបំពង់ដល់ឧស្ម័ន គេដឹងថាជិតដល់ស្រទាប់ប្រេងហើយ ដូច្នេះគេមានការប្រុងប្រយ័ត្ន

មិនឱ្យការបុកនេះ ជ្រុលហួសនាំឱ្យប្រេងកាតបាញ់ឡើងខ្លាំងហួសបំពង់បង្ហូរ ។ ប្រេងដែលគេបូមពីក្នុងដី ត្រូវហូរចូលបំពង់បង្ហូរទៅកាន់រោងចក្រចម្រាញ់ប្រេងកាត ។ គេបានប្រេងច្រើនប្រភេទពីការចម្រាញ់ប្រេងឆៅដូចជា ប្រេងកាតសម្រាប់យន្តហោះ ប្រេងសាំង ប្រេងកាត ប្រេងម៉ាស៊ូត ប្រេងរំអិល និងកាកសំណល់សម្រាប់ចាក់ក្រាលផ្លូវថ្នល់ ។

ប្រេងកាតឆៅ ឬ "មាសខ្មៅ" មានប្រយោជន៍ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រទេស ។ ដូច្នេះ កូនខ្មែរគ្រប់រូបត្រូវចូលរួមថែរក្សាសម្បត្តិធម្មជាតិ ទាំងក្នុងដី ទាំងក្នុងទឹក ឱ្យបានគង់វង្សជារៀងរហូត ។

## សំណួរ

១. តើប្រេងកាតមាននៅទីណាខ្លះ ?

២. តើគេត្រូវធ្វើដូចម្តេច ដើម្បីយកប្រេងកាតឆៅបាន ?

៣. តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលដែលប្រទេសអ្នកមានអណ្តូងប្រេងកាតបែបនេះ ?

៤. តើគេទទួលបានអ្វីខ្លះពីការចម្រាញ់ប្រេងឆៅ ?

## លំហាត់

ក. ចូររកពាក្យផ្ទុយនឹងពាក្យ ៖

ទឹកសាប ក្រោមទឹក មានប្រយោជន៍ រីកចម្រើន ឆាប់រហ័ស ។

ខ. ចូរបង្ហាញគោលបំណងរបស់អត្ថបទខាងលើ ។

គ. ចូរកត់ត្រាចំណុចសំខាន់ៗរបស់អត្ថបទខាងលើ ។

# ការរៀបរាប់អំពីរ៉ែផ្សេងៗ

លោកគ្រូរបស់វិច្ឆិកាបានទទួលព័ត៌មានតាមវិទ្យុជាតិអំពីការវិនិយោគលើរ៉ែដែកនៅកម្ពុជា ។ គាត់បានយកព័ត៌មានទៅផ្សព្វផ្សាយបន្ត ដល់សិស្សរបស់គាត់ ។

ចូរស្តាប់ការសន្ទនារបស់លោកគ្រូនិងសិស្សរបស់គាត់ ។

លោកគ្រូ : កាលពីព្រឹកមិញ លោកគ្រូបានទទួលព័ត៌មានថា មានក្រុមហ៊ុនមួយកំពុងដាក់វិនិយោគទុននៅតំបន់មានរ៉ែដែក ។ តើកូនៗបានដឹងឬទេ?

វិច្ឆិកា : ខ្ញុំមិនបានដឹងទេលោកគ្រូ ។ តើប្រទេសយើងមានរ៉ែដែកនៅឯណាខ្លះ ?

លោកគ្រូ : រ៉ែដែកក្នុងប្រទេសយើងមាននៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តកំពង់ធំ ។

កុម្ភៈ : លោកគ្រូ! តើគេធ្វើដូចម្តេច ដើម្បីយករ៉ែដែកមកប្រើប្រាស់បាន ?

លោកគ្រូ : ក្រុមហ៊ុនបានសាងសង់រោងចក្រស្លដែកមួយ នៅត្រង់ចំណុចប្រសព្វខេត្តទាំងបីខាងលើ ។ គេយករ៉ែដែកជីកបាន ទៅបញ្ចូលរោងចក្រទើបអាចបានដែកប្រើប្រាស់ ។

វិច្ឆិកា : លោកគ្រូ! តើដែកដែលគេស្លរួច ជាដែកប្រភេទណា ?

លោកគ្រូ : ដែកចេញពីរោងចក្រមានពីរប្រភេទ គឺដែករឹងល្អគេហៅថា ដែកថែប និងដែកធម្មតាដែលកូនឃើញគេលក់រាល់ថ្ងៃ ។

កុម្ភៈ : គិតទៅរ៉ែដែក ក៏មានប្រយោជន៍មិនចាញ់រ៉ែផ្សេងៗដែរមែនទេលោកគ្រូ?

លោកគ្រូ : មែនហើយ! រ៉ែទាំងអស់សុទ្ធតែជាធនធានដ៏មានតម្លៃបំផុត សម្រាប់ប្រទេសនីមួយ ៗ ។

## លំហាត់

ចូរអ្នកចាប់គូ ហើយនិយាយប្រាប់គ្នាអំពីរ៉ែណាមួយដែលអ្នកបានដឹងដោយប្រាប់ឈ្មោះរ៉ែ ទីកន្លែងមានរ៉ែនោះ និងផលប្រយោជន៍របស់វា ។

# រ៉ែមាសនៅកម្ពុជា



ខេត្តនីមួយៗនៅប្រទេសកម្ពុជា មានធនធានធម្មជាតិដោយឡែកៗពីគ្នា ។ ថ្មីៗនេះ នៅខេត្តមណ្ឌលគិរី គេប្រទះឃើញធនធានក្នុងដីដ៏មានតម្លៃមួយទៀត គឺរ៉ែមាស ។

អ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីបានផ្តល់ព័ត៌មានថា គេបានរកឃើញរ៉ែមាស ប្រហែលជាងប្រាំបីលានតោននៅកាទី និងមេម៉ង់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ។ ផ្នែកខ្លះនៃរ៉ែមាសក្នុងស្រុកនេះ បានត្រូវក្រុមហ៊ុនចិនធ្វើវិនិយោគរួចទៅហើយ ។ រ៉ែមាសនៅមណ្ឌលគិរី ជារ៉ែមាសដែលមានគុណភាពល្អ អាចយកទៅធ្វើជាគ្រឿងអលង្ការផ្សេងៗ សម្រាប់ប្រើប្រាស់ ឬសម្រាប់លក់ដូរបាន ។

រ៉ែមាសមិនមែនមានតែនៅខេត្តមណ្ឌលគិរីទេ នៅស្រុករវៀង ខេត្តព្រះវិហារក៏មានរ៉ែមាសដែរ ។ ប្រជាជននៅទីនោះ យកការរែងរ៉ែមាសជារបរចិញ្ចឹមជីវិតតាំងពីយូរណាស់មកហើយ ។ ពួកគេរែងមាស ដោយកម្លាំងពលកម្មសុទ្ធសាធ ។ គេអាចរកមាសសុទ្ធបានពីប្រាំជីទៅមួយតម្លឹងក្នុងមួយសប្តាហ៍ ឬយ៉ាងហោចណាស់ក៏បាន ២ ឬ ៣ ជីមាសធម្មតាដែរ ។

គេអាចយករ៉ែមាសបានដោយការជីកលុងដី រហូតដល់គេប្រទះឃើញស្រទាប់ដីពណ៌លឿងជាខ្សែៗ ។ គេយកដីនោះទៅវែង រួចគេយកទៅធ្វើអគ្គិសនីវិភាគយកមាសសុទ្ធ ។ គេត្រូវប្រែក្លាយវាឱ្យទៅជាមាសទឹកដប់សុទ្ធ ។

មាសជារូបិយប័ណ្ណសំខាន់ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ ។ ក្នុងនាមជាកុលបុត្រកុលធីតាខ្មែរ ត្រូវជួយថែរក្សាសម្បត្តិធម្មជាតិទាំងនេះឱ្យគង់វង្សបានយូរអង្វែង ដើម្បីឱ្យប្រទេសជាតិបានរីកចម្រើន ដូចប្រទេសនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសជឿនលឿនលើពិភពលោក ។

## សំណួរ

១. តើរ៉ែមាសមាននៅខេត្តណាច្រើនជាងគេ ?
២. តើគេធ្វើដូចម្ដេច ដើម្បីយកមាសបាន ?
៣. តើគេធ្វើដូចម្ដេច ដើម្បីឱ្យរ៉ែមាសទៅជាមាសសុទ្ធ ?
៤. តើរ៉ែមាសផ្ដល់ប្រយោជន៍អ្វីខ្លះ ដល់ប្រជាជននិងប្រទេសជាតិ ?
៥. តើការជីកយកមាសដោយកម្លាំងពលកម្មសុទ្ធសាធ អាចធ្វើឱ្យសម្បត្តិធម្មជាតិហិនហោចឆាប់រហ័សដែរ ឬទេ ?

## លំហាត់

ក. ចូរអាននិងពន្យល់ន័យពាក្យពហុព្យាង្គខាងក្រោម ៖

អគ្គិសនី រូបិយប័ណ្ណ សេដ្ឋកិច្ច កុលបុត្រ កុលធីតា អាស៊ីអាគ្នេយ៍ ។

ខ. ចូររកពាក្យដែលមានន័យផ្ទុយនឹងពាក្យ ៖

មាសសុទ្ធ គង់វង្ស រីកចម្រើន ជឿនលឿន ។

គ. ចូរស្រង់គុណនាមចង្អុលនៅក្នុងអត្ថបទខាងលើ ។

4

## អត្ថបទព័ត៌មានខ្លី

ចូរអ្នកពិនិត្យតារាងបង្ហាញព័ត៌មានអំពី "ធនធានធម្មជាតិក្រោមដី" រួចអានអត្ថបទអំណានដែលនៅពីខាងក្រោម ដោយយកចិត្តទុកដាក់ ដើម្បីជាទុនក្នុងការធ្វើលំហាត់ខាងក្រោម ៖

ក. ចូរអ្នកពិភាក្សាគ្នា ដើម្បីគូសតារាងដោយប្រើលេខ ឬចំណុចមូលខ្មៅ និងសរសេរបង្ហាញព័ត៌មានអំពីប្រធានបទអ្វីមួយដែលអ្នកបានដឹង ឬបានស្គាល់ ដោយមើលលំនាំតារាងក្នុងអំណានទី ១ ។

ឧទាហរណ៍ : រ៉ែមាសនៅកម្ពុជា

| ឈ្មោះរ៉ែ | ឈ្មោះកន្លែងមានរ៉ែ |
|---|---|
| | |

ខ. ចូរអ្នកសរសេរអត្ថបទខ្លីមួយ ផ្អែកលើតារាងខាងលើឱ្យបានប្រាំល្បះយ៉ាងតិច អំពីប្រធានបទដែលអ្នកបានជ្រើសរើស ។

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

មេរៀនទី

# ៤ ប្រយោជន៍នៃធម្មជាតិ



ធម្មជាតិមានទឹកដី ព្រៃព្រឹក្សា បក្សាបក្សី មច្ឆជាតិ ភ្នំ ស្ទឹង បឹងបួ ទន្លេ សមុទ្រ ។ល ។ ធម្មជាតិបានផ្តល់ភាពក្សេមក្សាន្ត និងផ្តល់ប្រយោជន៍ដ៏វិសេសវិសាលដល់មនុស្ស ប៉ុន្តែមនុស្សបែរជាបំផ្លិចបំផ្លាញធម្មជាតិឥតឈប់ឈរទៅវិញ ។

តើនឹងមានអ្វីខ្លះកើតឡើងចំពោះមនុស្សជាតិ បើធម្មជាតិវិនាសអស់?

## ព្រឹត្តិការណ៍រឿង

តើព្រឹត្តិការណ៍ជាអ្វី ? ព្រឹត្តិការណ៍ គឺជាហេតុការណ៍ ដែលកើតមានជាធម្មតានៅក្នុងសង្គម ឬនៅក្នុងរឿងនិទានផ្សេងៗ ។

នៅក្នុងរឿងមួយ តែងមានហេតុការណ៍ផ្សេងៗកើតឡើង ។ សកម្មភាព ឬអ្វីដែលតួអង្គធ្វើ និងជួបប្រទះ ឬអ្វីៗដែលកើតឡើងចំពោះតួអង្គ គឺជាព្រឹត្តិការណ៍រឿង ។

ចូរអ្នកអានរឿងខាងក្រោមនេះ ។ តើរឿងនេះមានព្រឹត្តិការណ៍អ្វីខ្លះ ?

### រឿង ក្តីប្រាថ្នារបស់កូនឫស្សី

កាលដើមឡើយ មានកូនឫស្សីមួយដើម មិនពេញចិត្តនឹងស្លឹករបស់វាសោះ ។ វាយល់ថា ស្លឹករបស់វាមានរាងវែង ហើយស្តើងពេកទៀតផង ។ វានិយាយថា វាចង់បានស្លឹកវាដូចមាស បើបានស្លឹកមាសទើបស្អាត ។

រុក្ខទេវតាឮដូច្នោះ ក៏បានធ្វើឱ្យស្លឹករបស់វាក្លាយជាមាសដូចប្រាថ្នា ។ កូនឫស្សីសប្បាយចិត្តណាស់ ។ ក្រោយមក មានបុរសម្នាក់ដើរមកឃើញកូនឫស្សីមានស្លឹកមាស ក៏បេះស្លឹកទាំងនោះយកទៅលក់ទាល់តែអស់ ។

កូនឫស្សីនឹកឃើញថា ស្លឹកមាសមិនសមនឹងវាទេ វាចង់បានស្លឹកដូចកញ្ចក់វិញ ។ រុក្ខទេវតា ក៏ផ្តល់ស្លឹកកញ្ចក់ឱ្យកូនឫស្សីដូចបំណង ។ កូនឫស្សីពេញចិត្តណាស់ ។ ប៉ុន្តែមិនយូរប៉ុន្មានស្រាប់តែមានភ្លៀងធ្លាក់យ៉ាងខ្លាំង ថែមទាំងមានខ្យល់បក់បោក ធ្វើឱ្យស្លឹកកញ្ចក់នោះបែកខ្ទេចខ្ទីអស់ ។ លើកនេះ កូនឫស្សីផ្សងថា សូមឱ្យវាមានស្លឹកធំៗ ហើយមានពណ៌បៃតងដូចឈើឯទៀតវិញ ។ រុក្ខទេវតា ក៏ជួយសម្រេចក្តីប្រាថ្នារបស់វាទៀត ។ ប៉ុន្តែបន្តិចក្រោយមក សត្វពពែបានមកដល់ ហើយស៊ីស្លឹកវាគ្មានសេសសល់ ។

កូនឫស្សីនិយាយថា ស្លឹកដែលសក្តិសមនឹងខ្លួនវា មានតែស្លឹកចាស់របស់វាតែប៉ុណ្ណោះ ។ ស្លឹកវែងស្តើង ដែលធម្មជាតិបង្កើតមកពិតជាសមចំពោះវាណាស់ ។ រុក្ខទេវតា ក៏ធ្វើឱ្យកូនឫស្សីនោះមានស្លឹកដូចដើមវិញ ។

រឿងខាងលើមានព្រឹត្តិការណ៍ចំនួន ៤ ៖

១. កូនឫស្សីមិនពេញចិត្តនឹងស្លឹកកំណើតរបស់វា ហើយចង់បានស្លឹកមាស ។

២. កូនឫស្សីចង់បានស្លឹកកញ្ចក់ ។

៣. កូនឫស្សីចង់បានស្លឹកពណ៌បៃតងហើយធំ ។

៤. កូនឫស្សីចង់បានស្លឹកដូចដើមវិញ ។

ព្រឹត្តិការណ៍នៃរឿង គឺជាហេតុការណ៍ដែលកើតឡើងនៅក្នុងរឿងនិទានផ្សេងៗ ។

## លំហាត់

ចូរអានរឿងខាងក្រោម ហើយរកព្រឹត្តិការណ៍នៃរឿង ។

### រឿង កូនសេក

ព្រឹងជាអ្នកយាមចម្ការដំឡូងរបស់ថៅកែម្នាក់ ។ គេសង់កូនខ្ទមតូចមួយនៅក្បែរជើងភ្នំ ។ ពេលយប់ ព្រឹងតែងប្រទះឃើញសត្វព្រៃមាន ប្រើស ឈ្លូស និងជ្រូកព្រៃដើររកស៊ីក្នុងចម្ការនោះ ។ ពេលថ្ងៃ សត្វបក្សាបក្សីហើរច្រវាត់ពេញព្រៃ ។

ពេលរសៀលមួយ ព្រឹងឃើញកូនសត្វធ្លាក់នៅមុខខ្ទម ។ គេដើរទៅមើលឃើញកូនសេករបួសជើងម្ខាងហើរមិនរួច ។ ព្រឹងរើសកូនសេកថ្នមៗ យកមកលាបថ្នាំឱ្យ ។ ភ្លាមនោះ មេសេកហើរមកស្រែកចេចចាចៗ ចង់ចុះមកយកកូនតែមិនហ៊ាន ។ ព្រឹងនិយាយទៅកាន់សេក ៖ " ឯងកុំភ័យអី ខ្ញុំមិនធ្វើអីកូនរបស់ឯងទេ ។ ចាំវាជា ខ្ញុំនឹងលែងវាឱ្យទៅជួបឯងវិញ " ។ ថាហើយ ព្រឹងយកកូនសេកទៅក្រុងក្នុងអង្រុត ហើយដាក់ទឹកនិងចំណីឱ្យវា ។ កូនសេកយំរកមេឥតឈប់ ។ ឯមេវាក៏មិនហ៊ានទៅណាឆ្ងាយពីកូនដែរ ។

ពីរបីថ្ងៃក្រោយមក ជើងរបស់កូនសេកបានជាដូចដើម ។ វាហើរចុះហើរឡើងនៅក្នុងអង្រុត ។ ព្រឹងពិនិត្យឃើញថា កូនសេកជាមែនទែនហើយ ក៏លែងវាឱ្យហើរទៅជួបមេវាវិញ ។

# រឿង ការភ្ញាក់រឭករបស់ អ៊ំ សែម




ព្រឹកមួយ កសិករចំណាស់ម្នាក់ឈ្មោះសែម បានយកផ្លាកមួយផ្ទាំងទៅបោះភ្ជាប់នឹងទ្វារចូលក្នុងដីដ៏ធំរបស់គាត់ ។ ផ្លាកនោះសរសេរថា " ដីសម្រាប់លក់ " ។

បោះផ្លាករួច អ៊ំសែមក៏ថយក្រោយបន្តិច ដើម្បីអានអក្សរនៅលើផ្លាកនោះ ។ បន្ទាប់មក គាត់អង្គុយចុះ ក្រោមដើមឈើមួយដើម ។

ភ្លាមនោះ មានបុរសពីរនាក់ជិះរថយន្តទំនើបមួយគ្រឿងមកឈប់នៅចំពីមុខគាត់ ។ បុរសម្នាក់ ចុះពីរថយន្តហើយសួរគាត់ ៖ " តើដីនេះសម្រាប់លក់មែន ឬទេ ? តើអ្នកណាជាម្ចាស់ដីនេះ ? " ។

អ៊ំសែម ក្រោកឈរហើយនិយាយដោយយឺតៗ ៖ " បាទ! នេះជាដីសម្រាប់លក់ ហើយវាជារបស់ខ្ញុំ" ។

អ៊ំសែម បាននាំបុរសទាំងពីរដើរមើលដីនោះ ។ នៅពេលឆ្លងកាត់ព្រែក បុរសម្នាក់បាននិយាយ ៖ " យើងនឹងចាក់ដីបំពេញព្រែកនេះ ហើយសង់អគារនៅលើដីនេះ" ។

អ៊ំសែមភ្លាត់មាត់ ៖ " បំពេញព្រែក ! ដូច្នេះ តើកង្កែបនឹងទៅឯណា ? " ។

បុរសម្នាក់ឆ្លើយ ៖“អូ! វាអាចទៅនៅព្រៃកផ្សេងទៀត ។ កង្កែបមិនសំខាន់ទេ” ។

អ៊ំតបវិញ ៖ “ ប៉ុន្តែវាសំខាន់ ព្រោះវាស៊ីសត្វល្អិតដូចជាមូសជាដើម ” ។

នៅពេលដើរទៅដល់ដើមឈើធំមួយ បុរសម្នាក់និយាយ ៖“ យើងនឹងជួលគេឱ្យកាប់ដើមឈើនេះ យកធ្វើជាអុសលក់ ។ បន្ទាប់មក យើងសង់អគារច្រើនទៀត” ។

លោកអ៊ំថ្ងូរតិចៗ ៖“កាប់ដើមឈើ! កន្លែងនេះនឹងប្រែជាក្តៅខ្លាំងមិនខាន” ។

បុរសម្នាក់ឆ្លើយ ៖ “ មែនហើយ ! យើងនឹងដាក់ម៉ាស៊ីនត្រជាក់ និងកង្ហារក្នុងអគារ ” ។

អ៊ំនិយាយ ៖ “ ដើមឈើជាមិត្តដ៏ល្អ វាសម្អាតខ្យល់ ។ នៅពេលអស់ដើមឈើ ខ្យល់នឹងមិនបរិសុទ្ធទេ” ។

ពួកគាត់នាំគ្នាដើររហូតដល់ទន្លេ ។ បុរសម្នាក់និយាយដោយពេញចិត្ត ៖ “ ល្អណាស់ ! កាកសំណល់ចេញពីរោងចក្រនឹងត្រូវបង្ហូរចូលទន្លេនេះ” ។

អ៊ំលែងនិយាយអ្វីទាំងអស់ ប៉ុន្តែគាត់បានស្រមៃឃើញ ទន្លេនោះលែងស្អាតទៀតហើយ ចំណែកត្រីធំៗងាប់ដោយកាកសំណល់នោះ ។

បុរសទាំងពីរបានដកប្រាក់មករាប់ ដើម្បីប្រគល់ជូនអ៊ំសែម ។ ពេលនោះ អ៊ំសែមប្តូរចិត្ត មិនព្រមលក់ដីនោះវិញ ។ គាត់គិតថា បើគាត់លក់ដីនេះ មានន័យថា គាត់បានចូលរួមចំណែកក្នុងការបំផ្លាញបរិស្ថានដែរ ។ គាត់ក៏ប្រាប់ទៅបុរសទាំងពីរ ៖“ ខ្ញុំមិនលក់ដីនេះទេ ព្រោះខ្ញុំមិនចង់បំផ្លាញធម្មជាតិឡើយ ” ។

## សំណួរ

១. តើអ៊ំសែមដាក់ផ្លាកសញ្ញាដើម្បីអ្វី ?

២. ហេតុអ្វីបានជាគាត់ចង់លក់ដី ?

៣. តើអ្នកចង់ទិញដី មានគម្រោងធ្វើអ្វីខ្លះ ?

៤. ហេតុអ្វីបានជាអ៊ំសែមសម្រេចចិត្តឈប់លក់ដី ?

៥. តើអ៊ំសែមមានអារម្មណ៍ដូចម្តេច នៅពេលគាត់ឮបុរសទាំងពីរនិយាយពីគម្រោងរបស់ពួកគេ ?

៦. តើអារម្មណ៍របស់អ៊ំសែម ត្រូវបានបង្ហាញដោយត្រង់ ឬបង្កប់ ?

៧. តើរឿងនេះមានតួអង្គណាខ្លះ ? តើអ្នកចូលចិត្តតួអង្គណាជាងគេ ? ហេតុអ្វី ?

## លំហាត់

ក. ចូររកពាក្យផ្ទុយនឹងពាក្យ ៖

ចំណាស់ ថយក្រោយ អង្គុយចុះ ទំនើប ក្តៅខ្លាំង ល្អ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ ៖ ដ៏ សួរ កំពុង ។

គ. ចូររកពាក្យដែលមានន័យដូចគ្នាមកជំនួសពាក្យដែលមានគំនូសពីក្រោម ។

១. ព្រឹកមួយ <u>កសិករ</u> ចំណាស់ម្នាក់ បានយកផ្លាកទៅបោះភ្ជាប់នឹងទ្វារចូល ... ។

២. មានបុរសពីរនាក់ជិះ<u>រថយន្ត</u> ទំនើបមួយគ្រឿង ។

៣. នៅពេលអស់ដើមឈើ ខ្យល់នឹងមិន<u>បរិសុទ្ធ</u>ទេ ។

ឃ. ចូរបង្ហាញព្រឹត្តិការណ៍នៃរឿងខាងលើ ។

ង. តើរឿងនេះចង់អប់រំដូចម្តេច ? ចូរជ្រើសរើសចម្លើយសមស្របមួយ ។

១. ត្រូវស្រឡាញ់ និងថែរក្សាព្រៃឈើ ។

២. ត្រូវស្រឡាញ់ និងថែរក្សាសត្វផ្សេងៗ ។

៣. ត្រូវស្រឡាញ់ និងថែរក្សាបរិស្ថានធម្មជាតិ ។

ច. តើការឆ្លើយតបរបស់អ៊ំសែម ទៅកាន់បុរសទាំងពីរនាក់ បញ្ជាក់ពីអារម្មណ៍បែបណារបស់គាត់ ? ចូរជ្រើសរើសចម្លើយមួយសមស្រប ។

១. អ៊ំសែមភ័យខ្លាចបាត់បង់ដី ។

២. អ៊ំសែមភ័យខ្លាចបាត់បង់សម្បត្តិធម្មជាតិ ។

៣. អ៊ំសែមឈឺចាប់នឹងសម្តីរបស់បុរសទាំងពីរ ។

# រឿង ស្រីកណ្តុរល្មោច













១. តើបុរសមានប្រពន្ធនោះធ្វើអ្វីរាល់ថ្ងៃ ?

២. តើមានហេតុការណ៍អ្វីកើតឡើង នៅពេលគាត់កាប់ដល់ដើមជ្រៃ ?

៣. តើគាត់យកមាសនោះទៅឯណា ?

៤. ហេតុអ្វីបានជាប្រពន្ធបុរសនោះ ប្រើប្តីឱ្យកាប់ដើមជ្រៃ ?

៥. តើប្រពន្ធបុរសនោះជាមនុស្សដូចម្តេច ?

៦. តើបុរសរកឃើញមាសដែរឬទេ នៅពេលគាត់រំលំដើមជ្រៃ ?

៧. តើមានអ្វីកើតឡើង នៅទីបញ្ចប់នៃរឿង ?

៨. តើផ្នែកណាមួយនៃរឿងដែលល្អ ?

៩. ហេតុអ្វីទើបអ្នកយល់ថាផ្នែកនេះល្អ ?

១០. តើរឿងនេះចង់អប់រំដូចម្តេច ?

## កិរិយាអកម្ម

កិរិយា គឺជាសម្ដីសម្ដែងអំពើ ឬជាពាក្យសម្គាល់សកម្មភាព ។

ចូរអានឧទាហរណ៍ខាងក្រោម ។ តើពាក្យណាខ្លះជាកិរិយាអកម្ម ?

៥. គាត់នាំគ្នាដើរ រហូតដល់ទន្លេ ។

១. កង្កែបលោត ។

២. ទឹកហូររីមៗ ។

៤. ត្រីធំៗនឹងងាប់អស់ ។

៣. ដើមជ្រៃរលំ ។

ពាក្យ " ដើរ លោត ហូរ ងាប់ រលំ " ជាកិរិយាដែលពុំមានកម្មបទផ្ទាល់ ឬពាក្យសម្រាប់បំពេញន័យទេ ។ កិរិយាទាំងនេះមានឈ្មោះថា " កិរិយាអកម្ម " ។

> កិរិយាអកម្ម គឺជាកិរិយាដែលមិនត្រូវការកម្មបទផ្ទាល់ ។

កិរិយាអកម្មមាន៖ សើច យំ ស្រែក ឈរ អង្គុយ ហើរ លោត ដើរ... ។

### លំហាត់

ក. ចូររកកិរិយាអកម្មឱ្យបាន៣ ហើយបង្កើតល្បះនឹងកិរិយាទាំងនោះ ។

ខ. ចូរស្រង់កិរិយាអកម្មនៅក្នុងកថាខណ្ឌខាងក្រោម ។

បុរសចំណាស់អង្គុយក្រោមដើមឈើម្នាក់ឯង ។ គាត់និយាយបណ្ដើរ ក្រោកឈរបណ្ដើរ ។ បន្ទាប់មកគាត់យកដៃអេះក្បាល ហើយដើរទៅមុខទៀតដោយយឺតៗ ។ ពេលនោះស្រាប់តែមេឃងងឹត ខ្យល់បក់បោកពីគ្រប់ទិសទី គាត់ក៏រត់សំដៅមកផ្ទះ ។ ភ្លាមនោះភ្លៀងចាប់ផ្ដើមធ្លាក់យ៉ាងខ្លាំង ផ្គរគ្រហឹមពេញមេឃ ។ ភ្លៀងធ្លាក់ ហ៊ឹងក៏ចាប់ផ្ដើមយំប្រណាំងគ្នា ។

# យើងរួមគ្នាថែរក្សាបរិស្ថាន



ថ្ងៃនេះ រដ្ឋាសប្បាយចិត្តណាស់ ។ គេនិងឪពុកគេកំពុងជិះរថភ្លើងធ្វើដំណើរទៅកសិដ្ឋានរបស់លោកតាគេ ។

នៅតាមផ្លូវ រដ្ឋាមើលវាលស្រែ ភ្នំ និងសត្វ ហើយនិយាយទៅកាន់ឪពុក ៖"ប៉ា! ខ្ញុំនឹងទៅហែលទឹកលេងក្នុងទន្លេដ៏ធំ ។ ខ្ញុំនឹងចាប់ត្រីមួយចំនួន និងឡើងដើមឈើទៀត" ។ ឪពុករបស់រដ្ឋាបន្ថែម ៖" ហើយជិះលើខ្នងក្របី ចាប់កង្កែប និងបេះផ្លែឈើ ដូចប៉ាធ្វើកាលពីក្មេង" ។

បន្ទាប់ពីធ្វើដំណើរយ៉ាងយូរ ពួកគេក៏បានទៅដល់កសិដ្ឋាននោះ ។ លោកតានិងចៅសប្បាយចិត្តណាស់ នៅពេលបានជួបគ្នា ។ ប៉ុន្តែបន្តិចក្រោយមក រដ្ឋាបែរជាក្រៀមក្រំចង់យំទៅវិញ ។ តើមកពីមូលហេតុអ្វី ? រដ្ឋាដឹងថាវាមិនអាចហែលទឹក វាមិនអាចជិះទូក ហើយវាមិនអាចចាប់ត្រីបានទេ ។

លោកតាបានប្រាប់ថា ៖“ ទន្លេត្រូវបានបំពុលហើយ ។ វាកខ្វក់ណាស់ ត្រីមិនអាចរស់នៅបានទេ ។ រោងចក្របានបង្ហូរទឹកកខ្វក់ចូលក្នុងទន្លេ ចំណែកមនុស្សក៏បំពុលទឹកទន្លេដោយបោះកាកសំណល់ផ្សេងដែរ” ។ កន្លងមក មានការអប់រំអំពីការបំពុលនេះដែរ ប៉ុន្តែយើងត្រូវការពេលយូរ ទើបទទួលបានផល ។

រដ្ឋានិយាយដោយក្រៀមក្រំ ៖“លោកតា! តើចៅអាចទៅមើលដើមឈើធំៗ និងបេះផ្លែឈើបាន ឬទេ ?” ។ លោកតានិយាយដោយការសោកស្តាយ ៖“ ឈើជាច្រើននៅក្បែរភ្នំត្រូវគេកាប់អស់ហើយ” ។

ឪពុករដ្ឋាមើលតាមបង្អួច ឃើញដើមឈើតិចតួចប៉ុណ្ណោះ ។ គាត់និយាយ ៖ “ ដើមឈើនៅសល់តិចតួចណាស់ ។ ដូច្នេះ សត្វព្រៃក៏ខ្សត់ដែរ ” គាងក់ក្បាលតិចៗនិងនិយាយ ៖“គួរឱ្យសោកស្តាយណាស់ ប៉ុន្មានឆ្នាំនេះ យើងខ្សត់ទាំងដើមឈើទាំងសត្វ ឯដំណាំរដូវក៏មិនល្អដែរ ដោយសារទឹកជំនន់ដ៏ធំបានធ្វើឱ្យដីអស់ជីជាតិ ។ ដីគ្មានជីជាតិធ្វើឱ្យបន្លែ និងរុក្ខជាតិមិនអាចលូតលាស់បានទេ ។ សព្វថ្ងៃ កសិករតិចតួចណាស់នៅដាំបន្លែ” ។

រដ្ឋាសួរឪពុកទាំងមិនអស់ចិត្ត ៖ ប៉ា! តើយើងអាចស្តារស្ថានភាពនេះបាន ឬទេ ? ឪពុករដ្ឋានិយាយ ៖ ប៉ាយល់ថា អ្វីដែលយើងត្រូវធ្វើ គឺយើងនឹងដាំកូនឈើឱ្យបានច្រើននៅតាមកសិដ្ឋាននានា ។ យើងនឹងបានកសិដ្ឋានកូនឈើ ” ។

## សំណួរ

១. តើរដ្ឋានិងឪពុករបស់គេ ធ្វើដំណើរទៅឯណា ?

២. តើនៅទីនោះ រដ្ឋាមានគម្រោងនឹងធ្វើអ្វីខ្លះ ?

៣. តើរដ្ឋាបានហែលទឹកទន្លេ និងបានចាប់ត្រីដែរ ឬទេ ? ហេតុអ្វី ?

៤. តើទន្លេត្រូវបំពុលដោយរបៀបណា ?

៥. តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីថែរក្សាបរិស្ថានធម្មជាតិ ?

# លំហាត់

ក. ចូរអានពាក្យពហុព្យាង្គ (ពាក្យច្រើនព្យាង្គ) ខាងក្រោម ៖

កសិដ្ឋាន រុក្ខជាតិ កសិករ ។

ខ. ចូរជ្រើសរើសពាក្យមួយ ដែលមានន័យដូចពាក្យ ៖

១. កសិដ្ឋាន ៖

☐ កន្លែងចិញ្ចឹមសត្វ ☐ កន្លែងធ្វើស្រែចម្ការ

☐ កន្លែងដាំដើមឈើ ។

២. រុក្ខជាតិ ៖

☐ ដើមឈើ ☐ វល្លិផ្សេងៗ ☐ ផ្លែឈើ ។

៣. កសិករ ៖

☐ អ្នកថែសួន ☐ អ្នកដាំបន្លែ ☐ អ្នកធ្វើស្រែចម្ការ ។

គ. ចូរសរសេរពាក្យផ្ទុយនឹងពាក្យ ៖

សប្បាយចិត្ត លឿន យូរ ក្រៀមក្រំ កខ្វក់ តិចតួច ។

ឃ. ចូររកពាក្យសូរដូចនឹងពាក្យ " ចិត្ត ដី " ។

ង. ចូរបង្ហាញតម្លៃអប់រំនៃរឿង ដោយជ្រើសរើសចម្លើយសមស្របមួយ ។

☐ ១. ត្រូវចូលរួមដាំដើមឈើឱ្យបានច្រើន ។

☐ ២. ត្រូវចូលរួមថែរក្សាបរិស្ថានធម្មជាតិ ។

☐ ៣. ត្រូវជួយអប់រំប្រជាជនកុំឱ្យបំពុលទឹក ។

ច. ចូរស្រង់កិរិយាអកម្មនៅក្នុងអត្ថបទខាងលើ ឱ្យបាន៤ ។

ឆ. ចូរស្រង់ព្រឹត្តិការណ៍នៃរឿងខាងលើតាមលំដាប់លំដោយ រួចសរសេរដាក់ក្នុងសៀវភៅសរសេររបស់អ្នក ។

## សញ្ញាផាត់លើ ឬសំយោគសញ្ញា

ក. ឧទាហរណ៍

១. ប្រជាជន នាំគ្នាយកជ័រទឹកពីដើមឈើទាល ។

២. ល័ខខ្មែរ មានគុណភាពល្អជាងល័ខនាំចូលពីបរទេស ។

៣. គាត់អាស្រ័យបាយក្រោមដើមរាំង ។

៤. សូមឱ្យអ្នកឆ្លងផុតគ្រោះភ័យទាំងឡាយ ។

សញ្ញាផាត់លើសម្រាប់បង្កើតសូរស្រៈ [អ៊ី] [អ៉] [អែ] និង[អ៊ែ] ។

ខ. ទីកន្លែង

សញ្ញានេះ ប្រើនៅលើព្យញ្ជនៈដើមព្យាង្គ ។

### លំហាត់

ក. ចូររកពាក្យដែលមានសញ្ញាផាត់លើឱ្យបាន៥ពាក្យ ។

ខ. ចូរបំពេញល្បះដោយប្រើពាក្យមានសញ្ញាផាត់លើឱ្យបានសមស្រប ។

១. តើផ្កានេះមាន... អ្វី ?

២. តើពាក្យនេះមាន... ដូចម្តេច ?

៣. ទិស... ស្ថិតនៅចន្លោះទិសបស្ចិម និងទិសឧត្តរ ។

៤. គេបើក... សៀវភៅអានដោយថ្នមៗ ។

៥. គាត់ក្តៅខ្លាំងហើយរងា... ដូចគ្រុន ។

គ. ចូរបង្កើតល្បះនឹងពាក្យនីមួយៗខាងក្រោម ៖

ជ័យ  ប្រល័យ  កេងប្រវ័ញ្ច

ឃ. ចូរអ្នកសរសេររឿងនិទានខ្លីមួយនិយាយអំពីអ្វីមួយ ដែលទាក់ទងនឹងធម្មជាតិដូចជា ព្រៃឈើ ទន្លេ ឬភ្នំ... ។

# ការពណ៌នាអំពីប្រយោជន៍នៃព្រៃឈើ

សំបូរនិងសម្បត្តិ បាននាំគ្នាទៅកម្សាន្តនៅក្នុងឧទ្យានជាតិមួយ ។ ពួកគេ បាននិយាយគ្នាអំពីប្រយោជន៍នៃព្រៃឈើ ។ ចូរអានការសន្ទនាខាងក្រោម ។

| | | |
|---|---|---|
| សំបូរ | : | សម្បត្តិ! នៅទីនេះមានដើមឈើច្រើនណាស់ ហើយត្រជាក់ទៀត ។ តើឯងស្គាល់ដើមឈើទាំងនេះទេ ? |
| សម្បត្តិ | : | ខ្ញុំស្គាល់ដើមឈើច្រើនណាស់ ពីព្រោះខ្ញុំធ្លាប់ចូលព្រៃជាមួយឪពុកខ្ញុំ ។ នេះជាដើមបេង ។ នេះជាកកោះ ។ នោះជាថ្នឹក និងឈើទាល ។ រីឯដើមត្រង់ហើយមានពណ៌សនោះ ជាដើមស្រឡៅ ។ |
| សំបូរ | : | តើឯងដឹងថា ដើមឈើមានប្រយោជន៍អ្វីខ្លះ? |
| សម្បត្តិ | : | ដើមឈើជាជម្រកសត្វព្រៃ ជាគ្រឿងសំណង់ និងគ្រឿងប្រើប្រាស់ផ្សេងៗ ។ ព្រៃឈើផ្តល់អុសដុត ថ្នាំសង្កូវ ចំណីអាហារមនុស្ស សត្វ ឯស្លឹកឈើធ្វើឱ្យដីមានជីជាតិ ។ |
| សំបូរ | : | ដើមឈើបញ្ចេញចំហាយទឹកជាពពក ធ្វើឱ្យមានភ្លៀងទៀងទាត់ ។ |
| សម្បត្តិ | : | នៅមានទៀត ដើមឈើជួយការពារយើងពីកម្តៅព្រះអាទិត្យកុំឱ្យយើងរងកម្តៅខ្លាំង និងស្រូបទឹកភ្លៀងដែលអាចការពារកុំឱ្យមានទឹកជំនន់លិចលង់ខ្លាំងខុសពីធម្មតា ។ |
| សំបូរ | : | ដោយសារព្រៃឈើមានប្រយោជន៍ច្រើនយ៉ាងនេះ យើងត្រូវតែនាំគ្នាជួយថែរក្សាព្រៃឈើដែលនៅសេសសល់ឱ្យបានគង់វង្ស និងដាំកូនឈើបន្ថែមឱ្យបានច្រើនទៀតមែនទេ ? |
| សម្បត្តិ | : | មែនហើយសម្លាញ់ ! |

## លំហាត់

ចូរអ្នកចាប់គូ ឬពិភាក្សាគ្នាតាមក្រុម ដើម្បីរៀបចំការពណ៌នាអំពីប្រយោជន៍នៃដើមឈើណាមួយ ដែលអ្នកបានដាំ ។

## សំណេររឿងនិទាន

អ្នកធ្លាប់បានអាន និងស្ដាប់រឿងជាច្រើនមកហើយ ។ រឿងខ្លះមានតួអង្គតិច រឿងខ្លះមានតួអង្គច្រើន ។ រឿងខ្លះមានព្រឹត្តិការណ៍រឿងតែមួយ ដំណើររឿងខ្លី រឿងមួយចំនួនទៀតមានព្រឹត្តិការណ៍រឿងច្រើន ធ្វើឱ្យដំណើររឿងវែង ។

ចូរអ្នកអានអត្ថបទអំណានទាំងពីរ ហើយពិនិត្យមើល តើមានតួអង្គតិច ឬច្រើន ហើយដំណើររឿងវែង ឬខ្លី ។ តើក្នុងរឿងមានព្រឹត្តិការណ៍ប៉ុន្មាន តួអង្គជួបនឹងបញ្ហាអ្វីខ្លះ ឬបានធ្វើអ្វីខ្លះ ?

ចូរអ្នកសរសេររឿងនិទានវែងមួយ ដែលមានតួអង្គច្រើន ។ មុននឹងសរសេរអ្នកត្រូវកំណត់ ៖

- តួអង្គសំខាន់ និងតួអង្គផ្សេងទៀត
- កាលអាកាស ៖
    + ទីកន្លែង (រឿងនោះកើតនៅឯណាខ្លះ ?)
    + ពេលវេលា (រឿងនោះកើតនៅពេលណា ?)
- ព្រឹត្តិការណ៍ (តួអង្គបានធ្វើអ្វីខ្លះ ឬជួបបញ្ហាអ្វីខ្លះ ? តើមានរឿងអ្វីកើតឡើងមុនដំបូង បន្ទាប់មក និងនៅចុងបញ្ចប់នៃរឿង ?)

បន្ទាប់មក អ្នកត្រូវសរសេរព្រាងនៅលើក្រដាសមួយ ។ នៅពេលសរសេរចប់ ចូរអ្នកអាននិងកែលម្អឡើងវិញ ហើយឱ្យមិត្តភក្តិជួយកែលម្អ ។ នៅចុងបញ្ចប់ អ្នកត្រូវចម្លងរឿងនោះឱ្យបានស្អាតជាការស្រេច ។

អ្នកអាចជ្រើសរើសប្រធានបទ ដែលបានរៀនរួចមកហើយ ឬប្រធានបទណាមួយខាងក្រោម ៖

- ការចូលរួមសម្អាតបរិស្ថានតាមដងព្រែក ឬស្ទឹង ឬទន្លេ
- ការចូលរួមការពារសត្វ
- ការចូលរួមការពារព្រៃឈើ ។

មេរៀនទី

# ៥ ធនធានជលផលនៅកម្ពុជា



ប្រទេសកម្ពុជាសម្បូរទៅដោយធនធានធម្មជាតិ ពិសេសធនធានជលផលគ្រប់ប្រភេទ ដែលមាននៅក្នុងបឹងទន្លេសាប ស្ទឹង ទន្លេ សមុទ្រ ដូចជាត្រី ក្ដាម ខ្យង កំពឹស បង្កង បង្គា មឹក ងាវ ។ ធនធានជលផលទាំងអស់នេះសុទ្ធសឹងផ្ដល់ប្រយោជន៍ច្រើនក្រៃលែងចំពោះប្រជាជនយើង ។

តើយើងត្រូវប្រើប្រាស់ និងថែរក្សាការពារដូចម្ដេចខ្លះ ដើម្បីឱ្យធនធានជលផលនៅគង់វង្ស ?

## តម្លៃអប់រំនៃរឿង

ក្នុងរឿងនីមួយៗ អ្នកនិពន្ធតែងតែបង្កប់នូវអត្ថន័យនៃការអប់រំ ។ ក្នុងការអប់រំនេះ អ្នកនិពន្ធមានវិធីបង្ហាញពីរយ៉ាង ៖

ទី១ : បង្ហាញអំពើល្អ ត្រឹមត្រូវ ស្របច្បាប់ ដើម្បីឱ្យអ្នកអានត្រងត្រាប់តាម ឬ យកជាបទពិសោធន៍សម្រាប់ជីវិត ។

ទី២ : បង្ហាញអំពើអាក្រក់ មិនស្របច្បាប់ ដើម្បីឱ្យអ្នកអានជៀសវាង ។

ចូរអានរឿងខាងក្រោម ។ តើរឿងនេះមានន័យអប់រំដូចម្ដេច ?

### រឿង សត្វភេពីរចែកផ្លូវគ្នារកអាហារ

មានសត្វភេពីរ ភេមួយដើររកត្រីខាងទឹកជ្រៅ ភេមួយទៀតដើររកត្រីខាងទឹករាក់ ។ ថ្ងៃមួយ ភេទាំងពីរចុះស្ទឹងមុជទឹកដេញចាប់ត្រី បានត្រីរ៉ស់មួយ ទើបនាំគ្នាទាញឡើងគោក ដើម្បីចែកគ្នា ។ ភេខាងទឹកជ្រៅទាមទារយកចំណែកខាងក្បាល ព្រោះវាថា វាមានការលំបាកខ្លាំងណាស់ ចំណែកឯភេខាងទឹករាក់ក៏ឆ្លើយថា ចំណែកខាងក្បាលត្រូវបានវាទើបត្រឹមត្រូវ ព្រោះបើវាមិនខំស្ទាក់ចាប់ទេ ក៏មិនបានត្រីនេះដែរ ។ ភេទឹកជ្រៅមិនព្រមចែក ទើបភេទាំងពីរឈ្លោះគ្នា រួចនាំគ្នាទៅរកចចកជាចៅក្រមឱ្យចែកឱ្យ ។

ចចកសួរនាំភេទាំងពីរ បានដឹងរឿងរ៉ាវសព្វគ្រប់ហើយ ក៏កាត់ត្រីនោះជា ៣ភាគ ។ ភាគក្បាលឱ្យភេដែលដើរទឹកជ្រៅ ភាគកន្ទុយឱ្យទៅភេដែលដើរខាងទឹករាក់ ភាគកណ្ដាលចចកយកបរិភោគខ្លួនឯង ។ ភេទាំងពីរ កាលបើឃើញចចកយកភាគកណ្ដាលអស់ដូច្នោះ ក៏តូចចិត្តនឹកស្ដាយចំណីរបស់ខ្លួនពន់ពេកណាស់ ។

តម្លៃអប់រំនៃរឿងខាងលើគឺ " ការលោភលន់ហួសប្រមាណ នាំឱ្យខាតលាភ " ។

> តម្លៃអប់រំនៃរឿង គឺជាដំបូន្មាន ឬបទពិសោធន៍ដែលអ្នកអាន អាចទាញយកពីខ្លឹមសារនៃរឿងណាមួយ ។

## លំហាត់

ក. ចូរអានរឿងខាងក្រោម រួចប្រាប់តម្លៃអប់រំនៃរឿង ដោយជ្រើសរើសចម្លើយមួយសមស្រប ៖

### រឿង កុកនិងក្ដាម

នៅក្នុងបឹងមួយមានត្រីតូច ធំ ជាច្រើន ។ នៅពេលទឹករីងហួត ត្រីទាំងឡាយមានការភិតភ័យជាខ្លាំង ។ កុកក្ដាប់បានសភាពការណ៍នេះ ក៏ទៅនិយាយប្រាប់ត្រីថាវាធានានាំត្រីទាំងនោះ ទៅរកកន្លែងដែលមានទឹកច្រើន ។ ត្រីទាំងឡាយក៏ជឿ ហើយយល់ព្រមធ្វើតាមកុក ។ បានឱកាស កុកក៏ពាំត្រីទៅស៊ីម្ដងមួយៗរហូតដល់អស់ ។ ចុងក្រោយបំផុត កុកក៏នាំយកក្ដាមគ្រោងទៅទៀត ។ ទៅដល់គល់ឈើមួយ ក្ដាមគ្រោងសង្កេតឃើញមានឆ្អឹងត្រីជាច្រើនគរនៅនឹងគល់ឈើនោះ ។ វាយល់ពីហេតុការណ៍ ដែលកើតមានកន្លងមក ។ ក្ដាមគ្រោងដឹងថាកុកយកខ្លួនមកស៊ី ក៏ប្រឹងកៀបកកុកយ៉ាងខ្លាំង រហូតដល់កុកបាត់បង់ជីវិត ។

១. មិនត្រូវសេពគប់អ្នកដែលយើងមិនស្គាល់ប្រវត្តិច្បាស់លាស់ ។

២. មិនត្រូវជឿគេដោយខ្វះការពិចារណា ។

៣. មិនត្រូវជួយអ្នកដទៃដោយសម្លឹងផលប្រយោជន៍ ។

ខ. ចូរអានរឿង “កូនបង្កងចចេស ” រួចរកតម្លៃអប់រំនៃរឿង ។

មានកូនបង្កងមួយ រស់នៅក្នុងព្រែកជាមួយនឹងមច្ឆជាតិជាច្រើនទៀត ។ កូនបង្កងនេះ បានអួតពីសម្រស់រាងកាយរបស់វាប្រាប់សត្វឯទៀត ។ វាតែងហែលលេងបង្អួតគេឯងពីសម្រស់របស់វា ។ បង្កងចំណាស់មួយឃើញដូច្នោះ ក៏និយាយណែនាំវា កុំឱ្យបង្ហាញខ្លួននៅលើទឹកត្រូវប្រុងប្រយ័ត្ន ពីព្រោះអ្នកនេសាទច្រើនណាស់ ។

កូនបង្កងឆ្លើយថា ទៅខ្លាចអីអ្នកនេសាទនោះ ។ គាត់មិនងាយចាប់ខ្ញុំបានទេ ខ្ញុំហែលលឿនណាស់ ។ ថាហើយកូនបង្កង ក៏ទៅបបួលមិត្តភក្ដិហែលលេងក្បែរៗទូកនេសាទ ។ កូនបង្កងផ្លៀកផុតពីទឹក ស្រាប់តែអ្នកនេសាទឃើញ ក៏បង់សំណាញ់ចាប់បានកូនបង្កង និងមិត្តភក្ដិវាអស់ ។ កូនបង្កងនឹកស្ដាយក្រោយ តែហួសពេលទៅហើយ ។

# រឿង វាសនាបឹងទន្លេសាប




អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ពូប្រាក់និងមីងសំ រស់នៅក្នុងភូមិផ្លុកទ្រូ ខេត្តកំពង់ឆ្នាំង ។ គ្រួសារគាត់ បានប្រកបមុខរបរនេសាទត្រី និងធ្វើប្រហុក ផ្អក ត្រីងៀត ត្រីឆ្អើរដែលជាអាជីពប្រចាំគ្រួសារ ។ រដូវសម្រុកមកដល់ ពូប្រាក់និងកូនប្រុសគាត់ពីរនាក់តែងតែចេញទៅនេសាទត្រីតាមទម្លាប់របស់គាត់ ។ ក្នុងមួយឆ្នាំៗ គាត់នេសាទត្រីបានយ៉ាងច្រើន ដើម្បីឱ្យប្រពន្ធ និងកូនស្រីគាត់យកទៅលក់នៅឯផ្សារ ធ្វើប្រហុក ផ្អក ទុកសម្រាប់ហូប និងលក់ដូរ ។ ប៉ុន្តែ ប៉ុន្មានឆ្នាំចុងក្រោយនេះ ពូប្រាក់រកត្រីពុំសូវបានដូចមុនៗទៀតឡើយ ។

ថ្ងៃមួយពេលត្រឡប់មកពីនេសាទវិញ គាត់ត្អូញត្អែរប្រាប់ប្រពន្ធដោយអស់សង្ឃឹមៈ “ ម៉ែវាអើយ ! ថ្ងៃនេះ ខ្ញុំរកត្រីមិនបានទេ យើងប្រហែលជាត្រូវដូរមុខរបរហើយ” ។ មីងសំឮដូច្នោះក៏សួរប្ដី ៖ “ ហេតុអ្វីបានជាឪវារកត្រីមិនបាន ?” ។ ពូប្រាក់រៀបរាប់ប្រាប់ភរិយា ៖ “ ម៉ែវាដឹងទេ សព្វថ្ងៃនេះបឹងទន្លេសាបកំពុងទទួលរងគ្រោះធ្ងន់ធ្ងរណាស់ ដោយសារអំពើអគតិរបស់ជនខ្លះ ។ ពួកគេបានទៅកាប់បំផ្លាញព្រៃលិចទឹកជុំវិញបឹង

ដែលជាជម្រកត្រីពងនិងបន្តពូជ ដើម្បីយកដីធ្វើស្រែ ។ ម្យ៉ាងទៀត មនុស្សមួយចំនួនធំបានទៅតាំងទីលំនៅលើទឹក ដើម្បីប្រកបរបរនេសាទ លក់ដូរ និងធ្វើសិប្បកម្មផ្សេងៗ ។ អ្នកទាំងនោះ បានបង្ហូរកាកសំណល់ពីលំនៅស្ថាន និងរោងសិប្បកម្ម ដែលមានជាតិពុលទៅក្នុងទឹកបឹងរាល់ថ្ងៃ ធ្វើឱ្យទឹកបឹងកខ្វក់ហើយរាក់ទៅៗ ។ ជាមួយនោះដែរប្រេងម៉ាស៊ីនកាណូតកប៉ាល់ ក៏នាំឱ្យទឹកបឹងកើនកម្តៅឆាប់រហ័ស បណ្តាលឱ្យត្រីពុល និងងាយងាប់ ។ ពិសេសទៅទៀត អ្នកខ្លះមានមហិច្ឆតាខ្លាំងពេក បានប្រើមង អួន សំណាញ់ដែលមានក្រឡាញឹកដើម្បីនេសាទត្រី ហើយជនល្មើសច្បាប់ខ្លះទៀតបានប្រើខ្សែភ្លើងឆក់ត្រីធ្វើឱ្យត្រីតូចធំងាប់គ្មានសល់ ។ កត្តាទាំងអស់នេះហើយ ដែលធ្វើឱ្យធនធានជលផលរបស់យើងចេះតែខ្សត់ទៅៗ" ។ " បើយ៉ាងនេះ ពួកយើងនឹងរកត្រីមិនបានថ្ងៃណាមួយមិនខានទេឪវា ។ " មីងសំសួរប្តីគាត់ ។ ពូប្រាក់ឆ្លើយឡើង ៖ " មែនហើយ ! បើទោះបីរាជរដ្ឋាភិបាល បានខិតខំអប់រំផ្សព្វផ្សាយច្បាប់នេសាទ និងបំផុសចលនាលែងកូនត្រីតាមបឹងឬយ៉ាងណាក៏ដោយ បើគ្មានអ្នកចូលរួមការពារនោះទេ ធនធានជលផលក៏នឹងវិនាសសាបសូន្យជាមិនខាន ។ បើនៅតែយ៉ាងនេះ ពុំមែនតែក្រុមគ្រួសារយើងទេដែលគ្មានមុខរបរ ឬគ្មានត្រីបរិភោគ គឺប្រទេសជាតិយើងទាំងមូលក៏នឹងធ្លាក់ក្នុងគ្រោះមហន្តរាយផងដែរ" ។

## សំណួរ

១. តើគ្រួសារពូប្រាក់រស់នៅឯណា ?

២. តើគ្រួសារពូប្រាក់ប្រកបមុខរបរអ្វី ?

៣. តើពូប្រាក់ត្អូញត្អែរប្រាប់ប្រពន្ធគាត់អំពីរឿងអ្វី ?

៤. តើបឹងទន្លេសាបកំពុងទទួលរងគ្រោះដោយសារអ្វី ?

៥. តើកត្តាទាំងអស់នោះ ធ្វើឱ្យមានផលប៉ះពាល់ដូចម្តេចខ្លះ ?

៦. ដើម្បីថែរក្សាធនធានជលផលឱ្យនៅគង់វង្ស តើអ្នកត្រូវធ្វើដូចម្តេច ?

## លំហាត់

ក. ចូររកន័យដូចនៃពាក្យ " អាជីព មហន្តរាយ សិប្បកម្ម កត្តា " ដោយជ្រើសរើសចម្លើយត្រឹមត្រូវមួយ ។

១. អាជីព ៖

☐ មុខរបរ ☐ ការចិញ្ចឹមជីវិត ☐ មុខរបរកិច្ចការ ។

២. មហន្តរាយ ៖

☐ សេចក្តីភិតភ័យ ☐ សេចក្តីវិនាសធំ ☐ សេចក្តីវិនាសតិចតួច ។

៣. សិប្បកម្ម ៖

☐ ការធ្វើដោយកម្លាំង ☐ ការជាង ☐ ការច្នៃប្រឌិត ។

៤. កត្តា ៖

☐ ភស្តុតាង ☐ ការផ្តើមធ្វើ ☐ ការសរុបសេចក្តី ។

ខ. តើល្បះមួយណាបង្ហាញតម្លៃអប់រំនៃរឿង ?ចូរជ្រើសរើសចម្លើយមួយសមស្រប ។

☐ ១. ត្រូវចូលរួមក្នុងចលនាលែងកូនត្រីនៅតាមបឹងបួ ។

☐ ២. ត្រូវខិតខំបង្កើតមុខរបរនេសាទនៅបឹងទន្លេសាប ។

☐ ៣. ត្រូវចូលរួមថែរក្សាការពារធនធានជលផលនៅបឹងទន្លេសាប ។

គ. ចូរប្រាប់ព្រឹត្តិការណ៍ទាំងអស់ក្នុងរឿងខាងលើ ។

ឃ. ចូរអ្នកសរសេររឿងខ្លីមួយដោយមើលរូបភាពខាងក្រោម ។



# អត្ថបទពណ៌នា



ត្រីប៉ាសេអ៊ី

ត្រីប៉ាសេអ៊ី ជាត្រីមួយប្រភេទដែលកម្រមាន ហើយជាត្រីដែលមានតម្លៃបំផុតនៅភូមិភាគឦសានក៏ដូចជានៅទូទាំងប្រទេស ។

ត្រីប៉ាសេអ៊ី ជាប្រភេទត្រីស្រកា និងមានរូបរាងស្រដៀងនឹងត្រីព្រួល ។ ត្រីនេះមានប្រវែងពី២០សង់ទីម៉ែត្រ ទៅ៥០សង់ទីម៉ែត្រ និងមានទម្ងន់ពីមួយគីឡូក្រាម ដល់បីគីឡូក្រាម ។ វាយកក្អែលថ្ម និងក្អែលឈើជាអាហារ ។ ត្រីប៉ាសេអ៊ីច្រើនរស់នៅតាមថ្ម ព្រៃលិចទឹក អន្លង់ជ្រៅ និងទឹកជូរ ។ អ្នកនេសាទបានឱ្យដឹងថា ត្រីប៉ាសេអ៊ីជាប្រភេទត្រីដែលមានតែនៅក្នុងអាងទន្លេបួន គឺទន្លេសេកុង សេសាន ស្រែពក និងទន្លេមេគង្គនៃខេត្តស្ទឹងត្រែងប៉ុណ្ណោះ ។ ក្នុងមួយឆ្នាំ ត្រីប៉ាសេអ៊ី ធ្វើការផ្លាស់ទីចំនួនពីរលើកជាទៀងទាត់ គឺលើកទី១ នៅដើមខែធ្នូដល់ខែមករា វាឡើងមកទន្លេសេសាននិងស្រែពក ចូលទៅក្នុងទន្លេសេកុង រួចឡើងទៅក្នុងតំបន់ទន្លេមេគង្គភាគខាងលើរហូតដល់តំបន់ល្បាក់ខោននៃព្រំដែនប្រទេសកម្ពុជា - ឡាវ ។ លើកទី២ពីខែមេសា ដល់ខែឧសភា វាត្រឡប់ឡើងទៅទន្លេស្រែពកវិញ ។ អាស្រ័យហេតុនេះ ទើបគេអាចនេសាទត្រីនេះបានតែពីរដងប៉ុណ្ណោះក្នុងមួយឆ្នាំ ។

គេអាចយកត្រីប៉ាសេអ៊ីទៅធ្វើម្ហូបបានច្រើនមុខ ពិសេសស្ងោរជ្រក់មានឱជារសឆ្ងាញ់ពិសាលើសត្រីដទៃទៀត ។ ដូច្នេះ អ្នកនេសាទគប្បីគោរពច្បាប់នេសាទគ្រប់គ្នា ដើម្បីថែរក្សាមច្ឆជាតិរបស់យើងឱ្យគង់វង្ស ពិសេសពូជត្រីដ៏កម្រនេះ ។

លំហាត់

ក. ចូរអ្នកសរសេរកថាខណ្ឌពណ៌នាអំពីត្រីខាងក្រោម ដោយគ្រាន់តែប្រាប់ឈ្មោះ និងរៀបរាប់អំពីរូបរាងរបស់វាតែប៉ុណ្ណោះ ។



ខ. ចូរអ្នកគូររូបត្រីមួយ ដែលអ្នកបានស្គាល់ច្បាស់ ឬ អ្នកបានចិញ្ចឹម រួចផាត់ពណ៌វាទៅតាមធម្មជាតិ ។ បន្ទាប់មក ចូរអ្នកសរសេរអត្ថបទខ្លីមួយ ពណ៌នាអំពីត្រីនោះឱ្យបានក្បោះក្បាយ ។

ក្នុងការសរសេរអ្នកត្រូវគោរពតាមគម្រោងតែងខាងក្រោម ៖

គម្រោងតែង

១. សេចក្ដីផ្ដើម

- ពេលវេលា និងទីកន្លែងចិញ្ចឹម
- ឈ្មោះត្រី កន្លែងរស់នៅ

២. តួសេចក្ដី

- រូបរាង ពណ៌សម្បុរ ប្រវែង ទម្ងន់ ក្បាល ព្រុយ ស្រកា ស្រកី កន្ទុយ ...
- ចំណី
- ផលប្រយោជន៍

៣. បញ្ចប់សេចក្ដី

ចំណាប់អារម្មណ៍របស់អ្នកសរសេរ ។

# ១ រឿង ដំណើរកម្សាន្តនៅអន្លង់ត្រីផ្សោត

ចូរស្តាប់រឿងដែលបានសរសេររួចហើយឡើងវិញ ។



## សំណួរ

១. តើអ្នកណា ធ្វើដំណើរទៅមើលត្រីផ្សោត ?

២. តើត្រីផ្សោតមាននៅឯណា ?

៣. តើបច្ចុប្បន្នត្រីផ្សោតមានតិច ឬច្រើន ?

៤. ហេតុអ្វីបានជាត្រីផ្សោតមាននៅសល់តិច ?

៥. តើតំបន់ដែលមានត្រីផ្សោត បានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជន ?

៦. តើរាជរដ្ឋាភិបាលបានធ្វើអ្វីខ្លះ ដើម្បីអភិរក្សត្រីផ្សោត ?

៧. តើតួអង្គណាមួយ ដែលកំពុងនិយាយប្រាប់រឿងនេះ ?

## លំហាត់

ចូរអានល្បះខាងក្រោមនេះ ។ តើល្បះមួយណាផ្តល់តម្លៃអប់រំនៃរឿងខាងលើ ?

☐ ១. ត្រូវជិះទូកកម្សាន្តមើលត្រីផ្សោត ។

☐ ២. ត្រូវខិតខំអភិរក្សត្រីផ្សោត ។

☐ ៣. ត្រូវខំទាញយកប្រយោជន៍ពីត្រីផ្សោត ។

# កិរិយាសកម្ម

ចូរអានល្បះខាងក្រោមនេះ និងសង្កេតមើលពាក្យអក្សរដិត ។

១. មីងសំប្រឡាក់ត្រី ។

២. ពួកគេធ្វើផ្អក ប្រហុក ត្រីងៀត ។

៣. ពូប្រាក់នេសាទត្រីនៅបឹងទន្លេសាប ។

៤. ប្រជាជនយើងបរិភោគត្រីច្រើនជាងសាច់ ។

៥. ខ្ញុំចូលចិត្តបង្គាស្រស់ជាងបង្គាក្រៀម ។

៦. ហ្វូងត្រីចឹកចំណីនៅក្នុងទឹក ។

៧. ពូសុខបបួលខ្ញុំទៅចាប់ក្ដាម ។

ពាក្យ“ ប្រឡាក់ ធ្វើ នេសាទ បរិភោគ ចូលចិត្ត ចឹក បបួល ” ក្នុងល្បះខាងលើបង្ហាញអំពើ ។ វាជា “ កិរិយា ” ។ កិរិយាទាំងនេះមាននាម កន្សោមនាម ឬសព្វនាមនៅជាប់ខាងស្ដាំ ។ កិរិយាទាំងនេះហៅថា “ កិរិយាសកម្ម ” ។ ពាក្យ “ ត្រី ផ្អក ប្រហុក ត្រីងៀត ត្រី បង្គា ចំណី ខ្ញុំ ” ដែលនៅខាងស្ដាំកិរិយាជា “ កម្មបទផ្ទាល់ ” ។

> កិរិយាសកម្ម ជាកិរិយាដែលមាននាម កន្សោមនាម ឬសព្វនាម នៅជាប់ខាងស្ដាំ ឬជាកិរិយាត្រូវការកម្មបទផ្ទាល់ ។

## លំហាត់

ក. ចូរស្រង់កិរិយាសកម្មនៅក្នុងល្បះខាងក្រោម ៖

១. ជីដូនខ្ញុំពិសាបាយជាមួយត្រីប្រៃ ។

២. សំនិងសានស្ទូចត្រី ។

៣. ពូសៅជួសមង ។

៤. ពួកគេទិញឧបករណ៍នេសាទ ។

៥. ពួកគេការពារព្រៃលិចទឹក ។

៦. ពូសានចិញ្ចឹមត្រីប្រាក្នុងស្រះក្បែរផ្ទះ ។

៧. ឆ្នាំនេះមីងម៉ៅធ្វើប្រហុក ផ្អកបានច្រើន ព្រោះប្ដីគាត់ជាអ្នកនេសាទ ។

៨. គេអាំងមឹកធំៗនៅឆ្នេរសមុទ្រកែប ។

ខ. ចូររកកិរិយាសកម្មនៅក្នុងចំណោម កិរិយាខាងក្រោម ៖

ទិញ ស្ទូច យំ លក់ នេសាទ រុត រងារ ចាប់ កាប់ ព្រុស ធ្វើ មើល ភ្ជួរ ។

គ. ចូររកកិរិយាសកម្មឱ្យបាន១០ពាក្យក្រៅពីកិរិយាសកម្មខាងលើ ។



## រឿង សុបិនចម្លែក



ស្លេះនិងម៉ារីណា ជាបងប្អូនបង្កើត រស់នៅក្នុងភូមិមួយជិតបឹងធំ ។ ពួកគេប្រកបរបរលក់ត្រីនៅតាមភូមិជាច្រើនឆ្នាំមកហើយ ។ ក្រោយមក មុខរបររបស់ពួកគេជួបការលំបាក ដោយសារអ្នកនេសាទចេះតែតម្លើងថ្លៃត្រីឥតឈប់ឈរ ។ ហេតុនេះ ស្លេះសម្រេចចិត្តនេសាទត្រីខ្លួនឯងវិញ ។

ល្ងាចមួយ ស្លេះប្រាប់ប្អូនស្រីឱ្យរកម្ហូបអាហារទុកបម្រុងយកទៅនេសាទនៅព្រឹកស្អែក រួចក៏និទ្រាលក់ទៅ ។ យប់នោះ ស្លេះយល់សប្តិឃើញថា ខ្លួនគេរកត្រីមិនបានសោះពេញមួយថ្ងៃ ។ លុះដល់ពេលជិតត្រឡប់មកវិញ ស្រាប់តែគេបង់សំណាញ់បានត្រីធំមួយ ។ គេដោះត្រីចេញពីសំណាញ់ដោយត្រេកអរពន់ពេក ស្រាប់តែត្រីនោះនិយាយមករកគេ ៖ " សូមអ្នកដោះលែងខ្ញុំទៅ ! ខ្ញុំជាស្តេចត្រីហើយកំពុងមានពងពេញពោះទៀតផង ។ បើអ្នកទុកជីវិតឱ្យខ្ញុំ ខ្ញុំនឹងបញ្ជូនកូនចៅខ្ញុំមកឱ្យអ្នកបរិភោគរាល់ថ្ងៃ អ្នកមិនបាច់បារម្ភទេ" ។ ឮសម្តីត្រីអង្វរ ស្លេះលើកត្រីបម្រុងលែងទៅក្នុងទឹកវិញ តែម៉ារីណាស្រែកឃាត់ ៖ " បងឆ្កួតទេឬ យើងចំណាយកម្លាំងមួយថ្ងៃ ទើបបានត្រីមួយនេះ ហេតុអ្វីក៏បងចង់លែងត្រីទៅវិញ ? ត្រីពងបែបនេះឆ្ងាញ់ណាស់ ហើយលក់ក៏បានថ្លៃណាស់ដែរ ។ កុំលែងវាអី !" ។ ស្លេះរារែកក្នុងចិត្ត ហើយទីបំផុតក៏លើកត្រីដាក់ក្នុងទូក រួចនាំបងប្អូនត្រឡប់មកគេហដ្ឋានវិញ ។

មកដល់ផ្ទះ ម៉ារីណាកាត់ត្រីទុកខ្លះសម្រាប់ហូប ហើយត្រីនៅសល់នាងយកទៅលក់បានប្រាក់យ៉ាងច្រើន ។ នាងសប្បាយចិត្តណាស់ ។ ថ្ងៃបន្ទាប់ ម៉ារីណាចាប់ផ្តើមក្តៅខ្លួន ។ ស្លេះរត់រកពេទ្យមកព្យាបាលប្អូនតែមិនធូរស្រាលសោះ ។ ក្រោយមក ម៉ារីណាក៏ធ្លាក់ខ្លួនឈឺធ្ងន់ ។ ស្លេះភ័យពេកស្រែកយំយ៉ាងខ្លាំង រហូតដល់ភ្ញាក់ដឹងខ្លួនវិញ ។

ស្អែកឡើង ស្លេះនិយាយរឿងប្រាប់អ្នកនេសាទម្នាក់ ។ បុរសនោះនិយាយថា នេះប្រហែលជាប្រផ្នូលរារាំងស្លេះមិនឱ្យទៅរកត្រីហើយ ព្រោះរដូវនេះជារដូវត្រីពង គេហាមមិនឱ្យនេសាទទេ ព្រោះនាំឱ្យពាយត្រី ។ បើគេចង់នេសាទ ត្រូវរង់ចាំឱ្យផុតរដូវត្រីពងសិន ដើម្បីឱ្យមច្ឆជាតិនៅតែសម្បូរជារៀងរហូត ។ ស្លេះយល់ហើយ ក៏ត្រឡប់មកផ្ទះវិញរង់ចាំឱកាសមកដល់គេនឹងទៅនេសាទ ។

## សំណួរ

១. តើស្លេះប្រកបមុខរបរអ្វី ?

២. តើមានរឿងអ្វីកើតឡើងចំពោះស្លេះ ?

៣. ហេតុអ្វីបានជា គេមិនឱ្យនេសាទនៅរដូវត្រីពង ?

៤. តើរឿងនេះមានព្រឹត្តិការណ៍ប៉ុន្មាន ? គឺអ្វីខ្លះ ?

## លំហាត់

ក. ចូរស្រង់កិរិយាសកម្មនៅក្នុងអត្ថបទឱ្យបានចំនួន៥ ។

ខ. ចូរស្រង់ពាក្យដែលមានន័យដូចគ្នា នៅក្នុងអត្ថបទខាងលើ ។

គ. ចូរបង្ហាញតម្លៃអប់រំនៃរឿងនេះ ។

ឃ. ចូររកពាក្យសូរដូចនឹងពាក្យ “ ក៏ ជា ” ។

ង. ចូររកពាក្យផ្ទុយនឹងពាក្យ ៖ តម្លើង ត្រេកអរ ស្លាប់ សម្បូរ ។

## សំណេរ

ចូរមើលរូបភាពខាងក្រោម រួចតែងកំណាព្យខ្លី ១វគ្គ បទពាក្យប្រាំពីរ ឬ បទកាកគតិ ។



# ការរៀបរាប់ពីធនធានជលផល

ធារ៉ានិងធីតាបានរៀបរាប់អំពីធនធានជលផលដែលមាននៅក្នុងតំបន់របស់គេ ។ ចូរអានការរៀបរាប់ខាងក្រោម ។





ខ្ញុំរស់នៅខេត្តព្រះសីហនុ ។ ទីនោះជាតំបន់សមុទ្រ ។ នៅសមុទ្រសម្បូរក្តាម បង្គា មឹក ងាវ ខ្យង គី បបែល និងត្រីច្រើនប្រភេទទៀត ។ ត្រីសមុទ្រមានរសជាតិឆ្ងាញ់ណាស់ ។

ខ្ញុំរស់នៅតាមដងទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង ។ នៅខេត្តនេះមានត្រីទឹកសាបច្រើនប្រភេទ ក្នុងនោះមានត្រីឥតស្រកា និងត្រីមានស្រកា ។ ត្រីទឹកសាបដែលមានរសជាតិឆ្ងាញ់ហើយមានតម្លៃថ្លៃ គឺត្រីឆ្ដោក ត្រីសណ្តាយ ត្រីគ្រំ ត្រីព្រួល ត្រីព្រលូង... ។ ចំណែកត្រីដែលមានរសជាតិឆ្ងាញ់បំផុត គឺត្រីប៉ាសេអ៊ី ។ ក្រៅពីត្រីទាំងនេះ បង្កងទឹកសាបក៏មានរសជាតិឆ្ងាញ់មិនចាញ់ត្រីប៉ាសេអ៊ីឡើយ ។ ត្រីដែលមានមាឌធំជាងគេបង្អស់ដែលគេចាត់ទុកថាជាស្តេចត្រីក្នុងទន្លេ គឺត្រីរាជ ។





## លំហាត់

ចូរអ្នករៀបរាប់ពីធនធានជលផលដែលមាននៅក្នុងភូមិ ស្រុករបស់អ្នក ប្រាប់មិត្តរួមថ្នាក់ឱ្យបានក្បោះក្បាយ ។

# ការរៀបរាប់ឡើងវិញព្រឹត្តិការណ៍មួយក្នុងរឿង

នៅក្នុងរឿងសុបិនចម្លែកមានព្រឹត្តិការណ៍ចំនួន៤ ៖

១. ស្លេះនិងម៉ារីណាប្រកបមុខរបរលក់ត្រីនៅតាមភូមិ ។

២. ស្លេះប្រាប់ប្អូនស្រីឱ្យរកម្ហូបអាហារទុកយកទៅនេសាទ ។

៣. ស្លេះយល់សប្តិចាប់បានស្តេចត្រី ។

៤. ស្លេះយករឿងយល់សប្តិប្រាប់អ្នកនេសាទម្នាក់ ។

ខាងក្រោមនេះជាការសរសេរព្រឹត្តិការណ៍ទី៣ នៃរឿងសុបិនចម្លែកឡើងវិញ ។ ចូរអ្នកអានហើយកត់ចំណាំពាក្យពេចន៍ដែលគេបានប្រើដើម្បីបង្ហាញ ការសរសេរឡើងវិញដោយផ្តល់ទស្សនៈរបស់តួអង្គណាមួយនៅក្នុងព្រឹត្តិការណ៍នោះ ។

## ព្រឹត្តិការណ៍មួយនៃរឿងសុបិនចម្លែក

បន្ទាប់ពីសម្រេចចិត្តប្រកបរបរនេសាទ ស្លេះដេកយល់សប្តិឃើញថាវាចាប់បានស្តេចត្រីមួយដែលកំពុងមានពង ។ ស្តេចត្រីនោះ បានអង្វរស្លេះឱ្យដោះលែងវាទៅវិញ ដោយធានាថានឹងផ្តល់ត្រីឱ្យស្លេះរាល់ថ្ងៃ ។ ស្លេះរៀបនឹងលែងត្រីទៅវិញ ស្រាប់តែប្អូនស្រីរបស់គេបានស្រែកឃាត់ មិនឱ្យគេលែងត្រីនោះទេ ។ មកដល់ផ្ទះ នាងយកត្រីនោះទៅលក់ ហើយកាត់ត្រីទុកខ្លះសម្រាប់បរិភោគ ។ ស្អែកឡើងនាងចាប់ផ្តើមឈឺ ស្លេះភ័យនឹងប្អូនខ្លាំង ក៏យំរហូតដឹងខ្លួន ។ ស្លេះបាននិយាយរឿងនេះ ប្រាប់អ្នកជិតខាងម្នាក់ ។ បុរសនោះកាត់យល់ថា ប្រហែលជាស្លេះគិតច្រើនពេកទើបយល់សុបិនបែបនេះ ។ ម្យ៉ាងទៀត ពេលដែលស្លេះយល់សប្តិ ជារយៈពេលដែលគេមិនការនេសាទ ដើម្បីឱ្យត្រីពង និងបន្តពូជឱ្យបានច្រើន ។ បើគ្មានរឿងយល់សប្តិនេះ ស្លេះនឹងទៅនេសាទហើយសមត្ថកិច្ចខាងជលផលនឹងចាប់ផាកពិន័យស្លេះជាមិនខាន ។

## សំណួរ

១. តើតួអង្គណាបានផ្ដល់ទស្សនៈ ឬការយល់ឃើញនៅក្នុងព្រឹត្តិការណ៍នៃរឿងនេះ ?

២. តើតួអង្គនោះផ្ដល់ទស្សនៈដូចម្ដេចខ្លះ ?

## លំហាត់

ក. ចូរជ្រើសរើសរឿងណាមួយដែលអ្នកពេញចិត្ត ឬធ្លាប់ចងចាំ ឬរឿងដែលអ្នកទើបនឹងតែង ហើយរកព្រឹត្តិការណ៍ទាំងអស់នៃរឿងនោះ ។

បន្ទាប់មក ចូរអ្នកជ្រើសរើសព្រឹត្តិការណ៍មួយនៃរឿងនោះ ហើយសរសេរឡើងវិញ ហាក់ដូចជាតួអង្គណាមួយផ្ដល់ទស្សនៈ ឬការយល់ឃើញរបស់ខ្លួននៅក្នុងព្រឹត្តិការណ៍នោះ ។

នៅពេលសរសេរចប់ ចូរអានផ្នែកដែលអ្នកសរសេរឡើងវិញឱ្យសិស្សក្នុងថ្នាក់ ឬតាមក្រុមស្ដាប់ ។

ខ. ចូរអ្នកសរសេរអត្ថបទខ្លីមួយ រៀបរាប់អំពីធនធានជលផលនៅក្នុងភូមិស្រុក ឬខេត្តរបស់អ្នកដោយ ៖

- ប្រាប់ឈ្មោះ ភូមិស្រុក ឬខេត្តរបស់អ្នក
- រៀបរាប់អំពីជលផលដែលអ្នកបានដឹងនៅក្នុងភូមិស្រុកនោះ
- ការចូលរួមថែរក្សា ការពារធនធានទាំងនោះមិនឱ្យបាត់បង់ផុតពូជ ។

មេរៀនទី

# ៦ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ



ខ្មែរយើងមានទំនៀមទម្លាប់ដ៏ល្អផូរផង់ តាំងពីយូរលង់ណាស់មកហើយ ។ ប្រពៃណីទាំងនោះមានដូចជា ព្រះរាជពិធីផ្សេងៗ ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបូជាសព និងពិធីបុណ្យជាច្រើនទៀត ។ ពិធីទាំងនេះ ត្រូវបានប្រជាជនយើងគោរពយ៉ាងខ្ជាប់ខ្ជួន តាំងពីបុរាណកាលរហូតមកដល់បច្ចុប្បន្ន ។

ដូច្នេះយើងជាកូនខ្មែរ ត្រូវបន្តគោរព និងចូលរួមថែរក្សាទំនៀមទម្លាប់ប្រពៃណីទាំងនោះឱ្យបានគង់វង្ស ។

# ពាក្យសូរដូច

តាមរយៈការនិយាយ គេអាចស្តាប់ឮពាក្យខ្លះមានសូរដដែលៗ ។ តែបើគេពិនិត្យមើលសំណេរពាក្យនោះវិញ គេឃើញថា សំណេរនិងន័យរបស់វាពុំដូចគ្នាទេ ។

ចូរអានឧទាហរណ៍ខាងក្រោម ពាក្យមានគំនូសពីក្រោមជាពាក្យសូរដូច ៖

ឧទាហរណ៍ ៖

ប្រទេសកម្ពុជាយើងបានចាត់ទុក ថ្ងៃទី២៥ ខែវិច្ឆិកា ជាថ្ងៃកាន់ទុក្ខចំពោះអ្នកដែលបានទទួលមរណភាពជាងបីរយនាក់ក្នុងឧបទ្ទវហេតុដ៏គួរឱ្យរន្ធត់ នាឱកាសព្រះរាជពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែនៅលើស្ពានពេជ្រថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ទុក្ខ(ទុក)ន. : សេចក្តីព្រួយ សេចក្តីលំបាក ។

ទុក កិ. : ដាក់អ្វីៗនៅទីណាមួយឱ្យបានគង់នៅ ។

អ្នក(នាក់)សព្វ. : ពាក្យប្រើជំនួសបុគ្គលដែលត្រូវនិយាយទៅរកទីចំពោះមុខដោយមិនចេញឈ្មោះ ។

នាក់ : ពាក្យសម្រាប់ដាក់ខាងចុងគុណនាមចំនួន ដើម្បីឱ្យដឹងចំនួនមនុស្ស ។

ពាក្យ“ទុក” និង“ទុក្ខ” ជាពាក្យសូរដូច ។ ពាក្យ“ អ្នក” និង“នាក់”ជាពាក្យសូរដូចគ្នា ។

ពាក្យសូរដូចជាពាក្យពីរ ឬច្រើនដែលមានសូរដូចគ្នា តែសំណេរនិងន័យខុសគ្នា ។

## លំហាត់

ក. ចូររកពាក្យសូរដូចក្នុងល្បះខាងក្រោម រួចពន្យល់ន័យរបស់ពាក្យទាំងនោះ ។

១. ប្រាសាទអង្គរវត្ត មានកេរ្តិ៍ឈ្មោះល្បីល្បាញ ។ ប្រាសាទនេះ ជាកេរដំណែលពីបុរាណ ។

២. ក្របីឡើងក វាត់កន្ទុយ ដេញរឹចគ្នានៅក្នុងវត្ត ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ “ រថ គុម្ព ពោះ” ។

# ពិធីបំបួសនាគ



ក្នុងសម័យបុរាណ ខ្មែរយើងនិយមឱ្យកូនប្រុសបួសជាព្រះសង្ឃ ។ មុននឹងបួស គេត្រូវធ្វើពិធីមួយហៅថា ពិធីបំបួសនាគ ។ អ្នកបួសត្រូវរៀនធម៌ឱ្យចេះដឹងជាមុន ល្មមអាចសូត្របាននៅថ្ងៃបំបួសនាគ ។ ការបំបួសមិនកំណត់ពេលវេលាទេ តែចាំបាច់ត្រូវចៀសវាងពេលដែលព្រះសង្ឃចូលព្រះវស្សា ។ មុននឹងចូលដល់ថ្ងៃប្រារព្ធពិធី អ្នកដែលត្រូវគេបំបួសកាន់ទៀនធូបទៅជម្រាបលាញាតិសន្តាន ។

ក្នុងពិធីនេះ គេត្រូវធ្វើបាយសីពីដើមចេកមួយដើមមាន១៩ថ្នាក់ ។ នៅលើកំពូលបាយសីនោះ មានកន្ទោងស្លឹកចេកដាក់បាយ១៩ពំនូត ។ បាយសីរុំព័ទ្ធដោយស្លឹកចេកទាំងផាង និងរុំព័ទ្ធដោយសំពត់ហូលមួយជាន់ពីលើទៀតផង ។ តួបាយសី១៩ថ្នាក់នោះតំណាងរូបអ្នកបួស ។ អ្នកបួសត្រូវគិតពិចារណាខ្លួនថា ខ្លួនមនុស្សប្រៀបដូចដើមចេកគ្មានខ្លឹមទេ មានសុទ្ធតែទឹកនិងដី ដែលអាចរលាយក្នុងថ្ងៃណាមួយមិនខាន ។ ប៉ុន្តែការសាងកុសល គឺជាប្រការចាំបាច់ មានន័យនិងមានខ្លឹមសារសម្រាប់ខ្លួនឯងផង និងសង្គមផង ។

គេធ្វើពិធីបំបួសនាគចាប់ពីពេលរសៀល ។ លុះដល់ព្រឹកថ្ងៃបន្ទាប់ គេត្រូវដង្ហែនាគចេញពីផ្ទះទៅកាន់វត្ត ។ នាគជិះសេះ ឬគោ ស្លៀកសំពត់ងូតពីក្នុង ស្លៀកហូលពីក្រៅ មិនពាក់អាវទេ ពានាក្រមាពណ៌សព័ទ្ធឆៀងលើស្មាឆ្វេង ។ ក្បួនដង្ហែមានភ្លេងឆៃយ៉ាំនាំមុខ និងភ្លេងពិណពាទ្យពីក្រោយ ហែហមដោយញាតិមិត្ត ។ ក្បួនហែនាគនេះ ត្រូវហែប្រទក្សិណព្រះវិហារបីជុំសិន ទើបនាំគ្នាចូលទៅក្នុងព្រះវិហារ ។ ពួកនាគអង្គុយជាជួរតាមលំដាប់អាយុ ដោយមានចីវរនៅខាងមុខរៀងៗខ្លួន ។ នៅទីបញ្ចប់ នាគថយទៅស្លៀកស្បង់ចីវរតាមច្បាប់វិន័យ ។ បន្ទាប់មក នាគកាន់ទៀនធូបចូលទៅថ្វាយបង្គំព្រះឧបជ្ឈាយ៍ ។ ព្រះគ្រូឧបជ្ឈាយ៍សូត្រប្រៀនប្រដៅវិន័យសង្ឃដល់នាគ ។

## សំណួរ

១. តើអ្នកបួសត្រូវធ្វើអ្វីខ្លះ មុននឹងបួស ?
២. តើគេត្រូវរៀបចំសម្ភារៈអ្វីខ្លះ សម្រាប់ពិធីបំបួសនាគ ?
៣. តើគេធ្វើពិធីអ្វីខ្លះ ក្នុងដំណើរការបំបួសនាគ ?
៤. តើគេត្រូវរៀបចំនិងធ្វើដូចម្ដេចខ្លះ នៅក្នុងពិធីដង្ហែនាគពីផ្ទះទៅវត្ត ?
៥. តើគេធ្វើដូចម្ដេចខ្លះ នៅចុងបញ្ចប់នៃពិធីបំបួសនាគ ?
៦. តើគេបួសដើម្បីអ្វី ?

## លំហាត់

ក. ចូររកពាក្យសូរដូចនឹងពាក្យទាំងនេះ “ ជួរ សង្ឃ ទេ ” ។
ខ. ចូរពន្យល់ពាក្យ “ នាគ ប្រទក្សិណ ចីវរ ” ដោយប្រើវចនានុក្រម ។
គ. ចូររៀបបណ្ដាពាក្យឱ្យបានជាឃ្លាត្រឹមត្រូវ ។

| | | | | | | |
|---|---|---|---|---|---|---|
| ១. | ដើមចេក | អ្នកបួស | ត្រូវ | ខ្លួនមនុស្ស | ប្រៀបដូច | គិតថា |
| ២. | គេ | ត្រូវ | ទៅកាន់ | ទីវត្ត | នាគ | ដង្ហែ |

# ១ តួនាទីនៅក្នុងអង្គប្រជុំផ្លូវការ



## សំណួរ

១. តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាព ?

២. តើគេត្រូវបែងចែកតួនាទីសមាជិកក្រុមដូចម្ដេចខ្លះ នៅក្នុងការប្រជុំផ្លូវការ ?

៣. តើប្រធានក្រុមធ្វើអ្វីខ្លះ ?

៤. តើលេខាមានភារកិច្ចអ្វីខ្លះ ?

៥. តើសមាជិកក្រុមមានភារកិច្ចអ្វីខ្លះ ?

៦. ដើម្បីឱ្យអង្គប្រជុំមួយមានដំណើរការល្អ តើសមាជិកក្រុមត្រូវធ្វើដូចម្ដេចខ្លះ ?

៧. តើអ្នកចូលរួមក្នុងអង្គប្រជុំនេះមានឈ្មោះអ្វីខ្លះ ?

## 🔑 សញ្ញាវង់ក្រចក ( ... )

នៅក្នុងសំណេរភាសាខ្មែរយើង មានប្រើប្រាស់សញ្ញាវង់ក្រចក ។ តើគេប្រើប្រាស់សញ្ញាវង់ក្រចកយ៉ាងដូចម្ដេច ? ចូរអានឧទាហរណ៍ខាងក្រោម ៖

១. អ្នកស្រុកកំពង់លែង តែងធ្វើពិធីបំបួសនាគ (បំបួសកូនប្រុសជាសង្ឃ) ជារៀងរាល់ឆ្នាំ ។

២. បើយើងឱ្យត្រីទៅមនុស្សម្នាក់ អ្នកនោះពិសាបានតែមួយថ្ងៃ បើយើងបង្រៀនអ្នកនោះឱ្យចេះស្ទូចត្រី អ្នកនោះនឹងពិសាបានមួយជីវិត (ប៉ាស្កាល់) ។

៣. ខ្លះជឿបុណ្យខ្លាំង យួរម្ហូបទាំងឆ្នាំង យកទៅវត្តវ៉ា

ម៉ែឪអត់ឃ្លាន ចង់បានណាស់ណា ភ្លយសួរកូនថា

មានសល់ឬទេ ។

ព្រឹកឡើងឃ្លានបាយ ញ័រពោះញើសខ្វាយ ឃើញសម្លគេ

កូនឆ្លើយរឹងថ្កាន មិនបានសល់ទេ ខ្ញុំស្លគ្រាន់តែ

ទៅវត្តទេឪ ។

(ដកស្រង់ចេញពីច្បាប់គោរពមាតាបិតារបស់លោកអ៊ូ ចុង)

នៅក្នុងឧទាហរណ៍នីមួយៗខាងលើ យើងសង្កេតឃើញថា ៖

- ឧទាហរណ៍ទី ១ ៖ ពាក្យក្នុងវង់ក្រចក ( បំបួសកូនប្រុសជាសង្ឃ ) ប្រើសម្រាប់ បញ្ជាក់សេចក្ដីនៃពាក្យ “ បំបួសនាគ” ។
- ឧទាហរណ៍ ទី ២ ៖ ពាក្យក្នុងវង់ក្រចក (ប៉ាស្កាល់ )ប្រើសម្រាប់ប្រាប់ឈ្មោះអ្នកនិពន្ធ ។
- ឧទាហរណ៍ទី ៣ ៖ ពាក្យក្នុងវង់ក្រចក (ដកស្រង់ចេញពីច្បាប់គោរពមាតាបិតារបស់លោកអ៊ូ ចុង) ប្រើសម្រាប់បញ្ជាក់ពីប្រភពអត្ថបទ ។

សញ្ញាវង់ក្រចក(...)សម្រាប់ដាក់អមពាក្យ ឬល្បះ ដើម្បីប្រាប់សេចក្ដីបន្ថែម ឬគំនិតបន្ថែមលើពាក្យ ឬល្បះដែលនៅខាងឆ្វេងវង់ក្រចក និងសម្រាប់ប្រាប់ពីអ្នកនិពន្ធឬប្រភពអត្ថបទ ។

លំហាត់

ក. ចូរប្រើសញ្ញាវង់ក្រចកក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ខ្មែរយើងតែងធ្វើពិធីក្រុងពាលី ពិធីសែនព្រេន មុនពេលសាងសង់សំណង់ផ្សេងៗ ។

២. ខ្ញុំដឹងតែមួយមុខ គឺខ្ញុំគ្មានចេះអ្វីទាំងអស់ សូក្រាត ។

៣. លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា
ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា
ឆ្កួតក្រៃកន្លង ។
ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង
លោកកុំឱ្យសេព ឱ្យវៀរជាម្ដង វាតែងឱ្យហ្មង
ភ្លេចភ្លាំងស្មារតី ។

ដកស្រង់ចេញពីច្បាប់កូនចៅ

ខ. ចូរតែងល្បះដោយប្រើសញ្ញាវង់ក្រចកឱ្យបានបីល្បះ ។



## រឿង ទំនៀមទម្លាប់ដាក់ប្រាក់កាក់ក្នុងមាត់អ្នកស្លាប់



មានរឿងបុរាណតំណាលតៗគ្នាថា មានបុរសម្នាក់នៅជាមួយប្រពន្ធតាំងពីក្មេង រហូតដល់ចាស់ គ្មានកូនមួយសោះ ។ គាត់មានមាសមួយបាត ។ ប្ដីប្រពន្ធនេះ បានសន្យាគ្នាថា បើអ្នកណាស្លាប់មុនត្រូវយកមាសនេះ ដាក់ក្នុងមាត់អ្នកនោះ ។ ចំណេរកាលមិនយូរប៉ុន្មាន ប្ដីបានស្លាប់មុនទៅ ។ ភរិយាក៏យកមាសនោះទៅដាក់ក្នុងមាត់ប្ដី ហើយយកសពប្ដីទៅបូជា ។ ភ្លើងឆេះមាសរលាយអស់នៅសល់តែបីស្លឹង ។

ថ្ងៃមួយ ព្រះមហាក្សត្របានត្រាស់បង្គាប់ឱ្យរៃអង្គាសមាសក្នុងមួយផ្ទះឱ្យបានមួយបាតជាកំហិត ។ ប្រពន្ធរបស់ខ្មោចនោះ ក៏យកមាសបីស្លឹងដែលគាត់រើសទុកនោះ ទៅថ្វាយស្ដេច ។ គាត់ទូលស្ដេច ៖ " ក្រាបទូលព្រះករុណា ! មាសនេះពីដើមពេញមួយបាត តែខ្ញុំម្ចាស់បានយកទៅបង់មាត់ឱ្យប្ដីខ្ញុំម្ចាស់នៅពេលគាត់ស្លាប់ ក៏ត្រូវភ្លើងឆេះអស់នៅសល់តែប៉ុណ្ណឹង ។ សូមព្រះករុណា មេត្តាដល់សត្វទ័លក្រផងចុះ ។ ខ្ញុំម្ចាស់មិនអាចរកមាសមកថ្វាយព្រះអង្គបានឡើយ" ។ ព្រះមហាក្សត្រទ្រង់ស្ដាប់ហើយ ក៏កើតក្ដីសង្វេគស្លុតព្រះទ័យ ទើបទ្រង់លើកលែងការរៃយកមាសពីបណ្ដារាស្ត្រតទៅទៀត ។

អាស្រ័យរឿងនេះ ទើបបណ្ដារាស្ត្រទាំងអស់យល់ថា ប្រាក់ ឬមាសដែលបង់ក្នុងមាត់ខ្មោច មានអានុភាពទៅលើទឹកចិត្តមនុស្សណាស់ សូម្បីព្រះមហាក្សត្រក៏ចុះចាញ់អានុភាពនេះដែរ ។ ម្យ៉ាងទៀត អានុភាពនៃប្រាក់ ឬមាសបង់មាត់ខ្មោចនេះ ជាវត្ថុស័ក្តិសិទ្ធិអាចជួយរំដោះគ្រោះថ្នាក់ ក្នុងពេលមានអាសន្នបាន ។ ហេតុដូច្នេះហើយ ទើបគេនាំគ្នាធ្វើរបៀបនេះ រហូតកើតទៅជាទំនៀមទម្លាប់តរៀងមក ។

ប៉ុន្តែអ្នកប្រាជ្ញបុរាណ ឱ្យយកប្រាក់ ឬមាសទៅដាក់ក្នុងមាត់ខ្មោច ដើម្បីធ្វើជាប្រស្នាឱ្យពិចារណាថា យើងមិនអាចយករបស់អ្វីមួយជាប់នឹងខ្លួនបានទេ នៅពេលដែលយើងស្លាប់ទៅ ។

(ដកស្រង់និងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ៩)

## សំណួរ

១. តើរឿងនេះមានតួអង្គណាខ្លះ ?

២. តើប្ដីប្រពន្ធបានសន្យាគ្នាដូចម្ដេច ?

៣. តើព្រះមហាក្សត្រត្រាស់បង្គាប់ដូចម្ដេច ?

៤. ហេតុអ្វីបានជាព្រះមហាក្សត្រឈប់រៃអង្គាសមាសពីប្រជារាស្ត្រ ?

៥. តើប្រជារាស្ត្រ មានជំនឿដូចម្ដេចចំពោះការយកប្រាក់ ឬមាសទៅបង់នឹងមាត់ខ្មោច ?

៦. តើអ្នកប្រាជ្ញបុរាណចង់អប់រំដូចម្ដេច ?

## លំហាត់

ក. ចូររកពាក្យន័យដូចនឹងពាក្យទាំងនេះ ៖ ព្រះមហាក្សត្រ ភរិយា ព្រះទ័យ សព ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យទាំងនេះ រួចប្រើវចនានុក្រមដើម្បីពន្យល់ន័យផង ៖ បាត សព ។

## ការបញ្ចេញមតិ

ថ្ងៃមួយ សិស្សថ្នាក់ទី៦ មួយក្រុម បានពិភាក្សាគ្នាអំពីទស្សនៈ “ ត្រូវប្រកាន់ឥរិយាបថល្អនៅពេលចូលរួមពិធីបុណ្យផ្សេងៗ” ។ ចូរអានការសន្ទនាខាងក្រោម ។

ប្រធានអង្គប្រជុំ : ថ្ងៃនេះ យើងពិភាក្សាគ្នាអំពីទស្សនៈមួយគឺ ត្រូវប្រកាន់ឥរិយាបថល្អនៅពេលចូលរួមក្នុងពិធីបុណ្យផ្សេងៗ ។ តើមិត្តទាំងអស់យល់យ៉ាងណាដែរ ? បូរីធ្វើជាលេខាសម្រាប់កត់ត្រាយោបល់មិត្តយើងទាំងអស់គ្នាឱ្យបានសព្វគ្រប់ ។

ស្រីនាង : ទស្សនៈដែលថា " ត្រូវប្រកាន់ឥរិយាបថល្អនៅពេលចូលរួមក្នុងពិធីបុណ្យ " មានន័យថាត្រូវស្លៀកពាក់ឱ្យបានសមរម្យ មិនត្រូវស្លៀកពាក់ខើចលើ ខើចក្រោម ឬពាក់មួកក្នុងពិធីបុណ្យនោះទេ ។

ណារិន : ខ្ញុំយល់ថា មិនត្រូវស្រែកឡូឡា ឬរត់ឆ្វេចឆ្វាច ប្រឡែងគ្នាធ្វើឱ្យរំខានគេឡើយ ។

ស្រីនាង : ខ្ញុំសូមបន្ថែមមួយចំណុចទៀត នៅពេលព្រះសង្ឃទេសនា ឬសូត្រមន្តយើងមិនត្រូវនៅខាងក្រៅនោះទេ យើងត្រូវអង្គុយបត់ជើងសំពះ និងសូត្រធម៌ជាមួយចាស់ៗដែរ ។

ចំរ៉ុង : ទស្សនៈនេះត្រឹមត្រូវណាស់ ពីព្រោះថាប្រសិនបើអ្នកចូលរួមពិធីបុណ្យប្រកាន់ឥរិយាបថនេះបាន ពិតជាមនុស្សថ្លៃថ្នូរគោរពទំនៀមទម្លាប់ខ្មែរបានល្អ ។

ប្រធានអង្គប្រជុំ : ឆ្លងតាមការពិភាក្សានេះ ឃើញថាគ្នាយើងបានបញ្ចេញមតិល្អៗច្រើន ។ ខ្ញុំសូមធ្វើការបូកសរុបដូចតទៅនេះ ៖ នៅពេលចូលរួមពិធីបុណ្យប្រពៃណីខ្មែរ អ្នកចូលរួមត្រូវស្លៀកពាក់ឱ្យបានសមរម្យ ប្រកាន់អាកប្បកិរិយារម្យទមនិងចូលរួមក្នុងពិធីជាមួយចាស់ៗបើអាចធ្វើបាន ។

## លំហាត់

ចូរធ្វើការពិភាក្សាក្នុងក្រុមតូចអំពីទស្សនៈមួយ"មិនត្រូវសើចសប្បាយនៅពេលចូលរួមក្នុងពិធីបុណ្យសព" ។

ក្នុងការពិភាក្សាត្រូវរៀបចំដូចខាងក្រោម ៖

- ជ្រើសរើសប្រធាននិងអ្នកកត់ត្រា
- ធ្វើការពិភាក្សាផ្តល់យោបល់ទាំងអស់គ្នា
- អ្នកកត់ត្រាត្រូវរាយការណ៍ដល់ក្រុម អំពីចំណុចសំខាន់ៗដែលបានកត់ ។

# ការពណ៌នាអំពីពិធីផ្សេងៗ

## ក. ការសិក្សាឧទាហរណ៍

### ពិធីបុណ្យ៧ថ្ងៃ

តាមទំនៀមទម្លាប់ខ្មែរ ក្រោយពីនរណាម្នាក់បានទទួលមរណភាពគម្រប់៧ថ្ងៃ គ្រួសារសព តែងតែនាំគ្នាធ្វើពិធីបុណ្យមួយហៅថា " បុណ្យ៧ថ្ងៃ" ដើម្បីឧទ្ទិសកុសល ជូនអ្នកដែលទើបនឹងស្លាប់ទៅនោះ ។

មុនថ្ងៃចាប់ផ្ដើមធ្វើពិធីបុណ្យ អ្នកផ្ដើមបុណ្យបានអញ្ជើញភ្ញៀវជិតឆ្ងាយឱ្យមកចូលរួមក្នុងពិធីបុណ្យ ។ អ្នកខ្លះទៀត ទៅទិញសម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យ ។ លុះដល់ព្រឹកថ្ងៃចាប់ផ្ដើមពិធី គេឃើញបងប្អូនញាតិមិត្តមកជួយរៀបចំសង់រោង បោសសម្អាត និងតុបតែងកន្លែងរៀបចំពិធី ។

លុះវេលារសៀល ជាពេលប្រារព្ធពិធីបុណ្យ អ្នកផ្ដើមបុណ្យបានមកឈរនៅខាងមុខរោង ដើម្បីរង់ចាំទទួលភ្ញៀវ ។ ពេលនេះ មានភ្ញៀវយ៉ាងច្រើនកុះករប្រកបដោយសម្លៀកបំពាក់សមរម្យតាមប្រពៃណីខ្មែរ មកចូលរួមក្នុងពិធីបុណ្យ ។ នៅពេលភ្ញៀវមកដល់ អ្នកផ្ដើមបុណ្យលើកដៃសំពះទទួល រីឯភ្ញៀវក៏លើកដៃសំពះតបវិញប្រកបដោយឥរិយាបថទន់ភ្លន់ ។ ភ្ញៀវទាំងអស់បាននាំមកនូវបច្ច័យនិងសម្ភារៈផ្សេងៗ សម្រាប់ចូលបុណ្យនិងពិសាភោជនាហារ ។

ក្រោយពីពិសាភោជនាហាររួច ភ្ញៀវខ្លះក៏ត្រឡប់ទៅលំនៅដ្ឋានវិញ ឯភ្ញៀវខ្លះនៅចូលរួមក្នុងពិធីសូត្រមន្តនិងស្ដាប់ធម៌ទេសនា ។ វេលាល្ងាចព្រះសង្ឃនិមន្តមកសូត្រមន្តរួចសម្ដែងធម្មទេសនា ។ ព្រឹកឡើងជាថ្ងៃបង្ហើយបុណ្យ គេរៀបចំចង្ហាន់ប្រគេនព្រះសង្ឃធ្វើពិធីបង្សុកូលនិងឧទ្ទិសកុសលជូនអ្នកដែលបានស្លាប់ទៅ ។ នៅចុងបញ្ចប់ អ្នកផ្ដើមបុណ្យថ្លែងអំណរគុណចំពោះភ្ញៀវទាំងអស់ដែលបានចូលរួម ។ ឯភ្ញៀវក៏លាទៅលំនៅដ្ឋានរៀងៗខ្លួនវិញ ។

## ១. ការសិក្សាពីគម្រោងសំណេរបែបពណ៌នា

ក្នុងការសរសេរអត្ថបទពណ៌នា គេត្រូវសរសេររៀបរាប់ឱ្យបានល្អិតល្អន់ តាំងពីដើមរហូតដល់ចប់ ដោយរៀបចំគំនិតឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយ ។ ទម្រង់នៃសំណេរបែបពណ៌នានេះ ចែកចេញជាបីផ្នែកគឺ សេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់ ។

ចូរពិនិត្យគម្រោងខាងក្រោម ៖

### គម្រោងតែង

១. សេចក្ដីផ្ដើម

ពេលវេលា ទីកន្លែង ឈ្មោះពិធីបុណ្យ គោលបំណងនៃពិធីបុណ្យ

២. តួសេចក្ដី

មុនពេលចាប់ផ្ដើមពិធីបុណ្យ

- ការអញ្ជើញភ្ញៀវ
- ការរៀបចំផ្សេងៗ : ការបោសសម្អាត ធ្វើរោង ការតុបតែង

ពិធីបុណ្យ

- ការទទួលភ្ញៀវ
- ការសូត្រមន្តនិងសម្ដែងធម្មទេសនា
- ការវេរចង្ហាន់ប្រគេនព្រះសង្ឃនិងបង្សុកូល

ក្រោយពេលបុណ្យ

- ការថ្លែងអំណរគុណចំពោះភ្ញៀវ
- ការរៀបចំផ្សេងៗ

៣. សេចក្ដីបញ្ចប់

ចំណាប់អារម្មណ៍របស់អ្នកសរសេរចំពោះពិធីបុណ្យ ។

## លំហាត់

ចូរអ្នកសរសេរអត្ថបទពណ៌នាអំពីពិធីបុណ្យអ្វីមួយដែលអ្នកធ្លាប់បានចូលរួម ។

មេរៀនទី

# ៧ តន្ត្រីនិងសិល្បៈបុរាណ



ខ្មែរយើងមានតន្ត្រី និងរបាំច្រើនប្រភេទណាស់ ។ តន្ត្រីខ្មែរមានភ្លេងខ្មែរ ភ្លេងអារក្សភ្លេងមហោរី ភ្លេងឆៃយ៉ាំជាដើម រីឯរបាំប្រពៃណីខ្មែរដែលគេនិយមលេងមានរបាំត្រុដិរបាំគោះអង្រែ របាំឃីកេ របាំឆៃយ៉ាំ របាំក្ងោក ។ល ។ តន្ត្រីនិងសិល្បៈទាំងនេះបំពេអារម្មណ៍មនុស្សឱ្យរីករាយ បន្ទាប់ពីធ្វើការនឿយហត់ ឬញ៉ាំងឱ្យបរិយាកាសក្នុងពិធីបុណ្យផ្សេងៗឱ្យមានភាពអធិកអធម ។

នៅក្នុងរូបភាពខាងលើ តើមានឧបករណ៍ភ្លេងអ្វីខ្លះ ? តើរបាំនេះមានឈ្មោះអ្វី ?

# ការផ្ដល់ការណែនាំ

ដើម្បីបង្រៀនអ្នកណាម្នាក់ ឱ្យចេះធ្វើអ្វីមួយ អ្នកចាំបាច់ត្រូវផ្ដល់ការណែនាំដល់គេតាមរយៈសកម្មភាព ឬរូបភាព ទើបគេអាចធ្វើកិច្ចការនោះបាន ។ ក្នុងការផ្ដល់ការណែនាំគេប្រើពាក្យដំបូង បន្ទាប់មក បន្ទាប់មកទៀត និងចុងក្រោយ ឬទី១ ទី២ ទី៣... ។

ការណែនាំអាចធ្វើឡើងដោយការនិយាយផ្ទាល់មាត់ក៏បាន ដោយការសរសេរក៏បាន ។

ចូរពិនិត្យមើលការណែនាំអំពីការគូរផ្កាយ ខាងក្រោម ៖

- ដំបូង គូសរង្វង់មួយ រួចក្រិត ៥ ចំណុចលើរង្វង់ឱ្យមានចម្ងាយស្មើៗគ្នានិងសរសេរអក្សរ ក ខ គ ឃ ងនៅលើចំណុចក្រិតនោះ ។
- បន្ទាប់មក គូសបន្ទាត់ភ្ជាប់ពីចំណុច ក ទៅចំណុច គ រួច គ ទៅ ង ។
- បន្ទាប់មកទៀត គូសបន្ទាត់ភ្ជាប់ពីចំណុច ខ ទៅ ចំណុច ឃ រួចចំណុច ឃ ទៅចំណុច ក ។
- ទីបញ្ចប់ គូសបន្ទាត់ភ្ជាប់ពីចំណុច ខ ទៅ ចំណុច ង ។

តើការណែនាំនេះមានប៉ុន្មានជំហាន ? តើគេប្រើពាក្យអ្វីខ្លះ ដើម្បីបញ្ជាក់ពីលំដាប់នៃការណែនាំ ?

## លំហាត់

ចូរអានការណែនាំខាងក្រោម ៖

- តើការណែនាំនេះមានប៉ុន្មានជំហាន ?
  . ជំហានទី១ គេឱ្យធ្វើអ្វី ? ជំហានទី២ គេឱ្យធ្វើអ្វី ? ជំហានទី៣... ?
- តើការណែនាំនេះនិយាយអំពីអ្វី ?
  . ដំបូងលើកដៃឆ្វេងឡើងលើ បោះជើងស្ដាំទៅមុខ ។
  . បន្ទាប់មកដាក់ដៃឆ្វេងចុះរួចជីប ។
  . បន្ទាប់មកទៀតលើកដៃស្ដាំឡើង បោះជើងឆ្វេងទៅមុខ ។
  . ទីបញ្ចប់ដាក់ដៃស្ដាំចុះជីប រួចលើកដៃឆ្វេងឡើង បោះជើងស្ដាំទៅមុខ (សាដើម) ។

# របាំក្ងោក



របាំក្ងោក ជារបាំមួយប្រភេទដែលប្រជាជននៅខេត្តប៉ៃលិននិយមលេង ។ អ្នកសម្តែងរបាំនេះមានពីរនាក់ ម្នាក់ដើរតួក្ងោកប្រកបដោយសម្លៀកបំពាក់ និងពាក់ស្លាបដូចសត្វក្ងោក ហើយម្នាក់ទៀតដើរតួព្រានព្រៃដែលនៅដៃមានស្នា និងបំពង់ព្រួញព្យួរពីក្រោយខ្នង ។ កាលណាក្រុមរបាំស្លៀកពាក់តែងតួរួច គេមកជួបជុំគ្នានៅត្រង់កន្លែងដែលបានរៀបចំទុក ។ ដើម្បីសម្តែងរបាំនេះ អ្នកលេងត្រូវធ្វើតាមការណែនាំខាងក្រោម ៖

ដំបូង អ្នកវាយស្គរចាប់បន្លឺមុនគេ រួចវង់ភ្លេងទាំងមូលចាប់ប្រគំឡើងព្រមគ្នា ។

បន្ទាប់មក អ្នកដើរតួក្ងោកអង្គុយលុតជង្គង់នៅលើតុមួយខ្ពស់ ដៃទាំងពីរប្រណមទំនងជាកំពុងភាវនាធម៌ ។

បន្ទាប់មកទៀត ក្ងោកលោតចុះមកដី កាងដៃ ត្រដាងស្លាប ហើយបត់រលាស់មានសណ្ឋានដូចជាក្ងោកហើរ ជើងទាំងពីរលោតបន្តើរៗជាចង្វាក់រាំវែ្ឆលជុំវិញទីកន្លែង ។ យូរៗម្តងធ្វើជាលោតផ្អើលៗ កន្ត្រៀងផ្អង ឆ្វេង ស្តាំ ដៃរលាស់ បង់បោយ រេចុះ រេឡើងតម្រូវតាមចង្វាក់ភ្លេង ។

បន្ទាប់ពីនោះ ព្រានដើរលោតៗជាចង្វាក់រាំតាមភ្លេង ភ្នែកគន់រំពៃឆ្វេង ស្ដាំ ហើយធ្វើកាយវិការជាភ្ញាក់ ទុចង៉ក់ព្រោះឃើញក្ងោកនៅពីមុខ ។

បន្ទាប់ពីនោះមកទៀត ព្រានទាញស្នាមកដាក់លើស្មា ផ្ទៀងកម្ទាង ហើយហូតយកព្រួញមួយមកផ្គង សម្រួលលើចង្កូរស្នា បំបែរចុងតម្រង់ទៅរកក្ងោក ។ ព្រានធ្វើជាតម្លោះកៃឱ្យព្រួញធ្លាក់ទៅដី តែមិនត្រូវក្ងោកទេ ។ ព្រានស្ទុះស្មាដោយក្ដៅចិត្ត ព្រោះបាញ់មិនត្រូវក្ងោក រីឯក្ងោក នៅតែរេរាំធ្វើព្រងើយ ។

ទីបញ្ចប់ ព្រានឃើញក្ងោកភ្លេចខ្លួន ក៏លបបាញ់ក្ងោក តែព្រួញជ្រុះទៅដីដូចមុនទៀត ។ ព្រានបញ្ចេញកាយវិការអស់សង្ឃឹមសាជាថ្មី ។

ចំណែកភ្លេង ត្រូវផ្លាស់ប្ដូរបទតាមឆាករឿង ដូចជាពេលក្ងោកចេញពង់លើតុ ភ្លេងលេងចង្វាក់យឺតបង្គួសៗ ។ ពេលតួព្រានព្រៃចេញ ភ្លេងរោទិ៍យ៉ាងញាប់ គួរឱ្យរន្ធត់ដល់ពេលព្រានបាញ់ខុស ភ្លេងលេង ចង្វាក់ធម្មតា។

## សំណួរ

១. តើអត្ថបទខាងលើនិយាយអំពីអ្វី ?

២. តើការណែនាំក្នុងអត្ថបទនេះ មានប៉ុន្មានជំហាន ?

៣. តើជំហានទី១ ទី២ ទី៣... គេតម្រូវឱ្យសម្ដែងធ្វើអ្វីខ្លះ ?

## លំហាត់

ក. ចូរស្រង់គុណនាមចង្អុលនៅក្នុងអត្ថបទខាងលើ ។

ខ. ចូរស្រង់នាម និងកិរិយាឱ្យបានប្រាំពាក្យក្នុងមួយមុខ ។

គ. ចូររកពាក្យសួរដូចនឹងពាក្យ “គួរ” ។

# សារ៉ាវ៉ាន់



## សំណួរ

១. តើអត្ថបទនេះ និយាយអំពីអ្វី ?

២. តើក្បាច់រាំសារ៉ាវ៉ាន់ មានប៉ុន្មានជំហាន ?

៣. តើជំហានទី១ត្រូវធ្វើដូចម្ដេច ?

៤. តើជំហានទី២ត្រូវធ្វើដូចម្ដេច ?

៥. ជំហានបន្ទាប់មកទៀតត្រូវធ្វើដូចម្ដេច ?

៦. ជំហានចុងក្រោយត្រូវធ្វើដូចម្ដេច ?

7

## សព្វនាមសំណួរ

ចូរអានឧទាហរណ៍ខាងក្រោម ហើយរកសព្វនាមសំណួរនៅក្នុងល្បះនីមួយៗ ។

ឧទាហរណ៍ ៖

១. តើអ្នកណាជាអ្នកផ្ដើមធ្វើបុណ្យនេះ ?

២. តើនរណាខ្លះបានចូលរួមក្នុងពិធីបុណ្យនេះ ?

៣. តើអ្នកណាខ្លះចេះរាំ ?

៤. តើយើងត្រូវការអ្វីខ្លះ សម្រាប់ប្រគេនព្រះសង្ឃ ?

៥. តើមានអ្វីឱ្យខ្ញុំជួយទេ ?

៦. តើអ្នកចិញ្ចឹមស្អីខ្លះ ?

ពាក្យ“នរណាខ្លះ អ្នកណា អ្នកណាខ្លះ អ្វីខ្លះ អ្វី ស្អី” ជាសព្វនាមសំណួរ ។

> សព្វនាមសំណួរ ជាពាក្យសម្រាប់សួរអំពីមនុស្ស សត្វ វត្ថុ ។

សព្វនាមសំណួរមាន ៖

សម្រាប់មនុស្ស ៖ អ្នកណា នរណា អ្នកណាមួយ នរណាមួយ អ្នកណាខ្លះ នរណាខ្លះ ។

សម្រាប់សត្វ ៖ ស្អី ស្អីខ្លះ ។

សម្រាប់វត្ថុ ៖ អី អ្វី អ្វីមួយ អ្វីខ្លះ ។

### លំហាត់

ក. ចូររកសព្វនាមសំណួរនៅក្នុងល្បះខាងក្រោម ។

១. តើអ្នកណាខ្លះទៅមើលសិល្បៈយប់នេះ ?

២. តើអ្នកចូលចិត្តអ្វីខ្លះ ?

៣. តើឯងជាអ្នកណា ?

៤. តើឯងខំរៀនដើម្បីអ្វី ?

៥. តើសៀវភៅទាំងនេះជារបស់អ្នកណា ?

ខ. ចូរបង្កើតល្បះឱ្យបាន៣ដោយប្រើសព្វនាមសំណួរ ។

គ. ចូរបំពេញល្បះដោយប្រើសព្វនាមសំណួរ ។

១. តើគាត់ឱ្យរង្វាន់ទៅ... ?

២. តើ... ស៊ីស្មៅ ?

៣. តើលោកត្រូវការ... ?

៤. តើ... ចូលរួមក្នុងការសម្ដែងល្ខោននេះ ?

៥. តើវាជ្រុះបាត់... ?

## របាំត្រុដិ



របាំត្រុដិជារបាំប្រពៃណីមួយបែប ដែលគេឃើញមាននៅក្នុងខេត្តសៀមរាប និងនៅកន្លែងខ្លះដែលមានព្រំប្រទល់ជាប់នឹងខេត្តនេះ ។ តាមព័ត៌មានខ្លះថា របាំត្រុដិមានប្រភពបែបរឿងនិទានខ្លះថា របាំនេះមានប្រភពបែបជំនឿរបស់អ្នកស្រុកទៅវិញ ។ ទោះបីមានប្រភពពីណាក៏ដោយ ក៏របាំត្រុដិនៅតែមានរបៀបលេងដូចគ្នាដដែល ។ របាំនេះ

មានតួសម្តែងច្រើន ហើយតួសំខាន់ៗ មានតួប្រើស ទន្សោង ក្ងោក និងមានឧបករណ៍ភ្លេងជាច្រើនដូចជា កញ្ឆារ ចង្រ្កង់ដំបែ ចង្រ្កង់រ៉ូង ស្គរ ប៉ីពក ទ្រអ៊ូ ទ្រសោ និងដងសន្ទូចរីងគ្រឿងតុបតែងតួមានមុខត្លុក មកុដ ស្នែងប្រើស ស្នែងទន្សោង កន្ទុយក្ងោក ក្រចក ។ល ។

ពាក្យ " ត្រុដិ" ជាភាសាសំស្រ្កឹត ប្រែថា"ការផ្តាច់" គឺសំដៅការកាត់ផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ។ អាស្រ័យហេតុនេះ ទើបគេច្រើនលេងរបាំត្រុដិនៅពេលចូលឆ្នាំខ្មែរ ដើម្បីជូនពរសព្ទសាធុការជ័យមង្គលដល់អ្នកស្រុកក្នុងឱកាសចូលឆ្នាំថ្មី ។ ប៉ុន្តែពេលខ្លះ គេលេងរបាំនេះសុំទឹកភ្លៀង នៅពេលដែលក្នុងភូមិស្រុកជួបប្រទះគ្រោះរាំងស្ងួតផងដែរ ។

តាមការស្រាវជ្រាវបានបញ្ជាក់ថា របាំត្រុដិកើតចេញពីជនជាតិសំរែ ។ ជនជាតិនេះ ច្រើនរស់នៅក្បែរភ្នំគូលែន និងនៅភាគខាងជើងបឹងទន្លេសាប ។ សព្វថ្ងៃ ពួកសំរែបានរលាយចូលជាមួយនឹងខ្មែរ ហើយរស់នៅម្តុំអង្គរវត្ត ។ តាមពាក្យតំណាលពីសម័យបុរាណ វង់ត្រុដិរបស់ជនជាតិសំរែប្រារព្ធឡើងជារៀងរាល់ឆ្នាំ ដើម្បីថ្វាយព្រះពរសិរីសួស្តីជ័យមង្គលដល់ព្រះរាជាខ្មែរដែលគង់នៅក្រុងអង្គរ ។ ដូច្នេះ ហើយបានជាអ្នកស្រុកសៀមរាប តែងតែលេងរបាំនេះរហូតដល់សព្វថ្ងៃ ។

(សម្រួលពីរបាំប្រជាប្រិយរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)

## សំណួរ

១. តើរបាំត្រុដិមានប្រភពមកពីជនជាតិណា ? នៅក្នុងខេត្តណា ?

២. តើគេលេងរបាំត្រុដិនៅពេលណាខ្លះ ?

៣. តើគេលេងរបាំនេះដើម្បីអ្វី ?

៤. តើរបាំនេះមានតួសំខាន់ៗអ្វីខ្លះ ?

៥. តើមានឧបករណ៍អ្វីខ្លះនៅក្នុងរបាំត្រុដិ ?

## លំហាត់

ក. ចូរប្រាប់ន័យដូចរបស់ពាក្យនៅខាងដើមជួរ ដោយជ្រើសរើសចម្លើយមួយ ។

១. ត្រុជិ ៖

☐ ការភ្ជាប់ ☐ ការផ្តាច់ ☐ ការជូនពរ ។

២. ឧបករណ៍ ៖

☐ គ្រឿងចាំបាច់ ☐ គ្រឿងប្រើប្រាស់ ☐ គ្រឿងប្រកបផ្សំគ្នា ។

ខ. ចូរផ្គូផ្គងពាក្យមានន័យផ្ទុយគ្នាខាងក្រោម ។

| | |
|---|---|
| ១. មង្គល | ក. ស្លាប់ |
| ២. តួសំខាន់ | ខ. អពមង្គល |
| ៣. បុរាណ | គ . សម័យបច្ចុប្បន្ន |
| ៤. រស់ | ឃ. តួបន្ទាប់បន្សំ ។ |

គ. ចូររកពាក្យសូរដូចនឹងពាក្យ “សព្វ នៅ” ។

### សំណេរ

តើអ្នកស្គាល់ឧបករណ៍តន្ត្រីអ្វីខ្លះ ?

ចូរអ្នកគូរឧបករណ៍តន្ត្រីដែលអ្នកពេញចិត្តឱ្យបានចំនួន ៣ រួចសរសេរឈ្មោះនៅខាងក្រោមរូបនីមួយៗ និងសរសេរអំពីរបៀបប្រើឧបករណ៍ទាំងនោះ ។

 ការផ្ដល់ការណែនាំ

សុខាបានគូររូបភាពងាយៗពីរ គឺរូបមុខមនុស្ស១ និងរូបផ្លែឈូក១ ។ សុខាបានលាក់រូបនោះ ហើយនាងប្រាប់សុភីឱ្យគូររូបនោះតាមការណែនាំរបស់នាង ។ ខាងក្រោមនេះ ជារូបភាពដែលនាងបានគូរ ។



រូបទី១



រូបទី២

សុខាបានផ្ដល់ការណែនាំដូចខាងក្រោម ៖

ដំបូង : គូររង្វង់មួយ ។ (រូបទី១)

បន្ទាប់មក : គូសគំនូសត្រង់មួយនៅក្នុងរង្វង់ ចម្ងាយ២ ភាគ ៣ពីផ្នែកខាងលើនៃរង្វង់ ។

ទីបញ្ចប់ : ដៅចំណុចពីរ នៅពីលើគំនូសត្រង់ ចំណុចទាំងពីរនេះ ត្រូវឱ្យឃ្លាតពីគ្នាបន្តិច ហើយមានចម្ងាយ១ភាគ ៣ ពីផ្នែកខាងលើនៃរង្វង់ ។

ដំបូង : គូររូបរាងពងក្រពើផ្ដេកមួយ ។ (រូបទី២)

បន្ទាប់មក : គូសបន្ទាត់ពីចុងសងខាងគំនូសពងក្រពើមកក្រោម

បន្ទាប់មកទៀត : គូសខ្សែស្រប ២ភ្ជាប់ពីចំណុចកណ្ដាលមកក្រោមឱ្យមានរាងកោង មកជួបគ្នាត្រង់ចំណុចកណ្ដាលមួយ ។

ទីបញ្ចប់ : ចុចចំណុចឱ្យបានច្រើននៅក្នុងរាងពងក្រពើ ។

នៅពេលសុភីគូររូបរួចរាល់ សុខាពិនិត្យការណែនាំឡើងវិញ ហើយសរសេរការណែនាំនោះឱ្យសុភីអាន ហើយធ្វើតាមម្ដងទៀត ។

## លំហាត់

ចូរអ្នកចាប់គូ ហើយម្នាក់ជាអ្នកគូររូបភាពងាយៗមួយ ឬពីរនៅលើក្រដាស រួចលាក់រូបនោះ កុំឱ្យដៃគូអ្នកឃើញ ។ បន្ទាប់មក អ្នកត្រូវផ្តល់ការណែនាំផ្ទាល់មាត់អំពីរូបភាពនោះ ឱ្យដៃគូអ្នកគូរតាម ។ នៅពេលដៃគូអ្នកគូររួច អ្នកត្រូវពិនិត្យមើលថា តើការណែនាំរបស់អ្នកត្រឹមត្រូវ ឬទេ ។ តមកទៀត អ្នកត្រូវសរសេរការណែនាំនោះ ហើយឱ្យដៃគូអាន ហើយធ្វើតាមម្តងទៀត ។

## ការណែនាំច្រើនជំហាន

ចូរអានអត្ថបទដែលផ្តល់ការណែនាំអំពីរបៀបលេង "ល្បែងគោះត្រឡោក" ។ ល្បែងគោះត្រឡោក ជាល្បែងម្យ៉ាងដែលគេលេងក្នុងពេលណាក៏បាន ។ អ្នកលេងមានតែម្នាក់គត់ ។ មុននឹងលេង គេយកត្រឡោកល្អ២ ទំហំប៉ុនគ្នាមកកាន់នឹងដៃស្តាំ១ ឆ្វេង១ ហើយគេអង្គុយ ឬឈរគោះប្រជល់គ្នាតាមចង្វាក់មាន៧ គឺ ៖

ទី១ គោះលើក្បាល

ទី២ គោះខាងមុខ

ទី៣ គោះខាងក្រោមឃ្លៀកស្តាំ

ទី៤ គោះខាងក្រោមឃ្លៀកឆ្វេង

ទី៥ គោះខាងក្រោមជើងស្តាំ

ទី៦ គោះខាងក្រោមជើងឆ្វេង

ទី៧ គោះខាងក្រោយខ្នង រួចចាប់គោះពីទី១ សាជាថ្មី ។

## លំហាត់

ក. ចូរអ្នកសរសេរអត្ថបទខ្លីដែលផ្តល់ការណែនាំឱ្យធ្វើអ្វីមួយ ។

   ១. របៀបលេងល្បែងកម្សាន្តណាមួយ ។

ខ. ចូរអ្នកចាប់ដៃគូ ហើយពិភាក្សាសរសេរឈ្មោះឧបករណ៍ភ្លេងដែលគេប្រើក្នុងវង់ភ្លេងពិណពាទ្យ ។

គ. ចូរប្រាប់ឈ្មោះឧបករណ៍ភ្លេងដែលគេប្រើក្នុងរបាំឆៃយ៉ាំ។

ឃ. តើអ្នកចេះរបាំអ្វីខ្លះ ? ចូររាប់ឈ្មោះរបាំទាំងនោះ ។ តើរបាំនោះគេនិយមរាំនៅពេលណាខ្លះ ?

ង. ចូរអ្នកចាប់ដៃគូហើយគូររូបស្គរ ១ រួចសរសេររៀបរាប់អំពីស្គរនោះ ។

ច. ចូរអ្នកសរសេរការណែនាំតាមលំដាប់រូបភាពខាងក្រោម ៖



មេរៀនទី

# ៨ ជំនឿនិងសាសនា



នៅលើលោកយើងនេះ មានច្រើនជាតិសាសន៍ណាស់ រីឯជំនឿនិងសាសនា ក៏មានច្រើនបែបច្រើនយ៉ាងដែរ ។ ដោយឡែក ប្រទេសកម្ពុជាយើងបានប្រកាន់យកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ គឺជាសាសនាដែលប្រជាជនខ្មែរភាគច្រើនគោរពបូជាតាំងពីបុរាណកាលមក ។ ប៉ុន្តែជនជាតិផ្សេងៗដែលរស់នៅលើទឹកដីកម្ពុជា មានសិទ្ធិពេញលេញក្នុងការជឿ និងគោរពសាសនាតាមទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិខ្លួនផងដែរ ។

# ពាក្យន័យដូចនិងពាក្យន័យផ្ទុយ

គេអាចយល់ន័យពាក្យពិបាកបានតាមរយៈពាក្យដទៃទៀតដែលមានន័យដូច ឬប្រហាក់ប្រហែលគ្នា ឬពាក្យដែលមានន័យផ្ទុយគ្នា។ ពេលខ្លះ គេប្រើពាក្យពីរដែលមានន័យដូចគ្នា ឬមានន័យផ្ទុយគ្នានៅក្នុងល្បះតែមួយ ឬល្បះពីរក្បែរគ្នាដើម្បីពន្យល់ន័យពាក្យណាមួយនៅក្នុងល្បះនោះ ។

ក. ពាក្យន័យដូច

ចូរអានឧទាហរណ៍ខាងក្រោម ៖

១. ពាក្យន័យដូចនឹងពាក្យ"សឹង"គឺគេង ដេក សម្រាន្ត ផ្ទំ ។

២. ពាក្យន័យដូចនឹងពាក្យ"ព្រះពាយ"គឺ ខ្យល់ ជំនោរ វាយោ វាតា ។

៣. ពាក្យន័យដូចនឹងពាក្យ"កម្ម"គឺ"អំពើ" ។

៤. លោកអាចារ្យអញ្ជើញមកដល់មួយស្របក់ ទើបព្រះសង្ឃនិមន្តមកដល់ ។

ពាក្យន័យដូច ជាពាក្យដែលមានន័យដូច ឬប្រហាក់ប្រហែលគ្នា តែមានសំណួរ(សូរសំឡេង)និងសំណេរខុសគ្នា ។

ខ. ពាក្យន័យផ្ទុយ

ចូរអានឧទាហរណ៍ខាងក្រោម ៖

១. ពាក្យន័យផ្ទុយនឹងពាក្យ"បុណ្យ"គឺ"បាប" ។

២. ពាក្យន័យផ្ទុយនឹងពាក្យ"មិត្ត"គឺ"សត្រូវ" ។

៣. ពាក្យន័យផ្ទុយនឹងពាក្យ"គង់វង្ស"គឺ"សាបសូន្យ" ។

៤. ព្រះពុទ្ធសាសនាដឹកនាំមនុស្សឱ្យបានសុខ រួចផុតពីទុក្ខកង្វល់ផ្សេងៗ ។

ពាក្យន័យផ្ទុយ ជាពាក្យដែលមានន័យផ្ទុយគ្នា ។

## លំហាត់

ក. ចូររកពាក្យន័យដូចនឹងពាក្យខាងដើមជួរ ដោយគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ ។

១. ប្រព្រឹត្ត ៖ ☐ ចូលចិត្ត ☐ ធ្វើតាម ☐ ប្រឹងប្រែង

២. ប្រហារ ៖ ☐ ខឹង ☐ ចង ☐ សម្លាប់

៣. គន្លង ៖ ☐ លំអាន ☐ របង ☐ ព្រំប្រទល់ ។

ខ. ចូររកពាក្យពីរដែលមានន័យដូចគ្នានៅក្នុងជួរនីមួយៗ ។

១. ត្រកាល ៖ ប្រសើរ ប្រយ័ត្ន ថ្លៃថ្លា

២. ដេរដាស ៖ ប្រញ៉ិក ពាសពេញ រីវក់

៣. ប្រមាញ់ ៖ បៀតបៀន ប្រមាថ ប្រមូល ។

គ. ចូររកពាក្យផ្ទុយនឹងពាក្យខាងដើមជួរ ដោយគូសសញ្ញា✓ ក្នុងប្រអប់មុខចម្លើយត្រឹមត្រូវ ។

១. សាមគ្គី ៖ ☐ រួបរួម ☐ បែកបាក់ ☐ វៀចវេរ

២. អ៊ូអរ ៖ ☐ ខ្វល់ខ្វាយ ☐ មមាញឹក ☐ ស្ងប់ស្ងាត់ ។

ឃ. ចូររកពាក្យដែលមានន័យផ្ទុយគ្នានឹងពាក្យនៅក្នុងជួរនីមួយៗ ។

១. បុរាណ យូរ សម័យ ចាស់

២. សរសើរ បន្ទុះបង្អាប់ ញញើត កោតក្រែង

៣. អន់ថយ ដុះដាល រួសរាយ ជឿនលឿន

៤. ទុកចិត្ត ប្រយ័ត្ន ធ្វេសប្រហែស ជឿជាក់

៥. ហូរហៀរ ចង្អៀត ញឹកញាប់ ម្ដងម្កាល ។

# ព្រះពុទ្ធសាសនា

ចូរអានអត្ថបទកំណាព្យ រួចឆ្លើយនឹងសំណួរ ។



(បទពាក្យប្រាំពីរ)

| | |
|---|---|
| នៅក្នុងលោកមានច្រើនសាសនា | ដែលមានសក្តាពន់ប្រមាណ |
| ល្បីល្បាញរន្ទឺគ្រប់ទីឋាន | កម្ពុជាយើងបានប្រកាន់យក ។ |
| ព្រះពុទ្ធសាសនាធ្វើជាយាន | ទុកធ្វើជាស្ពានជាជម្រក |
| សិរីសួស្តីនឹងតាមមក | ព្រោះយើងបានជ្រកគ្រប់ៗប្រាណ ។ |
| ព្រះអង្គទូន្មានប្រៀនប្រដៅ | ដល់អស់កូនចៅសព្វទីឋាន |
| ចៀសវាងសម្លាប់សត្វឱ្យបាន | នោះយើងសុខសាន្តមិនមានកម្ម ។ |
| ប្រព្រឹត្តអំពើសុចរិតល្អ | តាំងចិត្តស្មោះសរជាប្រចាំ |
| កុហកបោកប្រាស់កើតក្តីក្តាំ | កុំមើលបំណាំចាំជួយគ្នា ។ |
| កុំសេពគ្រឿងញៀនឬសុរា | កុំជក់កញ្ឆានាំវេទនា |
| កុំកាប់សម្លាប់ប្រមាថគ្នា | កុំលេងប៉ោបៀខាតធនធាន ។ |
| សាសនាដទៃគេគោរព | យើងក៏មិនស្អប់មិនបៀតបៀន |
| បន្តុះបង្អាប់ឬបំពាន | ជីវិតរស់រានមានក្តីសុខ ។ |

## សំណួរ

១. តើនៅលើលោកយើងមានសាសនាអ្វីខ្លះ ?

២. តើប្រទេសកម្ពុជាប្រកាន់យកសាសនាអ្វី ?

៣. តើសាសនាព្រះពុទ្ធប្រដៅមនុស្សឱ្យធ្វើអ្វីខ្លះ និងមិនឱ្យធ្វើអ្វីខ្លះ ?

៤. ហេតុអ្វីបានជាយើងមិនត្រូវស្អប់ខ្ពើមសាសនាដទៃ ?

## លំហាត់

ក. ចូរពន្យល់ន័យរបស់ពាក្យ " សាសនា យាន សុចរិត " ដោយជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

១. សាសនា ៖

☐ ពាក្យទេសនា ☐ ពាក្យឃោសនា ☐ ពាក្យប្រៀនប្រដៅ ។

២. យាន ៖

☐ គ្រឿងប្រើប្រាស់ ☐ គ្រឿងដឹកនាំ ☐ គ្រឿងបរិភោគ ។

៣. សុចរិត ៖

☐ ចរិតខិលខូច ☐ ចរិតស្លូត ☐ ចរិតល្អ ។

ខ. ចូររកពាក្យន័យដូចនឹងពាក្យ ៖ "ជម្រក សេព សាង" ។

គ. ចូររកពាក្យន័យផ្ទុយនឹងពាក្យ ៖ ល្បីល្បាញ សុចរិត សុខសាន្ត ។

ឃ. តើអត្ថបទកំណាព្យខាងលើនិយាយអំពីអ្វី ? ចូរជ្រើសរើសចម្លើយសមស្របមួយ ។

១. ☐ ការអប់រំតាមសាសនានានា

២. ☐ ការអប់រំតាមពុទ្ធសាសនា

៣. ☐ ការរើសអើងសាសនាផ្សេងៗ ។

## សំណេរ

ចូរអានវគ្គកាព្យខាងក្រោម រួចជ្រើសរើសពាក្យក្នុងប្រអប់សម្រាប់យកទៅបំពេញក្នុងចន្លោះវគ្គកាព្យ ឱ្យមានន័យនិងចំណាប់ចួនបានត្រឹមត្រូវ ។

| រ៉ាយរ៉ាប់ | ស្ងួនភ្ងា | ភ្នំបិណ្ឌ | ក្បួន | ពិធី | អលង្គី |
|---|---|---|---|---|---|

ខ្មែរមានជំនឿលើបុណ្យបាប ទើបវាមិនសាបរលាបសូន្យ
ខ្មែរខំធ្វើបុណ្យដែលជា ... សម្រាប់សណ្តូនទៅជាតិមុខ ។
បុណ្យមាឃឬវិសាខបូជា ហៅកូន ... រក្សាទុក
កូនអើយកត់ត្រាជាទំនុក ត្រូវរក្សាទុកបុណ្យសាសនា ។
បុណ្យចូលវស្សាបុណ្យ ... និងបុណ្យកឋិនចេញវស្សា
បុណ្យបច្ច័យបួនបុណ្យឆ្លងដារ ជុំញាតកាផ្កាសាមគ្គី ។
មានបុណ្យច្រើនទៀតត្រូវ ... កូនត្រូវត្រងត្រាប់តាមគម្ពីរ
ខ្មែរតែងប្រារព្ធធ្វើ ... ចូលឆ្នាំ... តរៀងមក ។

## ១ អ្នកបួសតាមពុទ្ធសាសនា (បទកាកគតិ)

ចូរប្អូនស្តាប់កំណាព្យ និងសរសេរបំពេញខ្លឹមសារកំណាព្យនៅពេលកំពុងស្តាប់ ។





តាំងពីដូនតា ខ្មែរជឿ... សមណគោតម
ព្រះអង្គនាំផ្លូវ ដើរទៅឧត្តម ប្រកាន់ក្រឹត្យ...
ល្បីគ្រប់ទិសទី ។

ខ្មែរឱ្យកូនបួស ជាព្រះសង្ឃព្រោះ តាមប្រពៃណី
បួសដើម្បីសង គុណលោកទាំង... និងតួ.......
ថែពុទ្ធសាសនា ។

បើបានបួសហើយ អ្នកកុំ........ កុំឱ្យមុសា
គោរពព្រះធម៌ ព្រះពុទ្ធផង... រៀនសូត្រធម៌...
ព្រះត្រៃបិដក ។

លះបង់កិលេស កាមគុណដែល... ដូចព្យុះបោក...
កម្ចាត់មោហោ ទោសោ....... កុំឱ្យរំលង់រំរក់
ជាប់ក្នុងអាត្មា ។

កុំបួសលេងៗ បួសធ្វើជា... បួសនាំខូច...
បាត់បង់ជំនឿ ព្រះពុទ្ធ...... បួសមិនជ្រះ...
បួសសន្សំទ្រព្យ ។

## សំណួរ

១. តើខ្មែរយើងមានជំនឿលើសាសនាអ្វី ?
២. តើខ្មែរយើងឱ្យកូនប្រុសកោរសក់បួសដើម្បីអ្វី ?
៣. ដើម្បីរក្សាពុទ្ធសាសនា តើអ្នកបួសធ្វើដូចម្ដេចខ្លះ ?
៤. តើតាមជំនឿអ្នកបួសគោរពតាមពុទ្ធឱវាទត្រឹមត្រូវនឹងទៅកើតនៅទីណា ?

## លំហាត់

ចូរកត់ត្រាគំនិតសំខាន់ៗ នៅក្នុងកំណាព្យ ។

## សព្វនាមចង្អុល

ចូរអានល្បះខាងក្រោមនេះ ពាក្យមានគំនូសពីក្រោមជាសព្វនាមចង្អុល ។

១. នេះជាព្រះវិហារ ។ នោះជាសាលាឆាន់ ។

២. ខ្ញុំបានទិញរូបចម្លាក់ព្រះពុទ្ធពីរអង្គ ។ នេះជារូបព្រះពុទ្ធទើបតែប្រសូត ឯនោះជារូបព្រះពុទ្ធចូលព្រះនិព្វាន ។

៣. ពេលចូលវិហារ ជនជាតិអ៊ីស្លាមស្លៀកសារុង និងពាក់មួកកន្ទិប ។ នេះជាទំនៀមទម្លាប់របស់ពួកគេ ។

៤. មានសៀវភៅពីរនៅលើតុ : អានេះជារបស់ខ្ញុំ ។ អានោះជារបស់ឯង ។

៥. បណ្ដាជាងទាំងពីរនាក់នេះ អ្នកនេះប្រសប់ជាងអ្នកនោះ ។

ពាក្យ"នេះ នោះ"ក្នុងល្បះទី១ និងទី២ ជាពាក្យចង្អុលបង្ហាញ ។ គេប្រើក្នុងពេលកំពុងនិយាយ ។

ពាក្យ"នេះ"ក្នុងល្បះទី៣ ជំនួសល្បះដែលគេនិយាយខាងដើម ។

ពាក្យ" អានេះ" " អានោះ" ក្នុងល្បះទី៤ សម្រាប់ផ្លាស់កន្សោមនាមវត្ថុ ។

ពាក្យ" អ្នកនេះ" " អ្នកនោះ" ក្នុងល្បះទី៥ សម្រាប់ផ្លាស់កន្សោមនាមមនុស្ស ។

> សព្វនាមចង្អុល គឺជាពាក្យសម្រាប់ចង្អុលបង្ហាញអ្វីមួយ ឬជំនួសកន្សោមនាម ឬល្បះដែលគេបាននិយាយពីមុខ ។

កំណត់ចំណាំ សព្វនាមចង្អុលមានពីរយ៉ាងគឺ ៖

- ពាក្យ "នេះ" សម្រាប់បង្ហាញអ្វីដែលនៅជិត ។
- ពាក្យ "នោះ" សម្រាប់បង្ហាញអ្វីដែលនៅឆ្ងាយ ។

សព្វនាមចង្អុលមាន ៖ នេះ នោះ អ្នកនោះ អានេះ អានោះ មួយនោះ មួយនេះ... ។

## លំហាត់

ក. ចូរអានល្បះខាងក្រោម រួចស្រង់សព្វនាមចង្អុល ៖

១. នៅថ្ងៃភ្ជុំបិណ្ឌ ខ្មែរយើងយកចង្ហាន់ទៅប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសកុសលដល់ញាតិសន្តានដែលបានចែកឋានទៅ ។ នេះមកពីយើង មានជំនឿថា ព្រះសង្ឃអាចបញ្ជូនកុសលដល់ពួកគាត់មែន ។

២. នៅលើសកលលោកមានសាសនាច្រើន ប៉ុន្តែប្រជាជនកម្ពុជាភាគច្រើនបានប្រកាន់យកសាសនាព្រះពុទ្ធ ។ នោះគឺដោយសារប្រជាជនយើង មានជំនឿមុតមាំលើព្រះពុទ្ធសាសនា ។

៣. មិត្តខ្ញុំទើបនឹងទិញសៀវភៅសរសេរពីរក្បាល ។ មួយនេះសម្រាប់កត់មេរៀន ឯមួយនោះសម្រាប់ធ្វើលំហាត់ ។

៤. គាត់ជាកូនភ្លោះ ប៉ុន្តែកាន់សាសនាខុសគ្នា ។ អ្នកនេះជឿព្រះពុទ្ធសាសនា ឯអ្នកនោះជឿគ្រិស្តសាសនា ។

ខ. ចូរប្រើប្រាស់សព្វនាម“នេះ អានេះ អ្នកនេះ” ដើម្បីតែងល្បះឱ្យបាន ៣ ល្បះ ។

8

# បុណ្យតាមជំនឿព្រះពុទ្ធសាសនា

## ចូរអានអត្ថបទកំណាព្យ រួចឆ្លើយនឹងសំណួរ ។



(បទព្រហ្មគីតិ)

ប្រទេសកម្ពុជា រាស្ត្រប្រជាស្តេចមន្ត្រី
ធ្វើបុណ្យទាំងប្រុសស្រី តូចធំក្តីតាមសទ្ធា ។
បុណ្យតាមពុទ្ធសាសនា មានបុណ្យផ្ការួមសាមគ្គា
កសាងកុដិវិហារ ធ្វើខ្លោងទ្វារឬចេតិយ ។
ភ្ជុំបិណ្ឌបុណ្យមួយទៀត ខំខ្មីឃ្មាតហើយលកលៃ
កាន់បិណ្ឌទាំងប្រុសស្រី ជាទ្រឹស្តីពុទ្ធសាសនា ។
ជាបុណ្យជូនកុសល ជូនមគ្គផលដល់ដូនតា
ដែលបានសូន្យសង្ខារ ចាកលោកាទទួលយក ។
ឯបុណ្យចូលឆ្នាំថ្មី នាំសិរីសួស្តីមក
នាំគ្នាបោសជម្រក ហើយរត់រករៀបផ្កាភ្ញី ។
ផ្លែឈើសែនទេព្តា ថែមម្លូស្លានិងវារី
ចង្ហាន់ធូបទៀនភ្ញី ក្រាបវន្ទីយ៍ប្រគេនលោក ។

## សំណួរ

១. តើកំណាព្យនេះ និយាយអំពីអ្វី ?

២. តើមានបុណ្យអ្វីខ្លះ ដែលរៀបរាប់នៅក្នុងកំណាព្យខាងលើ ?

៣. តើគេធ្វើបុណ្យផ្កាដើម្បីអ្វី ?

៤. គេធ្វើបុណ្យភ្ជុំបិណ្ឌដើម្បីអ្វី ?

៥. តើគេរៀបចំអ្វីខ្លះ សម្រាប់ថ្វាយទេពតានៅក្នុងពិធីបុណ្យចូលឆ្នាំថ្មី ?

៦. តើអ្នកចូលចិត្តធ្វើបុណ្យទាំងអស់នេះដែរ ឬទេ ? ព្រោះអ្វី ?

៧. ដើម្បីឱ្យបុណ្យទាំងអស់នេះនៅមានជារៀងរហូត តើអ្នកត្រូវធ្វើដូចម្ដេច ?

## លំហាត់

ក. ចូរពន្យល់ន័យរបស់ពាក្យ " សទ្ធា សិរី វន្ទិយ៍" ដោយជ្រើសរើសចម្លើយមួយ ។

១. សទ្ធា ៖

☐ សេចក្ដីរុងរឿង ☐ សេចក្ដីជឿជាក់ ☐ សេចក្ដីជឿបុណ្យ ។

២. សិរី ៖

☐ មាសប្រាក់ ☐ សេចក្ដីសុខ ☐ ទ្រព្យសម្បត្តិ ។

៣. វន្ទិយ៍៖

☐ ឱន ☐ ថ្វាយបង្គំ ☐ គោរព ។

ខ. ចូរអានរកពាក្យន័យដូចនឹងពាក្យ"វ័យ សង្ខារ វារី" ។

គ. ចូររកពាក្យន័យផ្ទុយនឹងពាក្យ"កុសល " ។

ឃ. ចូរផ្គូផ្គងពាក្យចួនឱ្យបានត្រឹមត្រូវតាមអត្ថបទកំណាព្យ ។

| | | | |
|---|---|---|---|
| កម្ពុជា | ផ្កា | សាមគ្គា | ស្រី |
| មន្ត្រី | ឃ្មាត | ទៀត | វិហារ |
| សាសនា | ប្រជា | កុសល | សង្ខារ |
| | | ដូនតា | មគ្គផល ។ |

## សំណេរ

ចូរសរសេរកំណាព្យខ្លីៗ ចំនួន ២ វគ្គ រៀបរាប់អំពីសាសនាដែលអ្នកស្គាល់ ឬដែលអ្នកគោរព ។

## សំណេរ

ចូរអានវគ្គកាព្យខាងក្រោម រួចជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញក្នុងចន្លោះនៃវគ្គកាព្យបទព្រហ្មគីតិនោះ ឱ្យមានន័យនិងចំណាប់ចួនត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| កម្លាំង | លោកា | ផ្សេង | ចិត្ត | កម្លោច | យាយី |

ជំនឿនិងសាសនា ក្នុង .... មានច្រើនណាស់
គ្រប់គ្នាត្រូវយល់ច្បាស់ កុំបោកប្រាស់ទាស់ទែងគ្នា ។
គោរពសាសនា ... តែកុំឆ្វេងបែកសាមគ្គី
រាប់រកគ្នាមូលមីរ កុំ.... នាំហិនហោច ។
បើយើងសាមគ្គីខ្លាំង រួម ... មានប្រយោជន៍
ជាជាងដុត.... នាំឱ្យខ្លោចផ្សារៀងខ្លួន ។
សាសនាខុសគ្នាពិត ឱ្យតែ ... មិនគុំកួន
បានសុខកាយរៀងខ្លួន ចាមចិនយួនគ្រប់សញ្ជាតិ ។

## ការរៀបរាប់អំពីជំនឿសាសនាផ្សេងៗ

ចូរអានការសន្ទនារវាងជីតានឹងចៅៗ ។ តើពួកគេកំពុងនិយាយគ្នាអំពីអ្វីខ្លះ ?

ចៅៗ : ជម្រាបសួរលោកតា !

ជីតា : លើកដៃថ្វាយព្រះ! តើពួកចៅមិនទៅរៀនទេឬ ថ្ងៃនេះបានជាមកលេងនឹងតា ?

ចៅៗ : ជម្រាបប្រសាសន៍លោកតា ថ្ងៃនេះជាថ្ងៃបុណ្យចូលឆ្នាំសកល ។ មន្ត្រីរាជការ កម្មករ សិស្ស និស្សិតទាំងអស់ ត្រូវបានឈប់សម្រាកពេញមួយថ្ងៃ ។

ជីតា : អូ! តាប៉ិះតែភ្លេចទៅហើយ! តើចៅៗមានការអ្វី ទើបមករកតាទាំងព្រលឹមបែបនេះ ?

ចៅៗ : បាទ! លោកតា ចៅៗមកនេះចង់ជម្រាបសួរលោកតាអំពីរឿងសាសនា ។ សព្វថ្ងៃនេះ ប្រទេសយើងប្រកាន់យកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ ហេតុអ្វីនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មានវិហារអ៊ីស្លាម វិហារយេស៊ូ និងវិហារចិនដែរ ?

ជីតា : ចៅដឹងទេ! ថ្វីត្បិតតែប្រទេសយើងប្រកាន់យកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ ប៉ុន្តែជនជាតិដទៃរស់នៅលើទឹកដីកម្ពុជា មានសិទ្ធិពេញលេញក្នុងការជឿជំនឿសាសនា របស់ជនជាតិខ្លួនផងដែរ ។

ចៅៗ : ដូច្នេះ យើងមិនត្រូវរើសអើងសាសនាដទៃទេ តើមែនឬទេលោកតា ?

ជីតា : មែនហើយចៅ កាលបើយើងមិនមានការរើសអើង ប្រជាជនកម្ពុជាទាំងអស់នឹងរួមរស់ជាមួយគ្នាក្នុងធម៌សាមគ្គី ហើយសាមគ្គីធម៌នេះធ្វើឱ្យយើងបានសុខសន្តិភាព ។

## សំណួរ

១. តើពួកគេសួរជីតាអំពីរឿងអ្វី ?

២. តើជនជាតិដទៃដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មានសិទ្ធិជឿលើជំនឿ និងសាសនាផ្សេងៗបានដែរឬទេ ? ព្រោះអ្វី ?

៣. ហេតុអ្វីបានជាយើងមិនត្រូវរើសអើងសាសនា ?

## លំហាត់

ចូរនិយាយប្រាប់មិត្តអ្នក អំពីជំនឿសាសនាដែលក្រុមគ្រួសាររបស់អ្នកបានប្រកាន់យកសព្វថ្ងៃនេះ ។

## ការតែងកំណាព្យ

ក. ចូរតែងកំណាព្យខ្លីដោយមើលរូបភាពខាងក្រោម ៖



ខ. អ្នកបានសិក្សាកំណាព្យបទព្រហ្មគីតិ និងបទពាក្យប្រាំពីររួចហើយតាមរយៈអត្ថបទអំណាន ។ ចូរអ្នកតែងកំណាព្យខ្លីមួយ ឱ្យបានចំនួន២វគ្គដោយប្រើបទពាក្យប្រាំពីរ ឬព្រហ្មគីតិ ។

មេរៀនទី

# ៩ រមណីយដ្ឋានទេសចរណ៍នៅកម្ពុជា



ប្រទេសកម្ពុជា សម្បូរកន្លែងទេសចរណ៍គួរជាទីមនោរម្យ ។ រមណីយដ្ឋានខ្លះ កើតឡើងដោយធម្មជាតិដូចជាឆ្នេរសមុទ្រ ទឹកជ្រោះ ទឹកធ្លាក់ ព្រៃភ្នំ ។ល។ កន្លែងខ្លះទៀតត្រូវមនុស្សបង្កើតឡើងដូចជា ប្រាសាទបុរាណ បារាយណ៍ជាដើម ។

តើកន្លែងទេសចរណ៍ក្នុងរូបភាពខាងលើមានឈ្មោះអ្វីខ្លះ ? តើរមណីយដ្ឋានទាំងនោះឋិតនៅក្នុងខេត្តណាខ្លះ ?



# អន្លង់ព្រីង



បើយើងចង់ធ្វើដំណើរទៅទស្សនាសត្វក្រៀលនៅតំបន់អភិរក្សអន្លង់ព្រីង យើងគ្រាន់តែចេញដំណើរពីទីប្រជុំជនស្រុកកំពង់ត្រាច ទៅទិសខាងត្បូងប្រមាណជាជាង១១ គីឡូម៉ែត្រនោះ យើងនឹងបានឃើញផ្ទៃទឹកល្ហល្ហេវ ហើយមានសត្វក្រៀលយ៉ាងច្រើនកំពុងដើររកចំណី ។

តំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីង ស្ថិតនៅក្នុងឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ។ តំបន់នេះ មានផ្ទៃល្ហល្ហេវជាច់កន្ទុយភ្នែក ហើយសម្បូរទៅដោយសត្វស្លាបជាច្រើនប្រភេទ ពិសេសសត្វក្រៀល ។ សត្វនេះ ជាប្រភេទសត្វត្រូវបានគេចាត់ទុកថាជាសត្វដ៏កម្រ និងជិតផុតពូជទៅហើយ នៅលើភពផែនដីយើងនេះ ។

នៅរដូវប្រាំង តំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីង គឺជាកន្លែងដ៏សំខាន់មួយ ដែលសត្វក្រៀលឆ្លងកាត់ទៅមក ពីប្រទេសវៀតណាមមករកចំណីនៅទីនេះ ។ តំបន់នេះកើតឡើងនៅក្នុងឆ្នាំ២០០៤ ប៉ុន្តែពេលនោះ សត្វក្រៀលមិនទាន់ចុះមកច្រើនទេ ទើបតែឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១០នេះ សត្វក្រៀលមានការកើនឡើង រហូតដល់ទៅជាង៣០០ក្បាល នេះបើតាមការឃ្លាំមើលពីអង្គការសង្គ្រោះសត្វស្លាបសហការជាមួយមន្ត្រីរដ្ឋបាលព្រៃឈើ ។

## សំណួរ

១. តើតំបន់អភិរក្សអន្លង់ព្រីង ឋិតនៅឯណា ?

២. តើតំបន់នេះ កើតឡើងនៅឆ្នាំណា ?

៣. តើសត្វក្រៀល មានការកើនឡើងចាប់ពីពេលណាមក ?

៤. តើសត្វក្រៀល មានចំនួនប្រហែលប៉ុន្មាន ?

៥. តើតំបន់នេះ ត្រូវបានបញ្ចូលជាតំបន់អភិរក្សសត្វក្រៀលនៅឆ្នាំណា ?

## លំហាត់

ក. ចូរប្រាប់ន័យពាក្យនីមួយៗ ដោយជ្រើសរើសចម្លើយមួយ ។

១. អភិរក្ស

☐ រក្សាជារៀងរហូត

☐ ថែទាំជានិច្ច

☐ រក្សាដោយប្រុងប្រយ័ត្ន ។

២. ល្ហល្ហេវ

☐ ខ្ពស់ស្រឡះ

☐ វែងឆ្ងាយ

☐ វាលធំគ្មានអ្វីទើស ។

៣. រដ្ឋបាលព្រៃឈើ

☐ អ្នករក្សាព្រៃឈើ

☐ អ្នករក្សាទឹកដី

☐ អ្នករក្សាសត្វ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ “ ពី ” ។

## សំណេរ

ចូរអ្នកសរសេរអត្ថបទពណ៌នាពីទេសភាព តាមរូបភាពខាងក្រោម ៖



តំបន់អភិរក្សសត្វក្រៀលនៅអន្លង់ព្រីងនេះ មានផ្ទៃដីជាច្រើនហិចតាជាប់នឹងឃុំពីរ គឺឃុំព្រែកក្រឹស និងឃុំបឹងសាលាខាងត្បូង ។ នៅខែវិច្ឆិកា ឆ្នាំ២០១០តំបន់នេះត្រូវបានប្រកាសជាផ្លូវការជាតំបន់អភិរក្សសត្វក្រៀល ។ ប្រជាពលរដ្ឋ និងមន្ត្រីទាំងឡាយរបស់ខេត្តកំពតសង្ឃឹមថាតំបន់អភិរក្សមួយនេះ និងទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាសត្វក្រៀលកាន់តែច្រើនឡើង ។

# ទេសភាពមាត់សមុទ្រ



ក្រោយពីបានស្តាប់ការរៀបរាប់ពីទេសភាពមាត់សមុទ្រ ចូរអ្នកឆ្លើយនឹងសំណួរខាងក្រោម ។

១. តើមានអ្វីគ្របពីលើផ្ទៃសមុទ្រនៅពេលព្រលឹមស្រាងៗ ?

☐ ស្បៃស្តើង ☐ ពពុះទឹក ☐ អ័ព្ទស្តើង ។

២. តើទឹកសមុទ្រមានពណ៌អ្វីនៅពេលយប់ ?

☐ ពណ៌ខ្មៅ ☐ ពណ៌ខៀវ ☐ ពណ៌ក្រហម ។

## ចំណងឈ្នាប់ ឬឈ្នាប់

ចំណងឈ្នាប់ ឬឈ្នាប់ មាន២ប្រភេទ គឺឈ្នាប់ចង និងឈ្នាប់ឃ្លា ។

ក. ឈ្នាប់ចង

ឧទាហរណ៍ ៖

១. តើអ្នកចូលចិត្តឡើងភ្នំ ឬងូតទឹកជ្រោះ ?

២. កន្លែងកម្សាន្ត គួរតែមានសុវត្ថិភាព និងអនាម័យ ។

៣. ប្អូនខ្ញុំចូលចិត្តទៅលេងមាត់សមុទ្រ តែវាមិនចូលចិត្តងូតទឹកសមុទ្រទេ ។

ពាក្យ " ឬ" សម្គាល់ទំនាក់ទំនងរវាងពាក្យ " ឡើងភ្នំ " និង " ងូតទឹក" ។

ពាក្យ " និង "សម្គាល់ទំនាក់ទំនងរវាងពាក្យ" សុវត្ថិភាព " និង " អនាម័យ " ។

ពាក្យ " តែ " សម្គាល់ទំនាក់ទំនងរវាងល្បះ " ប្អូនខ្ញុំចូលចិត្តទៅលេងមាត់សមុទ្រ" និងល្បះ " វាមិនចូលចិត្តងូតទឹកសមុទ្រទេ " ។

ពាក្យ " ឬ និង តែ " ជាឈ្នាប់ចង ។

ឈ្នាប់ចងមាន ៖ និង ហើយនិង ឬ ឬក៏ តែ ប៉ុន្តែ... ។

> ឈ្នាប់ចង គឺជាពាក្យចំណងសម្រាប់សម្គាល់ទំនាក់ទំនងរវាងល្បះនិងល្បះ ឬរវាងធាតុផ្សេងៗនៅក្នុងល្បះ ។

ខ. ឈ្នាប់ឃ្លា

ឧទាហរណ៍ ៖

១. គាត់ប្រាប់ខ្ញុំថា បងគាត់ទៅមើលប្រាសាទ ។

២. ខ្ញុំពុំដឹងជា គាត់ទៅណាទេ ។

ពាក្យ " ថា ជា " ជាឈ្នាប់ឃ្លា ។

ល្បះនីមួយៗខាងលើអាចចែកជា២ឃ្លា ៖

- គាត់ប្រាប់ខ្ញុំជាឃ្លា១
- ថាបងគាត់ទៅមើលប្រាសាទជាឃ្លាមួយទៀត ។ ឃ្លានេះមានឈ្មោះថា ឃ្លារណប ។

ឈ្នាប់ឃ្លាមាន៖ ថា ជា ពីព្រោះ ដើម្បី បើ លុះ កាលណា ទោះបី... ។

ឈ្នាប់ឃ្លា គឺជាពាក្យចំណង សម្រាប់សម្គាល់ទំនាក់ទំនងគ្នារវាង ឃ្លា និងឃ្លា ហើយនិងសម្រាប់បង្កើតឃ្លារណប ។

## លំហាត់

ក. ចូរស្រង់ឈ្នាប់នៅក្នុងកថាខណ្ឌខាងក្រោម ហើយប្រាប់ថា ពាក្យអ្វីខ្លះជាឈ្នាប់ចង ពាក្យអ្វីខ្លះជាឈ្នាប់ឃ្លា ។

រមណីយដ្ឋានអាងទឹកម្លិចស្ថិតនៅឃុំច្រេស ភូមិត្រពាំងឈើទាលស្ថិតនៅក្នុងស្រុកជុំគីរីខេត្តកំពត ។ រមណីយដ្ឋានម្លិច ហ៊ុមព័ទ្ធជុំវិញដោយកូនភ្នំ ហើយមានជំនោរបរិសុទ្ធបក់មករំភើយៗ គួរជាទីមនោរម្យ ។ ជាមួយគុណសម្បត្តិទាំងអស់នេះ គេឃើញចំនួនភ្ញៀវទេសចរទាំងក្នុង និងក្រៅតំបន់នៅតែបន្តហូរចូល និងកើនឡើងជាលំដាប់ ។

បរិស្ថានរមណីយដ្ឋានម្លិចពិតជាល្អប្រសើរណាស់ ទោះបីមានភ្ញៀវទេសចរទៅកម្សាន្តយ៉ាងកុះករក៏ដោយ ក៏នៅតែរក្សាបាននូវអនាម័យល្អ ព្រោះក្រៅពីមានការបោសសម្អាត រើសសំរាមដាក់ក្នុងធុង គឺនៅមានការបើកទ្វារទឹកបង្ហូរចេញតាមរដូវទៀត ។

ខ. ចូរតែងល្បះនឹងពាក្យនីមួយៗខាងក្រោមឱ្យបានមួយល្បះក្នុងពាក្យមួយ ។

ឬ តែ និង ថា ជា ពីព្រោះ ។

# រឿង បឹងយក្សឡោម



កាលពីយូរលង់ណាស់មកហើយ មានស្ដេចយក្សមួយអង្គមានឫទ្ធិអំណាចខ្លាំងពូកែណាស់ ។ ព្រះអង្គមានបុត្រីមួយដែលមានរូបស្អាត និងមានសក់ក្រអូប ។ ព្រះអង្គឱ្យឈ្មោះថា “ នាងសក់ក្រអូប” ។ លុះដល់ព្រះនាងធំពេញវ័យ មានមនុស្សម្នាក់ខ្លាំងពូកែបានចូលទៅលបលួចស្នេហា ជាមួយព្រះនាង ។ ដោយភ័យខ្លាចបិតាដឹង អ្នកទាំងពីរបាននាំគ្នារត់ចូលព្រៃមួយ ។

ក្រោយមក ស្ដេចយក្សដឹងរឿងរ៉ាវនេះ ក៏ផ្ដើលនោឡោកេណ្ឌពលយក្សទៅតាមរកបុត្រី ។ លុះដល់ព្រៃស្ដុកមួយ ស្ដេចយក្សសង្ស័យថា ប្រហែលបុត្រីខ្លួននៅជិតនោះ ទើបបញ្ជាឱ្យបរិវារមួយក្រុមយាមល្បាតហ៊ុមព័ទ្ធព្រៃនោះយ៉ាងមាំ ហើយមួយក្រុមទៀតដកព្រៃព្រឹក្សាគ្រវែងចោល និងជីកកកាយរកនាង ។ ទោះបីពួកយក្សប្រឹងជីកយ៉ាងណាក្ដី ក៏នៅតែរកពុំឃើញ ទើបស្ដេចក្រុងយក្សត្រឡប់ទៅវិញ ។

អាស្រ័យដោយពួកយក្សកកាយរកនាងសក់ក្រអូប ទើបទីនោះក្លាយជាស្រះមួយនៅក្នុងតំបន់ឡាបានសៀក ស្រុកលំផាត់ ខេត្តរតនគិរី ដែលគេហៅថា“ ស្រះយក្សឡោម” រហូតដល់សព្វថ្ងៃ ។

បឹងយក្សឡោម ជាស្រះមួយមានទឹកថ្លាឈ្វេង ។ ស្រះនេះ មានជម្រៅ៧០ម៉ែត្រ ។ ស្រះយក្សឡោម មានរាងរង្វង់មូលស្មើនារដូវប្រាំង ។ នៅតាមមាត់ស្រះ មានដើមមាក់ប្រេង មាក់ប្រាង សាវម៉ាវ សិរមាន់ដុះពាសពេញ ។ នៅជុំវិញស្រះ មានផ្លូវដីវិចិត្រដែលអាចបើកបររថយន្តបានយ៉ាងស្រួល និងមានព្រះរាជដំណាក់ ភោជនីយដ្ឋានតូចៗសម្រាប់ទទួលភ្ញៀវ ។ នៅក្នុងស្រះ មានមច្ឆជាតិតូចធំគ្រប់ប្រភេទហិចហែលទាំងហ្វូងៗ ។ អ្នកដំណើរណាដែលបានទៅដល់ខេត្តរតនគីរី គេពុំដែលភ្លេចទៅលម្ហែ ឬទស្សនាស្រះយក្សឡោមឡើយ ព្រោះកន្លែងនោះជារមណីយដ្ឋានមួយល្អនៅក្នុងភូមិភាគឦសាន ។

(សម្រួលពីសៀវភៅប្រជុំរឿងព្រេងភាគទី ៦ ទំព័រទី ៩៨)

## សំណួរ

១. តើស្រះយក្សឡោមស្ថិតនៅក្នុងខេត្តណា ?

២. តើស្រះយក្សឡោម ជាស្រះធម្មជាតិ ឬក៏ជាស្រះដែលកើតឡើងដូចរឿងរ៉ាវខាងលើ ?

៣. តើស្រះនេះកើតឡើងដោយសារអ្វី ?

៤. តើស្រះនេះមានរាងដូចម្ដេច ? មានជម្រៅប៉ុន្មាន ?

## លំហាត់

ក. ចូរអ្នករកពាក្យដែលមានន័យដូចគ្នាមកជំនួសពាក្យដែលមានគំនូសពីក្រោម ។

១. ព្រះអង្គមានបុត្រីមួយមានរូបស្អាត និងមានសក់ក្រអូប ។

២. ដោយភ័យខ្លាចបិតាដឹង អ្នកទាំងពីរបាននាំគ្នារត់ចូលព្រៃមួយ ។

៣. ស្ដេចក្រុងយក្ស នាំបរិវារត្រឡប់ទៅវិញ ។

៤. នៅជុំវិញស្រះ មានផ្លូវដីវិចិត្រដែលអាចបើកបររថយន្តបាន ។

៥. នៅក្នុងស្រះ មានមច្ឆជាតិតូចធំគ្រប់ប្រភេទហិចហែលទាំងហ្វូងៗ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ“វ័យ ពីរ ដុះ” ។

គ. ចូររកពាក្យផ្ទុយនឹងពាក្យខាងក្រោម និងបង្កើតល្បះងាយៗនឹងពាក្យនីមួយៗ ។

យូរ ខ្លាំង ស្អាត ក្រអូប ធំ ជិត ថ្លា ស្រួល តូច ។

ឃ. ចូរស្រង់ឈ្មោះ ឬចំណាងឈ្មោះនៅក្នុងអត្ថបទ ។

## អត្ថបទពណ៌នា

ក. ចូរសរសេរអត្ថបទខ្លី ពណ៌នាអំពីទីកន្លែងទេសចរណ៍មួយតាមរូបភាពខាងក្រោម ។



ខ. អ្នកបានអានអត្ថបទអំណាននិងស្តាប់រួចហើយ ។

ចូរសរសេរអត្ថបទខ្លីមួយ រៀបរាប់អំពីកន្លែងកម្សាន្តណាមួយដែលអ្នកបានស្គាល់ច្បាស់ ។

មេរៀនទី

# ១០ សេចក្ដីថ្លៃថ្នូរ






សេចក្ដីថ្លៃថ្នូរ ជាគុណសម្បត្តិដ៏ប្រពៃដែលមនុស្សគ្រប់រូបប្រាថ្នាចង់បាន ។ មនុស្សមានសេចក្ដីថ្លៃថ្នូរ លុះត្រាតែជននោះប្រព្រឹត្តតែអំពើល្អប្រកបដោយ គុណធម៌ សីលធម៌ សុចរិត សប្បុរស មិនបៀតបៀនអ្នកដទៃ ចេះគោរពច្បាប់ និងចេះអត់ឱន អធ្យាស្រ័យ ជាពិសេសមានមនុស្សធម៌ និងមានការងារសុចរិត ។

# រឿង ក្ដីស្រមៃ



ស៊ីថាជាសិស្សរៀននៅវិទ្យាល័យមួយក្នុងខេត្តសៀមរាប ។ នាងមានបងស្រីម្នាក់ឈ្មោះសុភាពពិការជើងម្ខាង ។ សុភាពតែងស្រមៃថា នាងនឹងមានការងារសមរម្យមួយនៅក្នុងពេលអនាគត ។

ថ្ងៃមួយ ពេលដែលស៊ីថារៀបនឹងចេញទៅបន្តការសិក្សានៅភ្នំពេញ សុភាពសុំប្អូនទៅតាមដែរ ព្រោះចង់រកការងារធ្វើ ។ ស៊ីថានិយាយទៅកាន់បងស្រីដោយក្ដីអាណិតក្រៃលែង ៖“ បងស្រីកុំព្រួយអី ចាំខ្ញុំមានការងារធ្វើ ខ្ញុំចិញ្ចឹមបង មិនឱ្យពិបាកធ្វើការនឿយហត់ឡើយ” ។ សុភាពមិនពេញចិត្តនឹងគំនិតនេះទេ ។ នាងឆ្លើយតបទៅប្អូន ៖“ បងមានដៃ អាចធ្វើការបាន ។ បងមិនអាចរស់ដោយសារប្អូនបានទេ ។ បងត្រូវតែរកការងារតាមលទ្ធភាពរបស់បង” ។ នាងបន្តទៀត ៖“ថ្ងៃមុនបងមើលទូរទស្សន៍ ឃើញមានហាងមួយលក់ផ្កាស្អាតៗ ។ បងចង់ទៅរៀនកាត់ផ្កាណាស់ ។ បងអាចធ្វើការងារនេះបាន ។ ឱ្យបងទៅជាមួយផង ” ។ ស៊ីថាមិនអាចឃាត់បងស្រីបាន ក៏សុខចិត្តឱ្យបងស្រីទៅតាម ។

មកដល់ភ្នំពេញ សុភាពបានរៀនកាត់ផ្កានៅក្នុងហាងលក់ផ្កា ដូចបំណងរបស់នាង ។ អាស្រ័យដោយមានការខិតខំប្រឹងប្រែង មិនយូរប៉ុន្មានសុភាពក្លាយជាអ្នកកាត់ផ្កាដ៏ជំនាញម្នាក់ ។ ពេលត្រឡប់មកស្រុកកំណើតវិញ នាងបានបើកហាងតូចមួយលក់ផ្កានៅ

ជិតផ្សារ ។ ក្នុងពេលប្រកបអាជីព នាងបានប្រើគំនិតច្នៃប្រឌិតបន្ថែម ធ្វើឱ្យផ្កានៅក្នុងហាងរបស់នាងមានគ្រប់បែប ហើយប្លែកជានិច្ច ។ រាល់ថ្ងៃ គេឃើញមានភ្ញៀវចេញចូលឥតឈប់ឈរ ។ សុភាពសប្បាយចិត្តណាស់ ។ ពេលនេះ ក្តីស្រមៃរបស់នាងក្លាយជាការពិតហើយ ។ ស៊ីថាកោតសរសើរបងស្រីនាងណាស់ ។ ស៊ីថាគិតថា មនុស្សពិការទាំងអស់សុទ្ធតែមានលទ្ធភាពកសាងជីវិតខ្លួនឱ្យល្អប្រសើរឡើងទៅតាមសមត្ថភាពរៀងៗខ្លួន និងអាចរស់នៅក្នុងសេចក្តីថ្លៃថ្នូរ ។

## សំណួរ

១. តើរឿងនេះ មានតួអង្គណាខ្លះ ?

២. តើសុភាពមានបំណងដូចម្តេច ?

៣. តើសុភាពធ្វើដូចម្តេចខ្លះ ទើបអាចសម្រេចបំណងរបស់ខ្លួនបាន ?

៤. តើរឿងនេះ មានគំនិតអប់រំដូចម្តេច ?

## លំហាត់

ក. ចូររកពាក្យសូរដូចនឹងពាក្យក្នុងប្រអប់ខាងក្រោម រួចប្រើវចនានុក្រម ដើម្បីពន្យល់ន័យរបស់វា ។

| | | | | |
|---|---|---|---|---|
| ចិត្ត | ការ | ទុក | ផ្សារ | រស់ |

ខ. ចូររកពាក្យន័យដូចនឹងពាក្យក្នុងប្រអប់ខាងក្រោម ។

| | | | |
|---|---|---|---|
| ផ្ទះ | អាជីព | សិក្សា | ផ្កា |

គ. ចូររកពាក្យន័យផ្ទុយនឹងពាក្យ ៖

សប្បាយ ប្រឹងប្រែង ទំនេរ អនាគត បន្ថែម រស់ ។

ឃ. ចូរសរសេរសង្ខេបរឿងខាងលើឡើងវិញ ។

## សំណេរ

ក. ចូរតែងល្បះតាមរូបភាពនេះ ឱ្យបាន៥ល្បះ ។



ខ. ចូរតែងកថាខណ្ឌខ្លីមួយ (៥-៧ល្បះ)និយាយពីមនុស្សណាម្នាក់ដែលអ្នកយល់ថាជាមនុស្សល្អ ។

## រឿង ក្ដីស្រមៃ

ចូរស្ដាប់សេចក្ដីសង្ខេបរឿង រួចឆ្លើយនឹងសំណួរខាងក្រោម ៖

១. តើរឿងនេះ មានតួអង្គណាខ្លះ ?

២. តើរឿងនេះ កើតឡើងនៅកន្លែងណាខ្លះ ?

៣. តើរឿងនេះ មានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ ?

៤. តើអ្នកយល់ស្របនឹងសេចក្ដីសង្ខេបរឿងនេះ ឬទេ ? ចូរបង្ហាញចំណុចស្រប ទាំងនោះ ។

# សព្វនាមឈ្នាប់

សព្វនាមមានច្រើនប្រភេទដូចជា សព្វនាមបុរិសៈ សព្វនាមចង្អុល សព្វនាមសំណួរ សព្វនាមមិនច្បាស់ និងសព្វនាមឈ្នាប់ ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីសព្វនាមឈ្នាប់ ។

ដូចម្ដេចដែលហៅថាសព្វនាមឈ្នាប់ ? តើគេប្រើសព្វនាមឈ្នាប់យ៉ាងដូចម្ដេច ?

ចូរសង្កេតឧទាហរណ៍ខាងក្រោម ៖

១. យើងស្រឡាញ់រាប់អានពូសុខ ។

២. ពូសុខជាមនុស្សទៀងត្រង់ ។

ល្បះទាំងពីរខាងលើនេះ មានពាក្យ " ពូសុខ " ដូចគ្នា ។ យើងអាចបង្រួមល្បះទាំងពីរជាល្បះតែមួយបានដោយយកពាក្យ " ដែល " មកផ្លាស់កន្សោមនាម " ពូសុខ " ។

យើងបានល្បះ ៖

- យើងស្រឡាញ់រាប់អានពូសុខ ដែលជាមនុស្សទៀងត្រង់ ។

ពាក្យ " ដែល " ជាសព្វនាមឈ្នាប់ប្រើជំនួសពាក្យ " ពូសុខ " ។ ល្បះ " ដែលជាមនុស្សទៀងត្រង់ " ជាល្បះរណាប ។

> សព្វនាមឈ្នាប់ ជាពាក្យសម្រាប់ផ្លាស់កន្សោមនាម និងបង្កើតល្បះរណាប ។

សព្វនាមឈ្នាប់មានតែមួយគត់គឺ " ដែល " ។

ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

១. ខ្ញុំគោរពស្រឡាញ់មនុស្ស ដែលគោរពច្បាប់ចរាចរណ៍ ។

២. សែយ៉ាជាសិស្ស ដែលមានសីលធម៌ល្អ ។

៣. ធីតាកំពុងអានសៀវភៅ ដែលនិយាយពីការថែទាំសុខភាព ។

តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថា ៖

- ល្បះទី១ ៖ សព្វនាមឈ្នាប់ " ដែល " ជំនួសនាម " មនុស្ស " ហើយល្បះ " ដែលគោរពច្បាប់ចរាចរណ៍ " ជាល្បះរណប ។
- ល្បះទី២ ៖ សព្វនាមឈ្នាប់ " ដែល " ជំនួសនាម " សិស្ស" ហើយល្បះ " ដែលមានសីលធម៌ល្អ " ជាល្បះរណប ។
- ល្បះទី៣ ៖ សព្វនាមឈ្នាប់" ដែល " ជំនួសនាម " សៀវភៅ " ហើយ ល្បះ" ដែលនិយាយពីការថែទាំសុខភាព" ជាល្បះរណប ។

## លំហាត់

ក. ចូរអានល្បះខាងក្រោម ។ តើសព្វនាមឈ្នាប់ទាំងនេះជំនួសពាក្យណា ? តើឃ្លាណាជាល្បះរណប ?

១. គេតែងគោរពមនុស្ស ដែលប្រកាន់ពាក្យសច្ចៈ ។
២. នេះគឺជាច្បាប់ ដែលយើងទាំងអស់គ្នាត្រូវគោរព ។
៣. គាត់ជាជនពិការ ដែលខិតខំតស៊ូក្នុងជីវិត ។
៤. យើងគោរពស្រឡាញ់ពូសុខ ដែលជាមនុស្សថ្លៃថ្នូរ ។
៥. ខ្ញុំចូលចិត្តមនុស្ស ដែលមានសុជីវធម៌ ។
៦. នេះជាសៀវភៅ ដែលចែងអំពីច្បាប់ចរាចរណ៍ ។
៧. យើងខិតខំធ្វើកិច្ចការ ដែលគ្រូបានដាក់ឱ្យ ។
៨. នេះជាបទបញ្ជាផ្ទៃក្នុងសាលា ដែលសិស្សទាំងអស់ត្រូវអនុវត្ត ។
៩. យើងថែរក្សាប្រាសាទបុរាណ ដែលជាមរតកជាតិយើង ។
១០. គាត់ជាសប្បុរសជន ដែលជួយសង់អគារសិក្សាឱ្យយើង ។

ខ. ចូរតែងល្បះដោយប្រើសព្វនាមឈ្នាប់ឱ្យបានបីល្បះ ។



# កំណាព្យ ៖ បុត្រល្អ



(បទពំនោល)

កុមារយើងជាបុត្រល្អ ទឹកចិត្តស្មោះសរ គោរពមាតាបិតា ។
លោកបីបមថ្នមរក្សា មើលខុសត្រូវណា ណែនាំពន្យល់អប់រំ ។
ទន់ភ្លន់គោរពចាស់ទុំ សុភាពរមទម្យ ប្រកាន់ចរិយាប្រពៃ ។
ការងារមោះមុតវាងវៃ រៀនសូត្រជោគជ័យ មាតាបិតាសប្បាយ ។
នឿយហត់លំបាករសាយ លោកឪពុកអ្នកម្ដាយ សង្ឃឹមអនាគតកូន ។
បុត្រល្អទុកដូចជាក្បូន យិតយោងបងប្អូន ញាតិមិត្តប្រជាមាតុភូមិ ។

## សំណួរ

១. តើកូនល្អត្រូវមានអាកប្បកិរិយាដូចម្ដេចខ្លះ ?

២. តើកូនល្អផ្ដល់សារៈសំខាន់ដូចម្ដេចខ្លះ ?

៣. តើកំណាព្យនេះនិយាយពីអ្វី ?

## លំហាត់

ក. ចូររកពាក្យន័យដូចនឹងពាក្យ ៖ មាតាបិតា សូត្រ បុត្រ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ ៖ ទុំ ចិត្ត ទុក្ខ ។

## សំណេរ

ក. ចូរតែងល្បះនឹងពាក្យក្នុងប្រអប់ខាងក្រោម ក្នុងមួយពាក្យឱ្យបានមួយល្បះ ។

| សរសើរ | ទម្លាប់ | ព្យាយាម | សីលធម៌ | សមរម្យ |
|---|---|---|---|---|

ខ. ចូរសរសេរអត្ថបទពណ៌នាអំពីលំនៅឋានតាមរូបភាព និងគម្រោងខាងក្រោម ។

១. សេចក្ដីផ្ដើម

ទីកន្លែង (ភូមិ ស្រុក ខេត្ត ផ្លូវ)



២. តួសេចក្ដី

- ទិដ្ឋភាពមើលពីចម្ងាយ
- ទិដ្ឋភាពចូលទៅជិត
- ទិដ្ឋភាពខាងក្រៅ
- ទិដ្ឋភាពខាងក្នុង
- ការរៀបចំតុបតែង
- សារប្រយោជន៍ ។

៣. សេចក្ដីបញ្ចប់

ចំណាប់អារម្មណ៍អ្នកសរសេរ ។

# សេចក្ដីថ្លៃថ្នូររបស់មនុស្ស





សេចក្ដីថ្លៃថ្នូរជាគុណសម្បត្តិមួយដ៏ប្រសើរថ្លៃថ្លា ដែលមនុស្សគ្រប់រូបប្រាថ្នាចង់បាន ។ សេចក្ដីថ្លៃថ្នូរនឹងកើតមានចំពោះមនុស្សទាំងឡាយណា ដែលមានភាពស្មោះត្រង់ ប្រកាន់សច្ចៈ យុត្តិធម៌ មានវិន័យ សីលធម៌ និងមានមនសិការវិជ្ជាជីវៈ ។ ប្រទេសណាដែលសម្បូរដោយមនុស្សថ្លៃថ្នូរ ប្រទេសនោះនឹងទទួលបាននូវកេរ្ដិ៍ឈ្មោះប្រសើរលើពិភពលោក ។

មនុស្សមានសីលធម៌សំដៅលើមនុស្ស ដែលមានឥរិយាបថល្អប្រពៃ ចេះគោរពច្បាប់ ចេះជួយគ្នាទៅវិញទៅមក និងចេះរួមរស់ជាមួយគ្នាប្រកបដោយសន្តិភាព ។ សីលធម៌ប្រៀបដូចជាចង្កូតជួយតម្រង់មនុស្សឱ្យដើរតាមផ្លូវល្អ ដែលកើតចេញពីការចេះគោរពប្រតិបត្តិដំបូន្មានល្អៗ ទំនៀមទម្លាប់ប្រពៃណី វិន័យ បទបញ្ញត្តិ និងច្បាប់នៅក្នុងសង្គម ។

មនុស្សមានមនសិការវិជ្ជាជីវៈ គឺជាមនុស្សដែលចេះស្រឡាញ់ការងារ យកចិត្តទុកដាក់នឹងការងារ មានស្មារតីទទួលខុសត្រូវនឹងការងារ ខំប្រឹងប្រែងធ្វើការងារ ខិតខំស្រាវជ្រាវ ច្នៃប្រឌិត និងធ្វើឱ្យការងារនោះមានការរីកចម្រើន ។

ចំណេះវិជ្ជាក៏ជួយមនុស្សឱ្យមានសេចក្ដីថ្លៃថ្នូរដែរ ព្រោះចំណេះវិជ្ជាធ្វើឱ្យមនុស្សចេះគិតពិចារណា ស្គាល់អំពើល្អ អំពើអាក្រក់ អ្វីគួរធ្វើ អ្វីមិនគួរធ្វើ ។ ចំណេះវិជ្ជាកើតឡើងដោយសារការខិតខំព្យាយាមរៀនសូត្រ ។

ដើម្បីឱ្យជីវិតកាន់តែមានតម្លៃថែមទៀតនោះ មនុស្សម្នាក់ៗ គប្បីខិតខំកសាងអំពើល្អ សុចរិតទៀងត្រង់ ។ អំពើទាំងនោះស្ដែងចេញឡើង តាមរយៈការជួយសង្គ្រោះអ្នកដទៃ ការមិនរើសអើង មិនរំលោភសិទ្ធិអ្នកដទៃ ការប្រកាន់យកសច្ចធម៌ជាដើម ។

សេចក្ដីថ្លៃថ្នូរធ្វើឱ្យមនុស្សមានកេរ្ដិ៍ឈ្មោះក្រអូប មានកិត្តិយសថ្កុំថ្កើង រស់នៅសុខសាន្ត ។ សេចក្ដីថ្លៃថ្នូរប្រៀបដូចជាគ្រឿងអលង្ការ ធ្វើឱ្យមនុស្សមានសោភ័ណ ។ ដូច្នេះ មនុស្សគ្រប់រូបត្រូវប្រកាន់យកសេចក្ដីថ្លៃថ្នូរ ទើបយើងអាចរស់នៅប្រកបដោយសុភមង្គលបាន ។

## សំណួរ

១. តើសេចក្ដីថ្លៃថ្នូរកើតឡើងដោយសារកត្តាអ្វីខ្លះ ?

២. តើចំណេះវិជ្ជា សីលធម៌ និងមនសិការវិជ្ជាជីវៈ កើតឡើងយ៉ាងដូចម្ដេច ?

៣. ហេតុអ្វីបានជាមនុស្សត្រូវការសេចក្ដីថ្លៃថ្នូរ ?

## លំហាត់

ក. ចូររកពាក្យដូចសូរនឹងពាក្យខាងក្រោម រួចប្រើវចនានុក្រមដើម្បីពន្យល់ន័យរបស់វា: សុខ បទ កេរ្ដិ៍ វា ។

ខ. ចូររកពាក្យន័យដូចនឹងពាក្យ ៖

សោភ័ណ ផ្លូវ បរិភោគ ។

គ. ចូររកពាក្យន័យផ្ទុយនឹងពាក្យ ៖

សុភមង្គល ថ្លៃថ្នូរ វិជ្ជា សីលធម៌ ក្រអូប គុណ ។

ឃ. ចូរសរសេរសង្ខេបអត្ថបទឡើងវិញ ។

# ការរៀបរាប់ពីមនុស្សថ្លៃថ្នូរ

ការរៀបរាប់ពីមនុស្ស ត្រូវផ្អែកលើលក្ខណៈពីរសំខាន់គឺ រូបសម្បត្តិ និងចរិយាសម្បត្តិ ។ តើការរៀបរាប់ពីមនុស្សថ្លៃថ្នូរ គេនិយាយទៅលើចំណុចអ្វីខ្លះ ? ចូរអានការសន្ទនាខាងក្រោម ។

មករា : តើអ្នកទាំងអស់គ្នាស្គាល់ពូដួងទេ ? ពូដួងជាកូនអ្នកក្រីក្រម្នាក់ តែគាត់ជាមនុស្សឧស្សាហ៍ព្យាយាមរៀនសូត្រណាស់ ។ សព្វថ្ងៃ គាត់ក្លាយជាគ្រូពេទ្យដ៏ពូកែម្នាក់នៅស្រុកខ្ញុំ ។

សារិន : នៅក្នុងស្រុក អ្នកណាក៏ស្គាល់ហើយគោរព សរសើរពូដួងដែរ ។ គាត់មានទឹកមុខញញឹម ចរិតស្លូតបូត រាក់ទាក់ មិនរើសអើងឡើយ ។

ចរិយា : គ្រួសារខ្ញុំចូលចិត្តគាត់ណាស់ ។ គ្រូពេទ្យដួង មិនត្រឹមតែពូកែព្យាបាលជំងឺទេ តែគាត់ជាមនុស្សមានចិត្តទូលាយ ជួយទុក្ខធុរៈអ្នកដទៃដោយស្មោះមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។ ពេលអ្នកស្រុកមានជំងឺមកពឹងពាក់គាត់ទៅព្យាបាលមិនថាយប់ ឬថ្ងៃ ដោយមិនគិតពីការនឿយហត់ឡើយ ។

សារិន : មែនហើយ! គ្រូពេទ្យដួង ជាមនុស្សថ្លៃថ្នូរគួរឱ្យគោរព និងយកតម្រាប់តាម ។

## សំណួរ

១. តើគេរៀបរាប់ពីអ្នកណា ?

២. តើគេធ្វើការរៀបរាប់ចំណុចសំខាន់ៗអ្វីខ្លះ ?

៣. តើចំណុចណាខ្លះ ដែលបង្ហាញពីលក្ខណៈថ្លៃថ្នូររបស់មនុស្ស ?

## លំហាត់

ចូររៀបរាប់អំពីមនុស្សថ្លៃថ្នូរណាម្នាក់នៅក្នុងសហគមន៍ ដែលអ្នកធ្លាប់ស្គាល់ ។

# សង្ខេបរឿងនិទាន

សង្ខេបរឿង គឺសរសេរសាច់រឿងឱ្យខ្លី ដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួន ដើម្បីឱ្យងាយស្តាប់បាន និងងាយយល់ពីខ្លឹមសារសំខាន់ៗនៃរឿងនោះ ។ អ្នកសរសេរត្រូវធ្វើការបញ្ចូលគំនិតដែលមាននៅក្នុងរឿងឱ្យបានច្បាស់លាស់ទៅតាមគោលសំខាន់នីមួយៗ ដោយមិនត្រូវយកផ្នែកមិនសំខាន់មកបញ្ចូលទេ ។ ដើម្បីសង្ខេបអត្ថបទ អ្នកត្រូវអនុវត្តតាមជំហានបន្តបន្ទាប់ដូចខាងក្រោម ៖

១. អានអត្ថបទរឿង និងស្វែងយល់ខ្លឹមសារឱ្យបានច្បាស់លាស់ជាមុន

២. ស្រង់ព្រឹត្តិការណ៍សំខាន់ ឬខ្លឹមសារសំខាន់របស់រឿង

៣. ប្រមូលគំនិត ឬព្រឹត្តិការណ៍បន្ទាប់បន្សំដែលមាននៅក្នុងព្រឹត្តិការណ៍ធំនីមួយៗ

៤. រៀបចំគំនិត ឬព្រឹត្តិការណ៍តាមលំដាប់មុនក្រោយ

៥. សរសេររឿងនោះឡើងវិញ ដោយផ្អែកលើគម្រោងដែលបានធ្វើរួច ។ ដើម្បីសរសេរអ្នកប្រើកន្សោមពាក្យ ឬឃ្លាភ្ជាប់សេចក្តី ដើម្បីភ្ជាប់គំនិតឬព្រឹត្តិការណ៍មួយទៅព្រឹត្តិការណ៍មួយទៀតឱ្យជាប់រដឹកតាំងពីដើមរហូតដល់ចប់ ។

## លំហាត់

ចូរអ្នកអានរឿងខាងក្រោម រួចសរសេរសង្ខេបរឿងនេះឡើងវិញឱ្យបានសមស្រប ។

### រឿង កុមារស្មោះត្រង់

សុធា ជាកុមារកំព្រាឪពុករស់នៅក្នុងគ្រួសារក្រីក្រមួយ ។ ម្តាយសុធា រស់នៅក្នុងដីភូមិរបស់អ្នកជិតខាងម្នាក់ ។ សព្វថ្ងៃ សុធារៀនថ្នាក់ទី៦ ។ ម្តាយសុធា ប្រកបរបរលក់ចេកចៀននៅតាមចិញ្ចើមផ្លូវ ។ ក្រៅពីទៅរៀន សុធាតែងមកជួយការងារម្តាយជារៀងរាល់ថ្ងៃ ។ ដោយជីវភាពជួបការលំបាក សុធាចង់ឈប់រៀន ។ គេនិយាយជាមួយម្តាយ ៖

- ម៉ែ! កូនគិតឈប់រៀនហើយ កូនចង់ទៅរកស៊ីឈ្នួលគេ ឬក៏ដើរលក់កាសែតដើម្បីបានប្រាក់ជួយម៉ែខ្លះ ។

- ទេ! កូនមិនអាចឈប់រៀនបានទេ ទោះជាលំបាកយ៉ាងណាក៏ដោយ ព្រោះថាបើកូនឈប់រៀននោះ អនាគតកូននឹងលំបាកដូចជាម៉ែអ៊ីចឹង ។ ម៉ែសុខចិត្តលំបាកគ្រប់បែបយ៉ាង តែមិនឱ្យកូនឈប់រៀនទេ ។

ថ្ងៃមួយ នៅពេលកំពុងឃ្លរចេកចៀនយកទៅឱ្យគេ សុធាបានឃើញបុរសម្នាក់ជ្រុះកាបូបពីហោប៉ៅ ហើយដើរទៅបាត់ ។ សុធារើសបម្រុងនឹងយកទៅឱ្យម្ចាស់គេវិញ ប៉ុន្តែដោយមនុស្សច្រើនពេករកម្ចាស់មិនឃើញ ។ សុធាវេរា មិនដឹងគិតធ្វើដូចម្ដេចឡើយ ។ ស្អែកឡើងសុធា យកកាបូបនោះទៅជូនអ្នកគ្រូនៅឯសាលា ។ អ្នកគ្រូសួរសុធា៖

- ឯងមានការអ្វីបានជាត្រហេបត្រហបម្ល៉េះ សុធា ?
- បាទអ្នកគ្រូ! ខ្ញុំរើសបានកាបូបមួយ!
- ចុះឯងរើសបានវានៅឯណា ?
- ខ្ញុំរើសបាននៅក្បែរផ្សារ ។

អ្នកគ្រូពិនិត្យមើលក្នុងកាបូបនោះ ឃើញមានលិខិតឆ្លងដែន ប័ណ្ណធនាគារ និងប្រាក់មួយចំនួនទៀត ។ គាត់បាននាំសុធាយកកាបូបនោះ ទៅប្រគល់ឱ្យប៉ុស្តិ៍នគរបាល ។ នគរបាល បានសរសើរពីសេចក្ដីស្មោះត្រង់របស់សុធា ។ គាត់សន្យាថា នឹងខំរកម្ចាស់របស់នោះឱ្យឃើញ ហើយប្រគល់ឱ្យម្ចាស់គេវិញ ។

បីថ្ងៃក្រោយ ស្រាប់តែនគរបាលនាំមនុស្សចម្លែកម្នាក់មកសួររកសុធានៅក្នុងសាលារៀន ។ សុធាងឿងឆ្ងល់ណាស់ តែក្រោយមកនគរបាលបានប្រាប់ថា គាត់ជាម្ចាស់កាបូបដែលសុធារើសបានពីថ្ងៃមុន ។ គាត់ជាអាណិកជនខ្មែររស់នៅសហរដ្ឋអាមេរិច ហើយជាប្រធានក្រុមហ៊ុនមួយនៅស្រុកយើងផង ។ បុរសនោះ ពេញចិត្តខ្លាំងណាស់នឹងទឹកចិត្តស្មោះត្រង់របស់សុធា គាត់ពោលទៅកាន់សុធា៖ " ខ្ញុំត្រូវការមនុស្សស្មោះត្រង់ ដើម្បីធ្វើការជាមួយ តែឥឡូវនេះ ក្មួយនៅក្មេងណាស់ ក្មួយត្រូវខំរៀនសូត្រសិន ។ ចាប់ពីពេលនេះ ពូជាអ្នកទំនុកបម្រុងក្មួយរហូតដល់រៀនចប់ ហើយពូនឹងយកក្មួយទៅធ្វើការនៅក្រុមហ៊ុនពូ" ។

ចាប់តាំងពីពេលនោះមក សុធាខិតខំរៀនសូត្រដោយមិនមានភ័យព្រួយពីការខ្វះខាតអ្វីទៀតឡើយ ។

# រឿង បុរសចិត្តធម៌



មានសេដ្ឋីម្នាក់បានធ្វើដំណើរទៅធ្វើបុណ្យនៅឯស្រុកកំណើតរបស់ខ្លួន ។ នៅតាមផ្លូវគាត់បានជួបនឹងពួកចោរមួយក្រុម ។ ពួកចោរបានវាយដំគាត់ ដណ្តើមយកមាសប្រាក់ រហូតដល់ធ្វើឱ្យគាត់សន្លប់បាត់ស្មារតី ។ ពួកវាបានប្រមូលយកមាសប្រាក់គាត់អស់ រួចគេចខ្លួនបាត់ទៅ ។

មួយស្របក់ក្រោយមក មានស្ត្រីចំណាស់ម្នាក់បានដើរឆ្លងកាត់ទីនោះ ។ ស្ត្រីនោះបានឃើញសេដ្ឋីរងគ្រោះថ្នាក់ដែរ តែគាត់មិនដឹងធ្វើដូចម្តេច ព្រោះខ្លួនគាត់ចាស់ ខ្សោយកម្លាំងមិនអាចធ្វើអ្វីបានឡើយ ។ គាត់ក៏បន្តដំណើរទៅមុខទៀត ។

មិនយូរប៉ុន្មាន មានប្តីប្រពន្ធពីរនាក់បានធ្វើដំណើរដោយរទេះសេះតាមផ្លូវនោះដែរ ។ នៅពេលរទេះសេះបរទៅដល់ទីនោះ ក៏ឃើញមនុស្សដួលនៅចិញ្ចើមផ្លូវដែរ តែពួកគាត់មិនបានឈប់បង្អង់ទេ ព្រោះគាត់ប្រញាប់ខ្លាំងណាស់ ។

លុះដល់ថ្ងៃរសៀល មានបុរសកម្សត់ម្នាក់បានធ្វើដំណើរឆ្លងកាត់ទីនោះក៏បានជួបសេដ្ឋី ដែលកំពុងសន្លប់មិនដឹងខ្លួន ។ ឃើញដូច្នោះ គាត់ក៏ប្រញាប់ជួយគ្រាហ៍សេដ្ឋីនោះ យកទៅដាក់ក្នុងខ្ទមរបស់ស្ត្រីម្នាក់ ដែលនៅមិនឆ្ងាយប៉ុន្មានពីទីនេះ ។គាត់បានជួយគក់ច្របាច់រឹត ដុតភ្លើងកម្តៅរហូតដល់បុរសនោះធូរស្រាល ។ គាត់បានសូមឱ្យស្ត្រីម្ចាស់ខ្ទម ជួយដាំបបរជូនអ្នករងគ្រោះហូបនៅពេលគាត់ដឹងខ្លួន ។ បន្ទាប់មក គាត់ក៏ចាកចេញទៅ ។

ក្រោយមក សេដ្ឋីរងគ្រោះបានដឹងខ្លួន ។ គាត់បានថ្លែងអំណរគុណចំពោះស្ត្រីម្ចាស់ខ្ទម ។ ស្ត្រីនោះបានប្រាប់គាត់ថា អ្នកដែលបានជួយគាត់នោះ មិនមែនគាត់ទេ គឺជាបុរសកម្សត់ម្នាក់ ។ ឥឡូវនេះ គេបានចាកចេញទៅបាត់ហើយ ។

## សំណួរ

១. តើមានរឿងអ្វីកើតឡើងចំពោះសេដ្ឋី ?

២. តើមនុស្សប៉ុន្មាននាក់បានឃើញសេដ្ឋីសន្លប់ ?

៣. តើអ្នកណាបានជួយសេដ្ឋី ?

៤. តើអ្នកយល់ថា បុរសកម្សត់ជាមនុស្សដូចម្ដេច ?

៥. តើអ្នកពេញចិត្តតួអង្គណាខ្លះ នៅក្នុងរឿងនេះ ? ហេតុអ្វី ?

៦. ប្រសិនបើអ្នកជួបរឿងបែបនេះ តើអ្នកដោះស្រាយដូចម្ដេច ដើម្បីជួយជនរងគ្រោះឱ្យផុតពីគ្រោះថ្នាក់ ?

## លំហាត់

១. ចូរជ្រើសរើសពាក្យដែលមានន័យត្រូវនឹងពាក្យខាងដើម ។

- សេដ្ឋី ៖ ☐ អ្នកធំ ☐ អ្នកមានធំ ☐ អ្នកមានអំណាច ។
- ស្មារតី ៖ ☐ ការភ្លេចភ្លាំង ☐ ការភ័យស្លុត ☐ ការចាំបាន ។
- បុរស ៖ ☐ ប្រុស ☐ អ្នកបានបួស ☐ អ្នកចិត្តល្អ ។

២. ចូររកពាក្យសូរដូចនឹងពាក្យ “ ក៏” ។

៣. ចូរស្រង់ព្រឹត្តិការណ៍នៃរឿងតាមលំដាប់លំដោយ ។

៤. ចូរស្រង់នាមនៅក្នុងអត្ថបទខាងលើ ។

៥. ចូរស្រង់គុណនាមនៅក្នុងអត្ថបទខាងលើ ។

៦. ចូរស្រង់កិរិយានៅក្នុងអត្ថបទខាងលើ ។

៧. ចូរស្រង់សព្វនាមនៅក្នុងអត្ថបទខាងលើ ។

## សំណេរពាក្យ ល្បះ និងកំណាព្យ

ក. ចូរអានពាក្យក្នុងប្រអប់ រួចស្រង់នាម គុណនាម កិរិយា និងសព្វនាមដាក់ដោយឡែកពីគ្នា ។

| |
|---|
| កសិករ ធ្វើ កូន ឪពុក គាត់ ឧស្សាហ៍ ការងារ ខ្ញុំ ស្រឡាញ់ ជា ល្អ បាន ប្រកប មនុស្ស ប្រសើរ មុខរបរ ស្របច្បាប់ ចិញ្ចឹម |

នាម ៖ ..........................................................................

គុណនាម ៖ ..........................................................................

កិរិយា ៖ ..........................................................................

សព្វនាម ៖ ..........................................................................

ខ. ចូរបង្កើតល្បះនឹងពាក្យក្នុងប្រអប់ឱ្យបានជាល្បះ ។ ( ពាក្យខ្លះអាចប្រើបានច្រើនដង )

គ. ចូររៀបឃ្លាកំណាព្យក្នុងវគ្គនីមួយៗខាងក្រោម ឱ្យត្រូវតាមទម្រង់នៃបទកាកគតិ ។

### បទកាកគតិ

បើចង់មានមិត្ត មិនត្រូវប្រព្រឹត្ត
អំពើឆ្គាំឆ្គង បើចង់មានទ្រព្យ
ប្រឹងប្រែងរកផង កុំលោតរំលង
ច្បាប់បានថែងស្រាប់ ។

បើចង់បានសុខ កុំធ្វើអុកឡុក
ត្រូវមានសណ្ដាប់ អ្នកកុំក្អេងក្អាង
ឱ្យបានគួរគាប់ ផុតខាងរករាប់
ទើបសុខកើតមាន ។

## តែសអំណាន

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ៖

# រឿង សត្វស្លាបនិងដំរី

មានដើមឈើធំមួយ ដុះនៅកណ្តាលព្រៃមួយ ។ សត្វស្លាបតូចមួយបានធ្វើសម្បុកជាជម្រកដល់កូនតូចៗ៣ នៅចុងឈើនោះ ។

ថ្ងៃមួយ ដំរីមួយបានមកដល់ ហើយព្យាយាមអង្រួនដើមឈើនោះ ។ ដើមឈើក៏ទោរទន់មកដី ។ កូនសត្វភ័យខ្លាំង ក៏រត់មកត្រដុសមេវា ។ ពេលនោះ មេវាបានបញ្ចេញចំពុះមកក្រៅសម្បុកហើយនិយាយទៅកាន់ដំរី ៖“ អេ! សត្វដ៏សម្បើម នៅជុំវិញទីនេះមានដើមឈើច្រើនណាស់! ហេតុអ្វីក៏អ្នកមកអង្រួនដើមឈើមួយនេះ ? កូនខ្ញុំខ្លាចណាស់ ហើយអាចធ្លាក់ពីសម្បុក” ។

ដំរីនៅស្ងៀម តែវាសម្លឹងមើលសត្វស្លាបដោយភ្នែកដ៏តូចរបស់វា ។ វាបក់ស្លឹកត្រចៀកដ៏ធំរបស់វាឮសូរភឹបៗ រួចចាកចេញពីទីនោះ ។

ស្អែកឡើង ដំរីត្រឡប់មកអង្រួនដើមឈើនោះម្តងទៀត ។ ដើមឈើក៏ទោរទន់មកដី ។ កូនសត្វភ័យរន្ធត់ ក៏រត់មកត្បុលក្បាលចូលក្នុងស្លាបមេវាទៀត ។ ម្តងនេះ មេខឹងខ្លាំងក៏ស្រែក ៖ “ ខ្ញុំនឹងឱ្យមេរៀនមួយដល់អ្នក!” ។

ឮដូច្នោះដំរីសើចចំអក ៖“ តើអ្នកអាចធ្វើអ្វីដល់អ្នកដែលមានមាឌធំដូចខ្ញុំ ? បើខ្ញុំចង់ ខ្ញុំអាចទង្គិចដើមឈើឱ្យសម្បុកនិងកូនរបស់អ្នកខ្ទាតទៅឆ្ងាយបាន” ។ សត្វស្លាបក៏នៅស្ងៀម ។

ថ្ងៃបន្ទាប់ ដំរីវិលមកអង្រួនដើមឈើនោះជាថ្មីម្តងទៀត ។ មួយរំពេចនោះ សត្វស្លាបបោះពួយលឿនដូចព្រួញ ចូលក្នុងត្រចៀកដំរី ហើយខ្វេះខ្វាចគ្មានប្រណី ។ ដំរីខំគ្រវីក្បាល ឱ្យសត្វជ្រុះតែឥតប្រយោជន៍ ។ ដោយទាល់ចំណោះ ដំរីក៏អង្វរ សត្វស្លាបឱ្យហើរចេញ ហើយសន្យាថា នឹងឈប់មកអង្រួនដើមឈើនេះទៀតហើយ ។

ទីបំផុត សត្វស្លាបក៏សុខចិត្ត ធ្វើតាមការអង្វររបស់ដំរី ។ វាក៏ហើរចេញពីត្រចៀកដំរី ។ ដំរីក៏ដើរចេញពីទីនោះ ហើយលែងវិលមកអង្រួនដើមឈើនោះទៀត ។

សំណួរ

ចូរអ្នកគូសសញ្ញា ✓ នៅក្នុងប្រអប់ ខាងមុខចម្លើយត្រឹមត្រូវមួយ ។

១. តើសត្វស្លាបតូចមួយរស់នៅឯណា ?

- ☐ នៅក្នុងព្រៃមួយ
- ☐ នៅលើចុងឈើ
- ☐ នៅជិតគល់ឈើ ។

២. តើមានអ្វីកើតឡើងចំពោះសត្វស្លាប ?

- ☐ សត្វដំរីអង្រួនដើមឈើដែលវារស់នៅ
- ☐ សត្វដំរីមកប្រទ្បែងកូនវា
- ☐ សត្វដំរីចង់ស៊ីកូនវា ។

៣. តើកូនសត្វតូចៗមានអារម្មណ៍ដូចម្ដេច ពេលដំរីអង្រួនដើមឈើ ?

- ☐ កូនសត្វរីករាយ
- ☐ កូនសត្វរំភើប
- ☐ កូនសត្វភ័យខ្លាច ។

៤. តើដំរីមកអង្រួនដើមឈើប៉ុន្មានដង ?

- ☐ ពីរដង
- ☐ បីដង
- ☐ បួនដង ។

៥. ហេតុអ្វីបានជាដំរីអង្រួនដើមឈើ ?

- [ ] ព្រោះវាចង់លេងជាមួយសត្វតូចៗ
- [ ] ព្រោះវាចង់ធ្វើបាបសត្វតូចតាច
- [ ] ព្រោះវាស្អប់សត្វស្លាបតូចៗ ។

៦. តើសត្វស្លាបធ្វើដូចម្ដេចដើម្បីផ្ដល់មេរៀនដល់ដំរី ?

- [ ] វាហើរចូលត្រចៀកដំរី
- [ ] វាហើរទៅចឹកដំរី
- [ ] វានៅស្ងៀមព្រោះខ្លាចដំរី ។

៧. តើដំរីនិងសត្វស្លាបអ្នកណាជាអ្នកឈ្នះ ?

- [ ] សត្វស្លាបឈ្នះ
- [ ] ដំរីឈ្នះ
- [ ] គ្មានអ្នកចាញ់និងអ្នកឈ្នះ ។

៨. តើដំរីជាសត្វដូចម្ដេចនៅក្នុងរឿងនេះ ?

- [ ] ជាសត្វស្លូតបូត
- [ ] ជាសត្វស្រឡាញ់សត្វឯទៀត
- [ ] ជាសត្វឈ្នានីសគេ ។

៩. តើសត្វស្លាបជាសត្វដូចម្ដេច ?

- [ ] សត្វឈ្លាសវៃ
- [ ] សត្វកាចសាហាវ
- [ ] សត្វសុខចិត្តចុះចាញ់គេ ។

១០. តើរឿងនេះចង់អប់រំដូចម្ដេច ?

☐ អ្នកធំមិនត្រូវអត់ឱនឱ្យអ្នកតូច

☐ អ្នកធំត្រូវរៀនសូត្រពីអ្នកតូច

☐ អ្នកធំមិនត្រូវមើលងាយអ្នកតូចតាច ។

១១. តើរឿងនេះមានតួអង្គប៉ុន្មាន ?

☐ តួអង្គបី

☐ តួអង្គពីរ

☐ តួអង្គប្រាំ ។

១២. ចូរស្រង់ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងរឿងខាងលើ ។

១៣. តើរឿងនេះបញ្ចប់ដូចម្ដេច ?

☐ តួអង្គខ្លាំងឈ្នះតួអង្គខ្សោយ

☐ តួអង្គល្អស្លាប់ទាំងអស់

☐ តួអង្គអាក្រក់សុខចិត្តចុះចាញ់ ។

# បទានុក្រម

## ក

កញ្ចាំង (កញ់ - ចាំង) *ន.* ឈ្មោះក្បាច់រចនាមានទំនងផ្សេងៗដែលហៅថា ក្បាច់កញ្ចាំង ច្រើនធ្វើពីស្ពាន់ក្រាប ។

កតញ្ញូ (ក:-ត័ញ-ញូ) *ន.* អ្នកដឹងគុណ អ្នកដែលមិនរមិលគុណគេ ។

កត្តា (ក័ត-តា) *ន.* អ្នកធ្វើ អ្នកផ្តើមធ្វើ ។

កន្ទោង (កន់-ទោង) *ន.* ភាជន៍ធ្វើដោយស្លឹកសម្រាប់ដាក់ ភោជនាហារ ដាក់ស្លាបារីបាន ។

កាមគុណ *ន.* ដំណើរចម្រើននៃសេចក្តីប្រាថ្នានូវអារម្មណ៍ទាំង៥គឺ រូប សំឡេង ក្លិន រស សម្ផស្ស ។

ការណ៍ (កា) *ន.* ហេតុ ដំណើរ : សេចក្តីរាយការណ៍ ។

កិច្ចការ (កិច-កា) *ន.* ការដែលត្រូវធ្វើ ការរវល់ ។

កិត្តិយស (កិត-តិ -យស់) *ន.* យសសក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង ។

កិលេស *ន.* សេចក្តីសៅហ្មងចិត្ត ។

កុដិ (កុត) *ន.* ខ្ទម ផ្ទះ លំនៅរបស់អ្នកបួស ។

កុដុម្ពិក: (កុ-ដុំ-ពីពិ-ក:) *គុ.* អ្នកមានសម្បត្តិដោយផលប្រយោជន៍កើតអំពីស្រែ ចម្ការ ដំណាំ ។

កុសល (កុ-សល់) *ន.* កម្មដែលកម្ចាត់បង់នូវអំពើអាក្រក់ ។ *គុ.* ដែលល្អប្រពៃ ដែលជាបុណ្យ ។

កុហក (កុ-ហក់) *គុ.* ដែលបំភាន់ជំនឿគេ ។

កេរ្តិ៍ (កេ) *ន.* សេចក្តីសរសើរ ការល្បី : កេរ្តិ៍ឈ្មោះ ។

ក្តីក្តាំ *ន.* វិវាទធម្មតា ។

ក្បួន *ន.* របស់ដែលចងជាដុំឱ្យអណ្តែតទឹក : ក្បួនឫស្សី ។

ក្រិត្យក្រម *ន.* លំដាប់នៃកិច្ច ។

ក្រុមហ៊ុន *ន.* ការដាក់ដើមទុនចូលគ្នាដើម្បីរកស៊ី ។

ក្សាន្ត (ក្សាន) *គុ.* ដែលស្ងប់ស្ងាត់ចាកក្តីទុក្ខ ។

ក្សេមក្សាន្ត *គុ.* ដែលមានសេចក្តីសុខសាន្ត ។

## ខ

ខន្ធ (ខ័ន) *ន.* ក ដើម គំនរ ពួក កង កំណត់ : ខន្ធ៥ មានរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។

ខ្ញុំស្រី ន. អ្នកបម្រើស្រី ។

ខ្នើត ន. ពន្លឺដែលកើតតាមលំដាប់ថ្ងៃ គឺចំណែកខែខាងដើមដែលមានពន្លឺព្រះចន្ទមកដល់ថ្ងៃពេញបូណ៌មីគឺ តាំងពីថ្ងៃ ១ កើត មកដល់ ១៥ កើត ថ្ងៃតពីនេះទៅហៅថា រនោច ។

## គ

គង្គា (គង់-គា) ន. ទឹក ។

គម្ពីរ (គុំ-ពី) ន. សាស្ត្រាច្បាប់ ធម្មវិន័យ ដែលរួបរួមដោយពួក ដោយប៉ែក ដោយខ្សែ ។

គុណ (គុណ) ន. អំពើល្អគួរគោរពតបស្នង ។

គុណធម៌ (គុន-ធ័រ) ន. សេចក្ដីល្អ សេចក្ដីបរិសុទ្ធ សេចក្ដីអាណិតអាសូរ ។

គុណភាព ន. របស់ដែលមានអានុភាពសក្ដិសិទ្ធិ ។

គុណសម្បត្តិ (គុន -ស័ម -ប័ត) ន. ការបរិបូណ៌ដោយសេចក្ដីល្អ សេចក្ដីបរិសុទ្ធ : មនុស្សនេះមានគុណសម្បត្តិគួរឱ្យសរសើរ ។

គុម្ព (គុំ) ន. ពួក ប្រជុំដើមឈើ ឬដំណាំផ្សេងៗ ។

គោរព (គោ-រប់) កិ. ប្រតិបត្តិតាម យកចិត្តទុកដាក់ ឱនលំទោន ។

គ្រូបាអាចារ្យ (គ្រូ-បា-អា-ចា) ន. គ្រូឧបជ្ឈាយ៍ ។

## ច

ចង្ហាន់ (ចង់ -ហាន់ ) ន. អាហារសម្រាប់ព្រះសង្ឃ ។

ចម្រាញ់ (ចំ-រ៉ាញ់) កិ. រំងាស់ សំរេងឱ្យដាច់ទឹក : ចម្រាញ់យកប្រេង ។

ចរាចរណ៍ (ចៈ-រ៉ា -ច) ន. ការដើរទៅមក ដំណើរតាមផ្លូវសាធារណៈ ។

ចរិត (ចៈ- រ៉ិត ) ន. ការប្រព្រឹត្តិ កិរិយា មារយាទ ឬកពា បែបបទ : ចរិតល្អ ។

ចរិយាសម្បត្តិ (ចៈ-រិ- យ៉ា- សំ- ប័ត ) ន. ការបរិបូណ៌ដោយការប្រព្រឹត្តល្អ ។

ចលនា (ចៈ- ល៉ៈ- ន៉ា) ន. ការមិនតាំងនៅស្ងៀម ដំណើររវើកជានិច្ច ។

ចីវរ (ចី- វ ) ន. គ្រឿងស្លៀកដណ្ដប់សម្រាប់អ្នកបួសក្នុងពុទ្ធសាសនា ។

## ញ

ញាណ (ញាន) ន. សេចក្ដីដឹង ប្រាជ្ញា ។

ញាតកា (ញា- តៈ- កា) ន. ពួកញាតិ ។

ញាតិ (ញាត) ន. អ្នកដែលរួមខ្សែលោហិតជាមួយគ្នាខាងម្ដាយ ឬខាងឪពុក ។

ញ៉ាំង	អា.និ. ប្រើ , បង្គាប់ : គ្រូញ៉ាំងសិស្សឱ្យរៀន , ញ៉ាំងចិត្តឱ្យជ្រះថ្លា ។

## ត

**តន្ត្រី** (ដន់-ត្រី) *ន.* គ្រឿងភ្លេងខ្សែ គ្រឿងភ្លេងដេញ ដំ ផ្លុំ កូត : ប្រគំតន្ត្រី ។

**តួអង្គ** (តួ-អង់) *ន.* មនុស្ស សត្វ រុក្ខជាតិដែលមានសកម្មភាពនៅក្នុងរឿង ។

**ត្រៃសរណគមន៍** (ត្រៃ-សៈ-រៈ-ណៈ-គំ) *ន.* ការដល់នូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំង៣ ជាទីរឭក ឬជាទីពឹង គឺជឿព្រះរត្នត្រ័យទាំង៣នេះស៊ប់ថា ជាទីរឭក ឬជាទីពឹងដ៏ប្រសើរបំផុត ។

## ថ

**ថវិកា** (ថៈ-វិ-កា) *ន.* បញ្ជីដែលគ្រោង ឬកត់ត្រានូវប្រាក់ចំណូល និងចំណាយរៀងរាល់ឆ្នាំ , ប្រៀបដូចជាថង់សម្រាប់ដាក់ប្រាក់ លុយ ។

**ថ្លៃថ្នូរ** *គុ.* មានតម្លៃគួរលើកសរសើរ គួររាប់អាន : មនុស្សនេះ ឫកថ្លៃថ្នូរណាស់ ។

## ទ

**ទស្សនៈ** (ទ័ស-សៈ-ន៉ៈ) *ន.* ដំណើរយល់ឃើញ ការឃើញ ។

**ទាសី** *ន.* ខ្ញុំស្រី ខ្ញុំបម្រើស្រី ។

**ទិដ្ឋភាព** (ទិត-ឋៈ-ភាប) *ន.* ភាពនៃអ្វីៗដែលគេបានឃើញ បានជួបប្រទះមកហើយ ។

**ខុយមុយ** *គុ.* ដែលមួយៗ យឺតៗ ភ្លឹះៗ មិនសូវនិយាយស្តី ។

**ទូន្មាន** (ទូន- មាន) *កិ.* អប់រំ ប្រៀនប្រដៅ ណែនាំ ។

**ទេសនា** (ទេសៈ-ន៉ា) *ន.* ការសម្តែងធម៌( ដូចគ្នានឹងទេសន៍ដែរ) ។

**ទោសា** *ន.* កំហឹង ។

**ទំនៀមទម្លាប់** *ន.* ប្រពៃណី បែបបទ សណ្តាប់ធ្នាប់ដែលធ្លាប់អនុវត្តតៗគ្នាមក ។

**ទោស័ក** *ន.* ស័កទី២នៃឆ្នាំ ក្នុងចំនួនស័កឆ្នាំទាំងដប់ ។

**ទ្រព្យ** (ទ្រ័ប) *ន.* វត្ថុ ធនធាន សម្បត្តិ ។

**ទ្រឹស្តី** (ទ្រឹស- ស្តី ជើងដ) *ន.* ការយល់ឃើញដោយគំនិត ប្រាជ្ញា យោបល់ គោលការណ៍ដែលពន្យល់ចង្អុលប្រាប់ដំណើរទំនងនៃកិច្ចការទាំងពួងដែលត្រូវធ្វើយ៉ាងណាៗ ។

## ធ

**ធនធាន** (ធន់-ធាន) *ន.* សម្បត្តិទ្រព្យរបស់ផ្សេងៗដែលគង់នៅ ។

**ធនាគារ** (ធៈ-នា-គា) *ន.* ឃ្លាំងប្រាក់ ឃ្លាំងដាក់ទ្រព្យ កន្លែងផ្ញើប្រាក់ ។

ធនាគារឥណទាន (ធៈ-នា-គា-អ៊ិ-ណៈ-ទាន) *ន.* ធនាគារឱ្យខ្ចីប្រាក់ ។

ធាតុ (ធាត) *ន.* សភាវៈ ឬធម្មជាតិទ្រទ្រង់ខ្លួនឯង មានទឹក ដី ភ្លើង ខ្យល់ ។ អាការ : ក្នុងខ្លួនមានសក់ ធ្មេញ សាច់ ឈាមជាដើម ។

ធុរៈ *ន.* ការរវល់ ដំណើរជំពាក់ដោយកិច្ចការ : ខ្ញុំទៅមិនបានដោយមានធុរៈ ។

## ន

នគរបាល (ន-គ-បាល) *ន.* អ្នករក្សានគរ ប៉ូលីស ។

ន័យ *ន.* ការណែនាំ សេចក្ដីពន្យល់ ហេតុ ទំនង លំនាំ ។

នាគ (នាក) *កិ.* កូនប្រុសដែលមានសេចក្ដីធុញទ្រាន់ចំពោះការនៅគ្រប់គ្រងផ្ទះ មានចិត្តជ្រះថ្លាចូលទៅសូមបួសក្នុងសំណាក់សាសនា ។

និព្វាន (និប-ពាន) *ន.* ឈ្មោះធម្មជាតិ ឬចិត្តដែលចេញផុតស្រឡះ ចាកតណ្ហា ទាក់ទាក់នៅក្នុងសន្តានចិត្ត ។

និមន្ត (និ-មន់) *កិ.* អញ្ជើញ សូមឱ្យទៅ សូមឱ្យមក : និមន្តព្រះសង្ឃ ។

និស្ស័យ (និស-សៃ) *ន.* ដំណើរ ឬគុណសម្បត្តិដែលមានពីកំណើតស្រាប់ : គាត់មាននិស្ស័យខាងវង់ភ្លេង ។

និស្សិត (និស-សិត) *ន.* អ្នករៀនដែលនៅក្នុងការគ្រប់គ្រងនៃគ្រូ ។

## ប

បង្សុកូល (ប័ង-សុ-កូល) *ន.* ឈ្មោះពិធីម្យ៉ាងក្នុងព្រះពុទ្ធសាសនា ដែលគេនិមន្តព្រះសង្ឃឱ្យចាប់កាន់អំបោះ ឬផ្ទាំងសំពត់ដែលតភ្ជាប់ពីសាកសព ឬអដ្ឋិធាតុរួចទាញយកមកប្រើប្រាស់តាមពុទ្ធានុញ្ញាត ។

បីបាច់ *កិ.* ថែរក្សាដោយយកចិត្តទុកដាក់ ។ បីបាច់រក្សា ថែរក្សាដោយការចាំបាច់ ។

ប័ណ្ណធនាគារ (ប័ន-ធៈ-នា- គា ) *ន.* លិខិត ឬប័ណ្ណ (កាត)សម្រាប់ម្ចាស់កម្មសិទ្ធិដែលមានរបស់ដាក់ក្នុងធនាគារ ។

បទបញ្ញត្តិ (បត់-ប័ញ-ញាត់ ) *ន.* សេចក្ដីហាមប្រាម បម្រាប់ សេចក្ដីដែលគេតែងតាំង ឬរៀបចំ ។

បច្ច័យ (ប៉ុច -ចៃ) *ន.* គ្រឿងអាស្រ័យសម្រាប់បព្វជិត ។ ហេតុដែលនាំឱ្យផលប្រព្រឹត្តទៅ ។

បច្ចេកទេស (ប៉ុច-ចេកៈ-ទេស) *ន.* ចំណេះពិសេសជាចំណែកមួយផ្សេង ដោយឡែកខាងសិល្បៈ ឬខាងមុខវិជ្ជាណាមួយយ៉ាងស្ទាត់ជំនាញ ។

បរិភោគ (ប-រិ-ភោគ) *ន.* ការចម្អែតអាត្មា ។

បារម្ភ (បា-រ៉ម់) *ន.* ដំណើរនឹកថប់ ឬនឹកព្រួយជាមុន ការភ័យខ្លាចមិនដឹងមុខ ។

បរិសុទ្ធ (ប-រិ-សុត) *គុ.* ដែលស្អាត ឥតសៅហ្មង : ចិត្តបរិសុទ្ធ ។

បាយសី *ន.* កំណាត់ដើមចេកមានជើងដោតបញ្ឈរ មានរមូរស្លឹកចេកសណ្ឋានម្រាមដៃដោតជាថ្នាក់ៗមាន ៣ ថ្នាក់ ៥ ថ្នាក់ ៧ ថ្នាក់ ៩ ថ្នាក់ មានដោតផ្កាលាយចម្រុះ មានដាក់បាយព្រលឹង ឬលាជ ។

បិណ្ឌ (បិន) *ន.* ការប្រមូលឱ្យមូល ឬពូតឱ្យជាដុំ ។ (ខ្មែរយើងប្រើពាក្យនេះជាឈ្មោះនៃវិធីធ្វើទានមួយយ៉ាង) ។

បិតា (បិ-ដា) *ន.* ឪពុក ។

បុត្រ (បុត) *ន.* កូនប្រុស ។

បុរាណ (បុ-រ៉ាន) *គុ.* ចាស់ ដែលកើតមានមុន ដែលមានយូរហើយ ។

បរិក្ខារ (ប ឬ ប៉ះ -រិក - ខា ) *ន.* គ្រឿងប្រដាប់ , គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ ។

បូជា *កិ.* ថ្វាយ ជូន : សូមបូជាកម្រងផ្កានេះចំពោះព្រះរតនត្រ័យ , ដុត : បូជាសព ។

ប្រការ *ន.* វិធី បែប ប្រភេទ ។

ប្រគេន *កិ.* លើកឱ្យដល់ដៃព្រះសង្ឃ ។

ប្រតិបត្តិ (ប្រះ-តិ-ប័ត) *ន.* ការប្រព្រឹត្តិ ការធ្វើតាម ។

ប្រទក្សិណ (ប្រ-ទ័ក-សិន ) *កិ.* ការសម្តែងសេចក្តីគោរព ឬសេចក្តីស្រឡាញ់ដោយដើរព័ទ្ធជុំវិញបុគ្គល ឬវត្ថុអ្វីៗឱ្យបុគ្គល ឬវត្ថុនោះនៅខាងស្តាំដៃ ។

ប្រផ្នូល *ន.* ហេតុដែលបណ្តាលឱ្យឃើញមុន ហេតុភេទដែលដឹងដោយបបូល ឬផ្សង ។

ប្រពៃណី (ប្រ-ពៃ-នី) *ន.* ទំនៀមទម្លាប់ដែលប្រជាជនក្នុងប្រទេសនិយមអនុវត្ត ។

ប្រាថ្នា *ន.* ការតាំងបំណង ការផ្តង ឬតាំងសូមសំណូម សូមឱ្យបាន សម្រេចដូចបំណង : មានប្រាថ្នា តាមប្រាថ្នា បានសម្រេចដូចប្រាថ្នា ។

ប្រមាថ (ប្រ-ម៉ាត) *កិ.* ចៀតចៀន មើលងាយ ។

ប្រសូត *កិ.* សម្រាលកូន ឆ្លងទន្លេ ។

ប្រារព្ធ (ប្រា-រប់) *ន.* តាំងផ្តើម ផ្តួចផ្តើម ផ្តងជាមុន គិតដល់ ។

## ផ

ផ្លាក ន. ប្រដាប់ធ្វើពីបន្ទះឈើ លោហៈ ឬក្រដាសរឹងសម្រាប់ធ្វើជាសញ្ញាសម្គាល់ ធ្វើជាយីហោជាដើម : ផ្លាកយីហោ ។

## ព

ពង្ស (ពង់) *ន.* វង្ស ត្រកូល ពូជ អម្បូរ ។

ពណ៌នា (ព័រ-ណះ-នា) *កិ.* ពោលរៀបរាប់ អធិប្បាយសេចក្ដី ។

ព័ទ្ធ (ព័ត) *កិ.* ចោមជុំវិញ ចោមស្ទាក់ជុំវិញមិនឱ្យផ្លូវចេញរួច : ព័ទ្ធចោរ វល្លិព័ទ្ធដើមឈើ ។

ពន់ប្រមាណ (ពន់-ប្រ-ម៉ាន) *គុ.* ហួសប្រមាណ ។

ពន្លះ *កិ.* អារលះកាត់ឱ្យដាច់ចេញដោយឡែកពីគ្នា គឺអារលះស្បែកចេញពីសាច់ ឬយកសាច់ចេញពីឆ្អឹង : ពន្លះស្បែក ពន្លះសាច់ ។

ពពិល *ន.* ប្រដាប់ធ្វើដោយលោហជាតិ មានសណ្ឋានស្រដៀងនិងស្លឹកពោធិ៍ សម្រាប់បិទទៀនអុជកាន់បន្តគ្នា បង្វិលបក់ផ្សែងចូលជុំវិញមនុស្ស ឬរបស់អ្វីដើម្បីឱ្យកើតស្រីសួស្ដី ។

ពុទ្ធសករាជ (ពុត -សៈ -កៈ -រ៉ាច) *ន.* ចំនួនថ្ងៃខែឆ្នាំរាប់តាំងពីក្រោយថ្ងៃដែលព្រះពុទ្ធចូលបរិនិព្វានទៅបានមួយថ្ងៃរៀងមក ។

ពានា *កិ.* យកសំពត់គ្របដណ្ដប់ព័ទ្ធធៀងស្នាម្ខាង ។

ពាលា *គុ.* មិនល្អ អាក្រក់ ។

ពិចារណា (ពិ-ចា -រ៉ៈ -ណា) *កិ.* ត្រិះរិះ រំពឹង គិតគូរ : ធ្វើការពិចារណា ។

ពិនិត្យ (ពិ -និត) *កិ.* ពិចារណា សង្កេតមើលដោយល្អិតល្អ ។

ពិភាក្សា (ពិ -ភាក -សា ) *កិ.* ជជែក ពិគ្រោះគ្នា ប្រឹក្សាគ្នា ។

ពិសា *កិ.* (ពាក្យគួរសម) ហូប បរិភោគ ស៊ី ។

ពុត *ន.* កិច្ចកលមាយា បង្វែងដំណើរឱ្យឃ្លាតចាកសេចក្ដីពិត : មានពុត ធ្វើពុត ។

ពេចន៍ (ពេច) *ន.* ពាក្យ សម្ដី : ពាក្យពេចន៍ ។

ព្យាបាល *កិ.* រក្សាជំងឺ ទ្រាំជំងឺ ។

ព្រហ្មគីតិ (ព្រំ -មៈ -គីតិ ឬ គីត) *ន.* ឈ្មោះកាព្យមួយយ៉ាងក្នុងមួយវគ្គមានបួនឃ្លា ត្រង់ឃ្លាទី១ និងទី៣មាន៥ព្យាង្គ ឃ្លាទី២ និងឃ្លាទី៤មាន៦ព្យាង្គ ។

ព្រឹត្តិការណ៍ (ព្រឹត-តិ-កា ) *ន.* ហេតុ ឬដំណើរដែលតែងកើតមានជាធម្មតា : ថ្ងៃនេះ មានព្រឹត្តិការណ៍ប្លែកៗ ។

ព្រះត្រៃបិដក (ព្រះ-ត្រៃ-បី-ដក់) *ន.* ប្រជុំនៃព្រះធម៌ក្នុងពុទ្ធសាសនាដែលចែកចេញជាបីផ្នែក គឺព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម ។

ព្រះបរិត្ត (ព្រះ-ប៉ះ-រិត) *ន.* ធម៌សម្រាប់ការពារសេចក្ដីអន្តរាយ ។

ព្រាហ្មណ៍ (ព្រាម) *ន.* មនុស្សដែលកំណត់តាមលទ្ធិបុរាណពីព្រេងនាយ ថាមានពូជ ដើមកើតអំពីព្រះឧស្សព្រហ្ម ។

## ភ

ភរិយា (ភៈ-រិ-យា) *ន.* ប្រពន្ធ ។

ភោជនាហារ (ភោជៈ-នា-ហា) *ន.* អាហារសម្រាប់បរិភោគ ។

ភ្វា *គុ.* ពុំងា ប្រសើរ ថ្លៃថ្លា ជាទីស្រឡាញ់ ។

## ម

មច្ឆជាតិ (ម័ច-ឆៈ-ជាត) *ន.* ពួកត្រីទាំងពួង ។

មតិ (មៈ-តិ) *ន.* គំនិត យោបល់ ។

មធ្យោបាយ (ម័ត-ធ្យោ-បាយ) *ន.* ឧបាយជាកណ្ដាល ដំណើរទំនងដ៏ល្មមគួរសម គួរសម្រាប់ធ្វើកិច្ចការឱ្យបានសម្រេចតាមបំណង ។

មនសិការ (មៈ-នៈ-សិការ៉ៈ-ប-កា) *ន.* ដំណើរយកចិត្តទុកដាក់ ។

មនុស្សធម៌ (មៈ-នុស-សៈ-ធ័រ) ន. ច្បាប់សម្រាប់ប្រដៅពួកមនុស្ស ឱ្យប្រព្រឹត្តសុចរិត ។

មរណកាល (មៈ-រៈ-ណៈ-កាល) *ន.* ស្លាប់ ឬសេចក្ដីស្លាប់ ។

មាតា (មា-ដា) *ន.* ម្ដាយ ម៉ែ ។

មាតុភូមិ (មាតុ-ភូម) *ន.* ស្រុកកំណើត ប្រទេសកំណើត ។

មិគសិរ (មិគៈ-សេ) *ន.* ឈ្មោះខែទី១ នៃចន្ទគតិ មាន២៩ថ្ងៃ ។

មុសា *គុ.* ឬ *គុ.កិ.* ដែលកុហក មិនពិត ខុស ខទេ ។

មេគង្គ (មេ-គង់) *ន.* មេទឹក មហានទីឈ្មោះទន្លេដែលមានប្រភពចេញពីទីបេត៍ ដែលហូរឆ្លងកាត់ប្រទេសចិន មីយ៉ានម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម ។

មោហោ *ន.* អវិជ្ជា សេចក្ដីវង្វេង សេចក្ដីល្ងង់ ឬភ័ន្តស្មារតីមិនយល់ការណ៍ពិតមិនស្គាល់ខុសត្រូវ ។

មោះមៃ *ន.* ការទាស់ហេតុ ទាស់ដំណើរ សេចក្ដីហ្មងឆ្គង សេចក្ដីខុសឆ្គង ។

## យ

យុត្តិធម៌ (យុត - តិ - ធ័រ) ន. សេចក្តីទៀងត្រង់ មិនលម្អៀង ។

## រ

រថ (រត់) ន. រទេះទឹមសេះ ។

រន្ធ (រន់ ) ន. រូង ប្រហោង រូងទាល់ ។

រន្ធត់ (រន់-ធត់)គុ. ដែលភ័យស្លុត ។

រម្យទម (រំ - ទំ) គុ. ស្រគត់ស្រគំ ដែលសុភាពរាបសា ។

រាជរដ្ឋាភិបាល (រាច-រ័ត-ថា-ភិ-បាល)ន. រដ្ឋាភិបាលនៃព្រះរាជា ការគ្រប់គ្រងរដ្ឋដែលទាក់ទងដោយព្រះមហាក្សត្រិយ៍ ។

រាយការណ៍ (រាយ-កា ) កិ. ថ្លែងរៀបរាប់សេចក្តីតាមដំណើរ ឬតាមកិច្ចការ ។

រុក្ខទេវតា (រុក -ខៈ -ទេវៈ -ដា) ន. ទេវតាដែលអាស្រ័យនៅលើដើមឈើ ។

រូបសម្បត្តិ (រូប -សំ-ប័ត) ន. ដំណើរមានរូបសមរម្យ មានរូបល្អ ។

រេល គុ. ជ្រុលជ្រាលអំពីគំនរ រណែល ទ្រេល ។

រ៉ែ ន. លោហធាតុផ្សេងៗ កើតនៅក្នុងដីដែលជីកគាស់យកមករម្លាយសម្រាំងយកតែសាច់បានជាលោហជាតិតាមកំណើតដើម : រ៉ែសំណ រ៉ែស្ពាន់ រ៉ែដែក ។ល ។

រោច ន. ថ្ងៃខាងរនោចនៃខែចន្ទគតិ គឺថ្ងៃដែលមានពន្លឺព្រះចន្ទ្រថយចុះដូចគេចាប់រោច ។

## ល

លទ្ធភាព (ល៉ុត -ធៈ -ភាប ) ន. ភាពនៃអ្វីៗដែលបានសម្រេចហើយ ភាពដែលអាចធ្វើកើត ។

លិខិត ន. សំបុត្រ ។

លិខិតឆ្លងដែន ន. លិខិតផ្តល់ឱ្យអ្នកដំណើរឆ្លងប្រទេសនីមួយៗ ។

លើសលប់ គុ.កិ. លើសហួសកំណត់ ហួសប្រមាណ ។

លោកា ន. លោកទាំងឡាយ ។

លំនៅដ្ឋាន (លំ -នៅ -ឋាន ) ន. ផ្ទះ ។

ល្បាក់ ន. ថ្នាក់ដែលបាក់របេះ ឬដែលមានសណ្ឋានដូចគេលាក់ ឬដូចជាបាក់ ។ ស្ថានដីដែលមានទម្រង់ដូចគេលាក់ ភាគច្រើនមានទឹកហូរធ្លាក់ចេញពីកន្លែងនោះ ។

## វ

វង្ស (វង់) ន. ពូជ ត្រកូល ក្រសែ តំណត្រកូល ។

វចនានុក្រម (វៈ-ចៈ-ន៉ា-នុ-ក្រំ) ន. កម្រងពាក្យដែលគេរៀបពាក្យលំដាប់អក្សរ និងមានការពន្យល់ន័យពាក្យទាំងនោះ ។

វីធ (វាត់) កិ. ដួសន្ធិះខ្លាំងដោយចុងស្នែង : ក្របីវីធ ។

វន្ទា (វ័ន-ទា) កិ. ថ្វាយបង្គំ សំពះ គំនាប់ ។

វន្ទីយ៍ (វ័ន-ទី) កិ. ថ្វាយបង្គំ សំពះ គំនាប់ ។

វាចា ន. សម្ដី ។

វារី ន. ទឹក ។

វិចិត្រ (វិ-ចិត) គុ. ល្អ ល្អប្លែក ។

វិជ្ជាជីវៈ (វិច-ជា-ជី-វៈ) ន. មុខតំណែង មុខការរបរសម្រាប់ចិញ្ចឹមជីវិត ។

វិញ្ញាណក្ខន្ធ (វិញ-ញាន-ណ័ក-ខ័ន) ន. កងវិញ្ញាណដែលរាប់បញ្ចូលក្នុងខន្ធ៥ ។

វិន័យ (វិ-នៃ) ន. ច្បាប់ដឹកនាំទៅរកផ្លូវល្អ ។

វិនាស កិ. ខូចបង់ ខូចខាត បាត់បង់ ។

វេទនា (វេ-ទៈ-នា) ន. ការទទួលអារម្មណ៍ជាទុក្ខ ។

វេរ (វេ) កិ. ប្រគល់ ឬប្រគេនអ្វីៗចំពោះមនុស្សណាម្នាក់ ឬចំពោះព្រះសង្ឃ ។

## ស

សង្ខារ (សង់-ខា) ន. ជីវិត គំនិត អ្វីៗទាំងពួងក្នុងលោក ។

សង្គម (សង់-គំ) ន. ការប្រជុំគ្នា ការប្រមូលរួបរួមផ្ដុំមនុស្ស ។

សច្ចៈ (ស័ច-ចៈ) ន. សេចក្ដីពិត ដំណើរទៀង ទៀងទាត់ ។

សច្ចធម៌ (ស័ច-ចៈ-ធ័រ) ន. ធម៌ដែលមានពិត ធម៌ដែលកើតឡើងពិត ។

សញ្ជាតិ (ស័ញ-ជាត) ន. កន្លែងដែលកើត ស្រុកកំណើត ឫសគល់កំណើត ដើមកំណើត ។

សញ្ជឹង កិ.វិ. ទ្រឹងសញ្ជឹងគិតដោយអាការក្រៀមក្រំ ។

សទ្ធា (ស័ត-ធា) ន. ជំនឿ ។

សន្តាន (សន់-ដាន) ន. ពូជពង្ស វង្សត្រកូល ។

សន្តិភាព (សន់-តិ-ភាប) ន. ភាពឬដំណើរស្ងប់ សាន្តត្រាណ ដំណើរសះជានឹងគ្នា ។

| | | |
|---|---|---|
| សប្បុរស | (សប់-បុ-រ៉ស់)គុ. ល្អ ប្រសើរ ត្រឹមត្រូវ ។ |
| សប្បុរសជន | (សប់-បុ-រ៉ស-ជន់)ន. អ្នកមិនធ្វើអំពើអាក្រក់ដោយកាយ វាចា ចិត្ត អ្នកត្រឹមត្រូវ ។ |
| សព | (សប់ ) ន. រូបបុគ្គលដែលស្លាប់ ខ្មោចស្រស់ សាកសព : តម្កល់សព បុណ្យសព ។ |
| សមណគោតម | (សះ-មះ-ណះ-កោត-ដំ) ន. ព្រះបរមនាមរបស់ព្រះសក្យមុនីសម្ពុទ្ធ ។ |
| សមរម្យ | (សំ -រំ ) កិ.វិ. ដែលត្រូវបែប ត្រូវយ៉ាង មិនទាស់ភ្នែក ។ |
| សមាជិក | (សះ-ម៉ា -ជិក ) ន. អ្នកដែលមានអំណាចចូលកាន់ទីប្រជុំបាន អ្នកចូលរួមក្នុងអង្គការនយោបាយសមាគម គ្រួសារ ។ |
| សម្ព័ន្ធ | (សំ-ពាន់) ន. ការចងភ្ជាប់គ្នា ការតភ្ជាប់គ្នា ដំណើរទាក់ទងរកគ្នា ។ |
| សម្រក | (សំ -រ៉ក) ន. រដូវទឹកស្រក ។ |
| សហគមន៍ | (សះ-ហះ- គំ) ន. ប្រជុំភូមិ ឬតំបន់អ្នកស្រុកប្រកបរបរចូលគ្នា ។ |
| សហាយ | (សះ-ហាយ ) ន. បុរសស្ត្រីដែលខូចកាចនឹងគ្នា ។ |
| សាមគ្គី | (សា -ម៉ុក -គី ) ន. សេចក្ដីព្រមព្រៀង សេចក្ដីព្រមព្រីសជាមួយគ្នា ដំណើរស្រុះគ្នា ។ |
| សាសនា | (សា - ស្នា) ន. ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ ។ |
| សិក្សា | (សិក - សា ) ន. ការរៀនសូត្រ ។ |
| សិទ្ធិ | (សិត - ធិ) ន. អំណាច ការសម្រេច មុខការដែលត្រូវសម្រេចលើខ្លួន ។ |
| សីលធម៌ | (សិល- លះ ធ័រ)គុ. ដំបូន្មានដែលនាំឱ្យវៀរចាកអំពើអាក្រក់ហើយឱ្យប្រព្រឹត្តតែអំពើល្អ ។ |
| សីល១០ | (សិល- ដប់) ន. សីលសម្រាប់សមណេរនិងគ្រហស្ថ ។ |
| សិរី | (សិ-រ៉ី)ន. មង្គល សួស្ដី សេចក្ដីសុខ ។ |
| សុចរិត | (សុ- ចះ- រិត ) ន. ការប្រព្រឹត្តិល្អ ការធ្វើត្រឹមត្រូវ ។ |
| សុជីវធម៌ | (សុ -ជី -វះ -ធម៌ ) ន. ការរស់នៅដោយល្អ ។ |
| សុភមង្គល | (សុ -ភះ -មង់ -គល់ ) ន. សេចក្ដីសុខទាំងផ្លូវកាយ និងផ្លូវចិត្ត ។ |
| សេដ្ឋកិច្ច | (សេត- ថះ- កិច)ន. មុខរបរដ៏ឧត្ដម មុខការរបរដែលមានប្រយោជន៍ដ៏សំខាន់ក្នុងប្រទេសនីមួយៗ : សេដ្ឋកិច្ចជាតិ ។ |
| សេព | (សែប) ន. ផឹក ប្រើប្រាស់ ប្រព្រឹត្ត ។ |
| សេពគប់ | (សែប -គប់) កិ. រាប់រកយកជាគ្នា ។ |
| សោភ័ណ | (សោ-ភន់)គុ. ល្អ ហ្មត់ហ្មង ប្រសើរ ។ |

សោមនស្ស (សោមៈ-ន័ស) *ន.* សេចក្តីសប្បាយចិត្ត ។

ស្តុកស្តម្ភ (ស្តុក- ស្តំ) *គុ.* មាំមួន បរិបូណ៌ មានច្រើន ។

ស្មារតី (ស្មា-រ-ដី) *ន.* សេចក្តីនឹកឃើញ ការចាំបាន ការរឭកឃើញមិនភ្លេច ។

ស្មោះសរ (ស្មោះ-ស) *ន.* សេចក្តីរីករាយរាក់ទាក់ សេចក្តីរួសរាយ សាទរ ។

ស្លាក *ន.* សំបុត្រជាកំណាត់តូចៗ ជាគ្រឿងសម្គាល់ឈ្មោះជាដើម : សរសេរស្លាក បិទស្លាកជាសម្គាល់ ។

## ហ

ហេតុការណ៍ (ហែត-កា) *ន.* ការ ឬដំណើរប្រព្រឹត្តទៅ ដំណើរ ឬរឿងដែលកើតឡើង ។

ហ្មងសៅ (ម៉ង-សៅ) *កិ.* មានមន្ទិល មិនបរិសុទ្ធ ។

## ឡ

ឡូ *ន.* ចំណែកផ្សេងៗក្នុងការបែងចែក ឬចំនួនផ្សេងដែលបែងចេញជាភាគ : ដីមួយឡូ ផ្លែឈើមួយឡូ ។

## អ

អគារសិក្សា (អៈ-គា-សិក-សា) *ន.* សាលារៀន ។

អង្គការ (អង់-កា) *ន.* បែបផែនរបៀបរៀបចំកិច្ចការដែលរដ្ឋ ឬក្រុមរាជការណាមួយបង្កើតឡើង ដើម្បីប្រព្រឹត្តទៅកាន់សេចក្តីចម្រើន ទីកន្លែងចាត់ការធំៗ ។

អត្ថន័យ (អ័ត-ថៈ-នៃ) *ន.* ការពន្យល់ សេចក្តី ការរៀបរាប់លក្ខណៈនៃវត្ថុផ្សេងៗ ។

អធិកអធម (អៈ-ធិក-អៈ-ធំ) *គុ.* ហ៊ឹកហ៊ាក់ ក្រៃលែង លើសលន់ រុងរឿង ។

អធ្យាស្រ័យ (អ័ត-ធ្យា-ស្រៃ) *ន.* បំណង ចំណងចិត្ត ។

អនាគត (អៈ-ន៉ា-គត់) *ន.* ពេលខាងមុខ ។

អលង្ការ (អៈ-លុង់-កា) *ន.* គ្រឿងប្រដាប់សម្រាប់តុបតែងខ្លួន (មានចិញ្ចៀន ខ្សែដៃ កងដៃ) ។

អលជ្ជី (អា-ល័ច-ជី) *គុ.* ដែលឥតខ្មាស ។

អាកប្បកិរិយា (អា-ក័ប-ប៉ៈ-កិ-រ៉ិ-យ៉ា) *ន.* អាការនៃរាងកាយ ដំណើរ ឬលំនាំរាងកាយ ឬឫកពា ។

អាការ (អា-កា-រ៉ៈ ឬអាការ) *ន.* គ្រឿងសម្គាល់ លក្ខណៈជាគ្រឿងសម្គាល់ ។

អាចារ្យ (អា-ចា) *ន.* អ្នកប្រដៅ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ ។

អាជីព (អា-ជីប) *ន.* ការចិញ្ចឹមជីវិត ដំណើរធ្វើការរបរចិញ្ចឹមជីវិត មុខរបរ ។

អាណិកជន (អាណិក -កៈ -ជន់ ) ន. ជនជាតិមួយដែលទៅរស់នៅប្រទេសផ្សេងទៀត ហើយចូលសញ្ជាតិជនជាតិនេះ ។

អាត្មា ន. ខ្លួន : រកស៊ីចិញ្ចឹមអាត្មា ។

អាពាហ៍ពិពាហ៍ (អា -ពា -ពិ -ពា ) ន. ការរៀបការ ពិធីមង្គលការ ។

អារម្មណ៍ (អា -រ៉ម់ ) ន. ការដឹង គ្រឿងតោងនៃចិត្ត គ្រឿងទាក់ទាញ ។

អារាធនា (អា -រ៉ា -ធៈ -នា ) ន. ការនិមន្ត ការអញ្ជើញ ។

អាសន្ន (អា -សន់ ) គុ. ជិត ឧ. ភ័យអាសន្ន ភ័យជិត គឺហេតុដែលគួរខ្លាចនៅជិតបង្កើយ ។

អាសូរ កិ. អាណិតទន់ចិត្ត អាណិតខ្លោចចិត្ត ។

អ្នកនិពន្ធ (នាក់ -និ -ពន់ ) ន. អ្នកតាក់តែង ចងក្រង រៀបរៀង ។

ឥណទាន (អិ -ណៈ -ទាន ) ន. ការឱ្យខ្ចី ។

ឥរិយាបថ (អិ -រ៉ិ -យ៉ា -បត់ ) ន. ផ្លូវ ឬគន្លងឥរិយា គឺការដើរ ដេក ឈរ អង្គុយ ។

ឧត្តម (អ៊ុត -ដំ) គុ. ខ្ពង់ខ្ពស់ ល្អ ប្រសើរ ថ្លៃថ្លា ។

ឧបករណ៍ (អ៊ុ -ប៉ៈ- ក) ន. គ្រឿងប្រកបផ្សំគ្នា គ្រឿងប្រុង គ្រឿងប្រដាប់សម្រាប់ធ្វើការ ។

ឧទ្ទិសកុសល (អ៊ុត-ទិស-កុ- សល់ )កិ. បញ្ចេញវាចាផ្សាយផលជូនដល់អ្នកមានគុណ ឬអ្នកណាម្នាក់ ។

ឧបការី (អុ -ប៉ៈ -កា រី ) ន. អ្នកទំនុកបម្រុង អ្នកផ្គត់ផ្គង់ ឬផ្ទុងផ្តើម ។

ឧបជ្ឈាយ៍ (អ៊ុ -ប៉ច -ឈា ) ន. គ្រូបង្រៀនធម៌ គ្រូបង្រៀនច្បាប់ ។

ឧបត្ថម្ភ (អ៊ុប៉ុត -ថ័ម) ន. ការទំនុកបម្រុង ការផ្តល់ឱ្យ ការគាំទ្រ ការជួយ ។

ឧបាយ (អ៊ុ -បាយ) ន. ល្បិច កិច្ចកល កលមាយា ។

ឧបាយកល (អ៊ុ -បាយ -កល់) ន. ល្បិច កិច្ចកលផ្លូវគំនិត កលមាយា ។

ឧបាសិកា (អ៊ុ -បា -សិ -កា) ន. គ្រហស្ថស្រី ។

ឧស្ម័ន (អ៊ុស -ស្មាន់) ន. ចំហាយ ចំហាយក្តៅ ចំហាយភ្លើង កម្សួល ។

**យើងបម្រើសេវាកម្ម៖**

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

**WE SERVE:**

- book and teaching-aid development
- printing
- distribution to schools


គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ច)

PUBLISHING AND DISTRIBUTION HOUSE ( PDH )

# បណ្ណាគារ គ.ប.ច

# PDH BOOKSHOP

១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ទូរស័ព្ទ: ០២៣ ៦៣ ៦៣ ០៣៣ 148, Norodom Boulevard, Phnom Penh, Tel: 023 63 63 033



IBC INTERNATIONAL BOOK CENTER

$ 2.20


**មានលក់៖**

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

**SELLING:**

textbooks , teacher's manuals , workbooks , supplementary readers , teaching-aids and stationary !


9 789995 001438